សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **រិទ្ធ ច័ន្ទទេពី**
កញ្ញា **សាមិត្ត ឥត្ថី**

សាស្ត្រាចារ្យណែនាំ
លោក **ជិន ឥណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៧

ឆ្នាំចូលរៀន ២០១៣
ឆ្នាំសរសេរសារណា ២០១៧

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ២០១៧

ស្រាវជ្រាវដោយ		សាស្ត្រាចារ្យណែនាំ	
និស្សិតឈ្មោះ	កញ្ញា **រិទ្ធ ច័ន្ទទេពី**	លោក **ជិន ឥណ្ណារ៉ា**	
	កញ្ញា **សាមិត្ត ឥត្ថី**		
ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**		ឆ្នាំចូលរៀន	២០១៣
ជំនាន់ទី ១៧		ឆ្នាំសរសេរសារណា	២០១៧

សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ រិទ្ធ ច័ន្ទទេពី និង សាមិត្ត រត្ថ ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ

លោកអ្នកមានគុណទាំងពីរផ្តល់កំណើតដោយបានចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់រូបកូនធំពេញវ័យព្រមទាំងផ្តល់ដំបូន្មានប្រៀនប្រដៅនិងបានអោយកូនចូលសាលាដើម្បីក្រេប យកចំណេះដឹងតាំងពីបឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថែមទាំងជួយជ្រោមជ្រែងគ្រប់បែបយ៉ាង ទាំងស្មារតី និងសំភារៈ ដោយពុំដែរត្អូញត្អែរពីភាពនឿយហត់ និងលះបង់គ្រប់បែបយ៉ាងដែលលោកមានគុណទាំងទ្វេបានផ្តល់ ចំពោះកូនឡើយ មូលហេតុនេះហើយដែលជំរុញអោយយើងខ្ញុំទទួលបានជោគជ័យរហូតដល់បច្ចុប្បន្ននេះ ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យសាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រទាំងអស់** ដែលបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីបណ្តុះបណ្តាល ចែករំលែកចំនេះដឹងដែលលោកមាន ព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនក្នុងសង្គម មកបង្ហាត់បង្រៀនយើងខ្ញុំ និងមិត្តរួមថ្នាក់ទាំងអស់គ្នា គ្រប់មុខវិជ្ជាតាំងពីថ្នាក់មូលដ្ឋានរហូតដល់បាន បញ្ចប់ការសិក្សា ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកសាស្ត្រាចារ្យ ជិន រណ្ណារ៉ា** ដែលលោក បានទទួលយកការដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដោយលោកបាន ចំនាយពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ កម្លាំងចិត្ត ទាំងគំនិត ប្រាជ្ញា ដើម្បីបណ្តុះបណ្តាល និងពន្យល់ណែនាំរូបយើងខ្ញុំ ក្នុងរយៈពេលកន្លងមកនេះរហូតបានចងក្រងសារណាបញ្ចប់បរិញ្ញាបត្រ នេះដោយជោគជ័យ ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **លោកស្រីប្រធានការិយាល័យ ចាន់ សុជាតា និងសហការីនៃការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន** ដែលបានផ្តល់ឯកសារ និង ចំណាយពេលវេលាដ៏មានតម្លៃដោយមិនខ្លាចហត់នឿយសម្រាស់ការចង្អុលបង្ហាញការណែនាំ ព្រមទាំងជួយពិនិត្យអក្ខរាវិរុទ្ធ កែប្រែរាល់កំហុសឆ្គងថែមទៀតដែលជាកម្លាំងចិត្តជម្រុញ ឲ្យយើងខ្ញុំខិតខំបន្តការសិក្សាស្រាវជ្រាវនេះរហូតបានសម្រេច។

ជាទីបញ្ចប់យើងខ្ញុំបាទសូមគោរពជូនពរ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកសាស្ត្រាចារ្យ ជិន រណ្ណារ៉ា លោកស្រីប្រធានការិយាល័យ ចាន់ សុជាតា និង សហការី នៃការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន** សូមឲ្យសូមជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចំរើនសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ មានកម្លាំងពលំខ្លាំងក្លា ប្រាជ្ញាស្មារតីចងចាំបានល្អ និងមានឲ្យមាន សំណាងល្អគ្រប់ពេលវេលា ជាពិសេសសូមឲ្យទទួលបានជោគជ័យគ្រប់ភារកិច្ច។

អារម្ភកថា

សារណានេះ បានតាក់តែងឡើងនៅក្នុងឱកាសបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយក៏ជាឧបករណ៍មួយសម្រាប់បង្ហាញពីសមត្ថភាព និងចំនេះដឹង ដែលបានមកពីការខិតខំប្រឹងប្រែង និងសិក្សាស្រាវជ្រាវអស់រយៈពេល ៤ឆ្នាំនៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**។ សារណាដែលបានតាក់តែងឡើងមកនេះ គឺជាស្នាដៃថ្មីមួយសម្រាប់ជាគុណប្រយោជន៍ដល់ការសិក្សាសម្រាប់និស្សិតផ្នែកនីតិសាស្ត្រជំនាន់ក្រោយៗខាងមុខទៀត។

សព្វថ្ងៃនេះ ប្រទេសកម្ពុជាជាប្រទេសមួយដែលកំពុងតែអភិវឌ្ឍន៍ ដោយសង្កេតឃើញថាមានការរីកចំរើនគ្រប់វិស័យទាំងអស់ជាពិសេសគឺទៅលើសំណង់អាគារយ៉ាងប្រណីត ទំនើបៗ និងមានជាសុខភាព សម្រាប់ជាលំនៅឋានក្នុងការរស់នៅរបស់ប្រជាពលរដ្ឋដូចជាផ្ទះលែង ខុនដូ ភូមិគ្រឹះ ជាដើមដែលត្រូវបានរៀបចំបង្កើតឡើងដោយក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន។ ដោយសារតែប្រទេសកម្ពុជា ជាប្រទេសមានស្ថេរភាពយោបាយ និងសុខសន្តិភាពទើបមាន ក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនក្រៅប្រទេសជាច្រើន មកវិនិយោគទៅលើវិស័យអភិវឌ្ឍលំនៅឋាន គួរអោយកត់សម្គាល់។

ហេតុដូច្នេះហើយ ទើបយើងខ្ញុំបានខិតខំស្វែងរកឯកសារ នៅក្នុងស្ថាប័នដែលពាក់ពន្ធ័ក្នុងប្រទេសកម្ពុជាជាគោលបំណងគឺចង់យល់ដឹងអំពីប្រពន្ធ័ច្បាប់ និងសកម្មភាពនៃការប្រតិបត្តិនានារបស់អាជីវកម្មអភិវឌ្ឍលំនៅឋានរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដើម្បីប្រមូលនូវចំណេះដឹងថ្មីនិងបទពិសោធន៍ល្អៗសម្រាប់ចងក្រងនូវសៀវភៅមួយឈ្មោះថា " **ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន**" ។ យើងខ្ញុំជឿជាក់ថា តាមរយៈស្នាដៃនេះនឹងជួយឲ្យអ្នកសិក្សានិងមិត្តអ្នកអាន ឲ្យយល់កាន់តែច្បាស់អំពីនីតិវិធី និងកាតព្វកិច្ចផ្សេងៗនៃអាជីវកម្មអភិវឌ្ឍលំនៅឋានឲ្យស្របតាមមាគ៌ាច្បាប់ជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ទោះបីជាសារណាមួយនេះបានបង្កើតឡើងដោយការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងណាក្តី កំហុសឆ្គងដោយអចេតនាដូចជាការប្រើប្រាស់ពាក្យពេចន៍ ឃ្លាឃ្លោង និងប្រយោគជាដើម រមែងតែងតែកើតមានឡើងជាមិនខាន។ អាស្រ័យហេតុ រាល់មតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកសាស្ត្រាចារ្យ មិត្តនិស្សិតអ្នកអានទាំងអស់គឺជាចំណែកដែលមិនអាចខ្វះបាន ដើម្បីជាការចូលរួមកែលម្អ និងដើម្បីទុកជាមេរៀនសម្រាប់បង្កើនចំណេះដឹង។

មាតិកា

ទំព័រ

សេចក្តីផ្តើម **១**

ជំពូកទី១

ដំណាក់កាលដំបូងនៃក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

១.១. លក្ខណៈទូទៅនៃការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋាន **៣**

១.១.១ លក្ខខណ្ឌគ្រឹះ ៣

១.១.១.១ ការព្រមព្រៀង ៣

១.១.១.២ សមត្ថភាព ៣

១.១.១.៣ កម្មវត្ថុ ៣

១.១.១.៤ ដើមទុន ៥

១.១.២ លក្ខខណ្ឌបន្ថែមផ្សេងទៀត ៥

១.១.២.១ ទ្រង់ទ្រាយ ៦

១.១.២.២ នាមករណ៍ ៦

១.១.២.៣ ទីស្នាក់ការ ៧

១.១.២.៤ ថិរវេលា ៧

១.១.៣ ការចុះហត្ថលេខាលើលក្ខន្តិកៈ ៧

១.២. ការចុះបញ្ជីក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន **៩**

១.២.១ ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ៩

១.២.១.១ ឯកសារតម្រូវសំរាប់ចុះបញ្ជីក្រុមហ៊ុន ១០

១.២.១.២ របៀបនៃការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ១០

ក. ការបង្កើតគណនីប្រើប្រាស់ប្រព័ន្ធ ១១

ខ. ការត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍ ១១

គ. ការចុះបញ្ជីពាណិជ្ជកម្ម ១៣

ឃ. ការកែប្រែព័ត៌មានក្រុមហ៊ុន និងបោះពុម្ពវិញ្ញាបនបត្រ ១៥

១.២.២.ការចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ ១៦

១.២.២.១ កាតព្វកិច្ចនៃការចុះបញ្ជីពន្ធដារ ១៦

១.២.២.២ ការស្នើសុំចុះបញ្ជីពន្ធដារ ១៦
១.២.២.៣ ឯកសារ និងការតម្រូវ សម្រាប់ចុះបញ្ជីពន្ធដារ ១៧
១.២.២.៤ កម្រៃសេវាចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធ ១៨
១.២.២.៥ រយៈពេលទទួលបានការចុះបញ្ជីពន្ធដារ ១៨

ជំពូកទី២

នីតិវិធីតម្រូវបន្ថែមសម្រាប់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានមុនដំណើរការអាជីវកម្ម

២.១ អាជ្ញាបណ្ណអភិវឌ្ឍលំនៅឋាន ២០
២.១.១ ប្រភេទ និងថ្លៃអាជ្ញាបណ្ណ ២០
២.១.១.១ ប្រភេទអាជ្ញាបណ្ណ ២០
២.១.១.២ ថ្លៃអាជ្ញាបណ្ណ ២១
២.១.២ ការស្នើសុំអាជ្ញាបណ្ណ ២១
២.១.២.១ ឯកសារតម្រូវ ២២
ក. ឯកសារសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រភេទទី១ ..... ២២
ខ. ឯកសារសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រភេទទី២ ..... ២៣
២.១.២.២ កម្រៃសេវាសាធារណៈ ២៤
២.១.២.៣ ការត្រួតពិនិត្យ និងសំរេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ២៤
២.១.៣ ការដក ឬការផ្អាកអាជ្ញាបណ្ណ ២៥
២.២ លិខិតអនុញ្ញាតសាងសង់របស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ២៦
២.២.១ ការស្នើសុំលិខិតអនុញ្ញាតសាងសង់ ២៧
២.២.១.១ ខ្លឹមសារនៃពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ២៩
២.២.១.២ ការចុះហត្ថលេខារបស់ម្ចាស់គម្រោងលើពាក្យសុំ ៣០
២.២.១.៣ ការដាក់ពាក្យសុំនៅសាលាខេត្ត-ក្រុង ៣០
ក. បរិបថនៃការត្រួតពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ៣០
ខ. រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ៣២
២.២.១.៤ ការដាក់ពាក្យសុំនៅសាលារាជធានីភ្នំពេញ ៣២
ក. បរិបថនៃការពិនិត្យនិងសំរេចលើពាក្យសុំ ៣២
ខ. រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំ ៣២
២.២.១.៥ ការដាក់ពាក្យសុំ ទៅអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម

និងខុន្ទកាល័យទេសរដ្ឋមន្ត្រី ៣៤
ក. បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ៣៤
ខ. រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់..... ៣៤
២.២.២. សមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ៣៦
២.២.២.១ សមត្ថកិច្ចរបស់សាលារាជធានី ខេត្ត-ក្រុង ៣៦
២.២.២.២ សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល..... ៣៦
២.២.៣ ការស្នើសុំលិខិតបើកការដ្ឋាន ៣៧
២.២.៣.១ ការស្នើសុំលិខិតបើកការដ្ឋាននៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និងសុរិយាដីខេត្ត-ក្រុង ៣៨
២.២.៣.២ ការស្នើសុំលិខិតបើកការដ្ឋាននៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់..... ៣៩
២.២.៣.៣ ការរៀបចំបើកការដ្ឋាន ៤០
២.២.៤ ការសុំលិខិតអនុញ្ញាតចិទការដ្ឋាន ឬវិញ្ញាបនបត្រសំគាល់សំណង់ត្រឹមត្រូវ **៤១**
២.២.៥.សហគ្រាស ក្រុមហ៊ុនសិក្សាគម្រោងល្អង់ និងសាងសង់ និងក្រុមជាងសាងសង់.....**៤១**
២.២.៥.១ សមត្ថកិច្ចផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្ម.....៤២
២.២.៥.២ សមត្ថកិច្ចទទួលពាក្យសុំវិញ្ញាបនបត្រប្រកបអាជីវកម្ម.....៤២
២.២.៥.៣ សមត្ថកិច្ចចុះបញ្ជីប្រកបអាជីវកម្ម ៤៣

ជំពូកទី៣

ភាតព្វកិច្ចនៅពេលប្រតិបត្តិការអាជីវកម្ម និង ការដោះស្រាយវិវាទ

៣.១ ភាតព្វកិច្ចក្រោយទទួលបានអាជ្ញាបណ្ណ **៤៤**
៣.១.១ ភាតព្វកិច្ចជំហ្ជរបស់ក្រុមហ៊ុនអតិវឌ្ឍលំនៅឋាន ៤៤
៣.១.២ ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីគម្រោងអតិវឌ្ឍលំនៅឋាន ៤៥
៣.១.២.១. លក្ខខណ្ឌនៃការផ្សព្វផ្សាយ ៤៥
៣.១.២.២. ការទទួលខុសត្រូវលើការផ្សព្វផ្សាយ.....៤៦
៣.១.៣ កិច្ចឯកាលក់-ទិញលំនៅឋាន ៤៦

៣.១.៣.១.ការប្រតិបិត្តការលក់-ទិញ ៤៧
៣.១.៣.២. ការបំពេញលក្ខខណ្ឌលក់-ទិញ ៤៧
៣.១.៤ លំនៅឋានគំរូ ៤៨
៣.១.៥ ប្រាក់តម្កល់លើអាជីវកម្ម ៤៨
៣.១.៥.១ ការតម្កល់ប្រាក់អាជីវកម្ម ៤៩
៣.១.៥.២ ការដកប្រាក់តម្កល់ ៤៩
៣.១.៦ គណនីអភិវឌ្ឍលំនៅឋាន ៤៩
៣.១.៦.១ ការបើកគណនីអភិវឌ្ឍលំនៅដ្ឋាន ៥០
៣.១.៦.២ ការដកប្រាក់ពីគណនីអភិវឌ្ឍលំនៅឋាន ៥០
៣.១.៧ ការធ្វើរបាយការណ៍ ៥១
៣.២ ការដោះស្រាយវិវាទលើអាជីវកម្មអភិវឌ្ឍលំនៅឋាន ៥២
៣.២.១ ការផ្សះផ្សានិងដោះស្រាយវិវាទ ៥២
៣.២.១.១ ការផ្សះផ្សា ៥២
៣.២.១.២ ការដោះស្រាយវិវាទ ៥២
៣.២.២ ទោសប្បញ្ញត្តិ ៥៣
៣.២.២.១ អំពើការបំពានទៅលើអាជីវកម្ម ៥៣
៣.២.២.២ ការទទួលទោស ៥៤
ក. ទោសរដ្ឋបាល ៥៤
ខ. ទោសជាពិន័យអន្តរការណ៍ ៥៤

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ក/ សេចក្តីសន្និដ្ឋាន ៥៩
ខ/ អនុសាសន៍ ៦០
ឯកសារយោង
ឧបសម្ព័ន្ធ

សេចក្តីផ្តើម

សេចក្តីផ្តើម

ស្របពេលដែលប្រទេសកម្ពុជាកំពុងមានកំណើនសេដ្ឋកិច្ច កម្រិតជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាមានភាពប្រសើរគួរឲ្យចាប់អារម្មណ៍ ដែលជាកត្តាសំខាន់ធ្វើឲ្យប្រជាជនចាប់ផ្តើមមានគំនិតក្នុងការកែប្រែរបៀបរស់នៅរបស់គាត់តាមបែបទំនើបដែលពោរពេញដោយផាសុខភាព និងសុវត្ថិភាព។ កំណើនប្រជាជន និងគ្រួសារថ្មីដែលមានជីវភាពសមរម្យ ក៏ធ្វើឲ្យមានតម្រូវការនូវអាគារលំនៅដ្ឋានជាច្រើន។ ការអនុញ្ញាតឲ្យជនបរទេសមានសិទ្ធិទទួលបាននូវកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិគឺជាការវិវត្តន៍ដ៏សំខាន់ ដែលធ្វើឲ្យមានការអភិវឌ្ឍន៍លើវិស័យលំនៅឋានយ៉ាងខ្លាំង ដោយសារ ជនបរទេសជាច្រើនបានសម្រេចចិត្តមកធ្វើការ ធ្វើជំនួញ និងតាំងទីលំនៅនៅប្រទេសកម្ពុជា។ ក្នុងន័យនេះ ធ្វើឲ្យមានតម្រូវការនូវលំនៅឋានបែបអាគារសហកម្មសិទ្ធិ (ខុនដូ) ជាច្រើន។ ជាលទ្ធផលក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានបានធ្វើការអភិវឌ្ឍន៍នូវអាគាលំនៅឋានជាច្រើនប្រភេទនេះឡើងដើម្បីឆ្លើយតបនូវតម្រូវការទាំងក្នុងស្រុក និងបរទេសនេះឡើង។

តួយ៉ាងរាល់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវធ្វើការចុះបញ្ជីអោយបានត្រឹមត្រូវតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានឹងទទួលបានការអនុញ្ញាតពី ក្រសួងពាណិជ្ជកម្មនិងជូនដំណឹងទៅអគ្គនាយកពន្ធដារ។ បន្ទាប់ពីក្រុមហ៊ុនក្លាយជានីតិបុគ្គលត្រឹមត្រូវតាមច្បាប់ហើយក្រុមហ៊ុនត្រូវរៀបចំនៅផែនការអាជីវកម្ម រយៈពេលសាងសង់និងគំរូប្លង់សាងសង់អោយបានច្បាស់លាស់មុននឹងក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានការស្នើសុំអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ម្យ៉ាងណាមិញដើម្បីអោយក្រុមហ៊ុនអភិវឌ្ឍលំនៅឋានចាប់ផ្តើមធ្វើការសាងសង់គម្រោងអគារលំនៅឋានរបស់ខ្លួនបាន និងអាចក្លាយជាអ្នកអាជ្ញាបណ្ណអភិវឌ្ឍលំនៅបានពេញលេញ លុះត្រាតែទទួលបានការអនុញ្ញាតត្រឹមត្រូវពីក្រសួងដែនដី រូបនីយកម្ម និងសំណង់ផងដែរ។ រាល់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលចង់ក្លាយជាក្រុមហ៊ុននាំមុខគេក្នុងវិស័យអាជីវកម្មអភិវឌ្ឍលំនៅឋាន នៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនត្រូវអនុវត្តកាតព្វកិច្ចតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ។ ចំពោះគម្រោងអភិវឌ្ឍន៍លំនៅឋានត្រូវតែបំពេញអតិថិជនប្រកបដោយប្រសិទ្ធិភាពខ្ពស់ ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន និងអ្នកប្រើប្រាស់។

ការសិក្សាលើប្រធានបទ **ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន** ត្រូវបានធ្វើឡើងដោយសារតែក្រុមហ៊ុននេះបានរួមចំណែកយ៉ាងខ្លាំង ក្នុងវិស័យសេដ្ឋកិច្ចជាតិតាមរយៈការប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានដែលមានគុណភាព និងធានាចីរភាពនៃការអភិវឌ្ឍន៍វិស័យ អចលនវត្ថុ សំដៅដល់កំណើន

សេដ្ឋកិច្ចជាតិហើយតាមរយៈការសិក្សាបានបង្ហាញថាការ ធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋានកំពុងរីកដុះដាល ហើយក៏ជាអាជីវកម្មដែលកំពុងពេញនិយមនៅព្រះរាជាណាចក្រកម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានក៏ជាវិស័យមួយដែលបានរួមចំណែកជួយផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាជាច្រើនផងដែរ។

ចំណោទបញ្ហាត្រូវបានចោទឡើង បន្ទាប់ពីយើងបានស្គាល់ដោយសង្ខេបពី ក្រុមហ៊ុនអភិវឌ្ឍលំហានហើយ ដើម្បីបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋានក៏ដូចជាការអនុវត្តន៍អាជីវកម្មអាចប្រព្រឹត្តទៅដោយរលូននឹងស្របច្បាប់ តើត្រូវបំពេញបទដ្ឋានគតិយុត្តអ្វីខ្លះ?ទៅតាមស្ថាប័នណាខ្លះ? បន្ទាប់ពីក្លាយជាក្រុមហ៊ុនអភិវឌ្ឍលំនៅឋានហើយ តើមានអាជីវកម្មអភិវឌ្ឍលំនៅឋានមានកាតព្វកិច្ចដូចម្តេចខ្លះ?

ទាក់ទិននឹងប្រធានបទខាងលើដោយធ្លាប់មានប្រកាសលេខ១២២២ សហវ.ប្រកចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ប៉ុន្តែត្រូវបាននិរាករណ៍ហើយត្រូវបានប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋានមានអានុភាពអនុវត្តជំនួសវិញ។ដើម្បីធ្វើការសិក្សាអោយបានលំអិត និង ឆ្លើយតបទៅនឹងចំណោទបញ្ហាដែលបានចោទសួរខាងលើអោយបានស៊ីជម្រៅ យើងខ្ញុំបានបែងចែកអត្ថបទនេះជាជំពូកដូចខាងក្រោម ៖

- **ជំពូកទី១ ដំណាក់កាលដំបូងនៃការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន** ដែលក្នុងនេះយើងនឹងធ្វើការបង្ហាញពី ចំនុចដំបូងនៃការបង្កើត លក្ខខណ្ឌ នីតិវិធី នៃការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងអគ្គនាយដ្ឋានពន្ធដារ ដែលជាភាពចំបាច់ដែលក្រុមហ៊ុនត្រូវបំពេញ។
- **ជំពូកទី២នីតិវិធីតម្រូវពិសេសសម្រាប់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានមុនដំណើរការអាជីវកម្ម** ដែលយើងនឹងលើកយកអំពីប្រភេទទំហំរយៈពេលនិងនីតិវិធីដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតម្រូវ ហើយនឹងបង្ហាញពីការស្នើសុំលិខិតអនុញ្ញាតសាងសង់នៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ មុនដំណើរការសាងសង់គម្រោងអភិវឌ្ឍលំនៅឋាន។
- **ជំពូកទី៣ កាតព្វកិច្ចក្រោយទទួលបានអាជ្ញាបណ្ណ និងការដោះស្រាយវិវាទលើអាជីវកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន** ដែលក្នុងនោះពួកយើងនឹងធ្វើការជម្រាបពីកាតព្វ កិច្ចក្រុមហ៊ុនដែលតម្រូវដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តម្រូវក្នុងអំឡុងពេលដំណើរការអាជីវកម្ម និងការដោះស្រាយវិវាទផ្សេងៗ ខណៈពេលក្រុមហ៊ុនកំពុងដំណើរការនៃក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋាន។

ជំពូកទី១
ដំណាក់កាលដំបូងនៃការ
បង្កើតក្រុមហ៊ុន
អតិថិជ្ញលំនៅឋាន

ជំពូកទី១
ដំណាក់កាលដំបូងនៃការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន គឺជាក្រុមហ៊ុនមួយដែលធ្វើអាជីវកម្មទៅលើការលក់លំនៅឋានជាច្រើនប្រភេទមានដូចជា ផ្ទះល្វែង អាគារសហកម្មសិទ្ធិ ភូមិគ្រឹះគ្រប់ប្រភេទ និងសំណង់ផ្សេងទៀតទៅឱ្យអ្នកទិញលំនៅឋាន មានន័យថាក្រុមហ៊ុននេះធ្វើសកម្មភាពពាណិជ្ជកម្ម ឬវិនិយោគគ្រប់ប្រភេទដែលមានកម្មវត្ថុជាការសាងសង់លំនៅឋានសម្រាប់លក់ ដើម្បីស្វែងរកចំនេញ។ នៅក្នុងដំណាក់កាលដំបូងនៃការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដើម្បីឲ្យអាចក្លាយជានីតិបុគ្គលពេញលេញបាន យើងខ្ញុំនឹងបង្ហាញអំពី លក្ខណៈទូទៅនៃការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន (១.១) និងការចុះបញ្ជីបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន(១.២)។

១.១ លក្ខណៈទូទៅនៃការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

ដំណាក់កាលដំបូងនៃ ការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវគោរព និងបំពេញទៅតាមលក្ខខណ្ឌមួយចំនួន បានឆ្លុះបញ្ចាំងពីលក្ខណៈទូទៅនៃការបង្កើតក្រុមហ៊ុនដែលបានបែងចែកជាលក្ខខណ្ឌគ្រឹះ(១.១.១) លក្ខខណ្ឌបន្ថែមលើលក្ខខណ្ឌគ្រឹះ(១.១.២) និងការចុះហត្ថលេខាលើលក្ខន្តិកៈ(១.១.៣)។

១.១.១ លក្ខខណ្ឌគ្រឹះ

ជាគោលការណ៍ការបង្កើតក្រុមហ៊ុនអភិវឌ្ឍលំនៅឋានមួយបានលុះត្រាសមាជិក ភាគហ៊ុននៃក្រុមហ៊ុនទាំងអស់បង្ហាញ និងបញ្ជាក់នូវលក្ខខណ្ឌគ្រឹះ ដែលមាន ការព្រមព្រៀង(១.១.១.១) សមត្ថភាព(១.១.១.២) កម្មវត្ថុ(១.១.១.៣) និង ដើមទុន(១.១.១.៤)។

១.១.១.១ ការព្រមព្រៀង

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានជាប្រភេទក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលមានសមាជិកភាគហ៊ុនចាប់ពី ០២ (ពីរ)នាក់ រហូតដល់ ៣០(សាមសិប)នាក់ ហេតុនេះបង្ហាញឲ្យឃើញថាការបង្កើតក្រុមហ៊ុនត្រូវធ្វើឡើងដោយមានការព្រមព្រៀងរវាងសមាជិកទាំងអស់ ដោយហេតុថាសមាជិកទាំងអស់ត្រូវប្រឈមមុខរាល់ហានីភ័យផ្នែកហិរញ្ញវត្ថុ និងផ្នែកព្រហ្មទណ្ឌក្នុងដំណើរការនៃការប្រកបអាជីវកម្មរបស់ក្រុមហ៊ុន។ ដូច្នេះការបង្កើតក្រុមហ៊ុននេះ ចាំបាច់ឲ្យសមាជិកភាគហ៊ុនទាំងអស់ត្រូវមានឆន្ទៈនៃការព្រមព្រៀង និងការប្តេជ្ញាចិត្តសហការគ្នាជារួម។

១.១.១.២ សមត្ថភាព

នៅក្នុងលក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតពុំមានចែងច្បាស់លាស់ពីសមត្ថភាពរបស់បុគ្គលដែលចង់ក្លាយជាសមាជិកហ៊ុនឡើយ មានន័យថាគ្រប់បុគ្គលទាំងអស់

មិនថានីតិជន ឬអនីតិជន។ ដូច្នេះមានន័យថាអនីតជនក៏អាចក្លាយជាសមាជិកក្រុមហ៊ុនបានដែរ ហើយលើសពីនេះទៅទៀត គ្មានករណីវិសមិតភាព និងការហាមឃាត់ឡើយ។

១.១.១.៣ កម្មវត្ថុ

ក្រុមហ៊ុនឯកជន ឬសហគ្រាស ទទួលខុសត្រូវមានកម្រិត អនុវត្តន៍នូវរាល់ពាណិជ្ជកិច្ចដោយ រលូន និងមិនបំពានច្បាប់ ក្រុមហ៊ុនត្រូវបញ្ចូលនូវកម្មវត្ថុដែលស្របទៅនឹងបទប្បញ្ញត្តិជាធរមាន ចូលទៅក្នុងលក្ខន្តិក:របស់ក្រុមហ៊ុន។ ចំពោះក្រុមហ៊ុនអភិវឌ្ឍលំនៅឋានមានសកម្មភាព ពាណិជ្ជកម្ម ឬវិនិយោគគ្រប់ប្រភេទដែលមានកម្មវត្ថុជាការសាងសង់លំនៅឋានសម្រាប់លក់ ដើម្បី រកប្រាក់ចំនេញ។ ហេតុនេះកម្មវត្ថុអាជីវកម្មនៃសកម្មភាពអាជីវកម្មក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវ បញ្ចូលទៅក្នុងលក្ខន្តិក:មានដូចខាងក្រោម៖

- **ការសាងសង់អាគារ**
  - អាគារលំនៅឋាន
  - អាគារមិនមែនលំនៅឋាន
- **សកម្មភាពអចលនទ្រព្យ ដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ**
  - ការទិញ ការលក់ ការជួល និងការធ្វើអាជីវកម្មចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ
  - ការអភិវឌ្ឍគម្រោងសាងសង់អាគារ សម្រាប់អាជីវកម្មផ្ទាល់ខ្លួន (ឧ. សម្រាប់ការ ដាក់ជួលផ្ទៃទំនេរនៅក្នុងអាគារ)
- **សកម្មភាពអចលនទ្រព្យ ដោយយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា**
  - សកម្មភាពរបស់ភ្នាក់ងារ ឬអន្តរការីអចលនទ្រព្យ
  - ការគ្រប់គ្រង់អចលនទ្រព្យដោយយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា
  - សេវាកម្មវាយតម្លៃអចលនទ្រព្យ
  - សកម្មភាពអចលទ្រព្យដោយយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យាដទៃទៀត ដែលពុំបានរាប់បញ្ចូល

កម្មវត្ថុខាងលើដកស្រង់ចេញសកម្មភាពអាជីវកម្ម និងសកម្មភាពអាជីវកម្មចម្បង ដែលបាន ដាក់អោយជ្រើសរើស ក្នុងពេលចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។ ជាទូទៅក្រុមហ៊ុនធ្វើ ប្រតិបត្តិការពាណិជ្ជកម្មដែលជាប់ទាក់ទងដោយចំពោះ ឬមិនចំពោះ ជាមួយកម្មវត្ថុខាងលើ ឬកម្ម វត្ថុប្រហាក់ប្រហែល ឬប្រទាក់គ្នា ឬដែលមានចរិកសំដៅអនុគ្រោះដល់កិច្ចអភិវឌ្ឍន៍រាល់ប្រតិបត្តិការ របស់ក្រុមហ៊ុន។

១.១.១.៤ ដើមទុន

ដើមទុននៃការចុះបញ្ជីក្រុមហ៊ុន គឺតំណាងឲ្យតម្លៃនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសំរាប់យកទៅ ធ្វើប្រតិបត្តិការណ៍ ឬសកម្មភាពពាណិជ្ជកម្មផ្សេងៗទៅតាមកម្មវត្ថុនៃក្រុមហ៊ុននោះ ហើយដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ [1] ចំពោះចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើ ប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឲ្យបោះដោយក្រុមហ៊ុននោះ[2]។ ម្យ៉ាងទៀតដើមទុនគឺអាចសំដៅដល់វត្ថុ អាចជាចលនវត្ថុ ឬជាអចលនទ្រព្យ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន។ ក្នុងនោះ អាចចាត់ទុកអចលនវត្ថុរបស់ក្រុមហ៊ុនទៅជាជាភាគហ៊ុនពេញសិទ្ធិ ឬជាភាគហ៊ុនអាស្រ័យផលលើឆន្ទៈរបស់ម្ចាស់ភាគហ៊ុននៅពេលចុះបញ្ជី។

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មិនមានកំណត់ដើមទុនជាអប្បបរមាទេ[3] ប៉ុន្តែសំរាប់ដើមទុននៃក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន ជាទូទៅសង្កេតឃើញថា ក្នុងការចុះបញ្ជីក្រុមហ៊ុនបានកំណត់យកដើមទុនចុះបញ្ជីអប្បបរមា ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល[4] ដោយបែងចែកជាចំណែកហ៊ុនមានតម្លៃស្មើៗគ្នាហើយយកប្រាក់ដើមទុនតម្គល់នៅគណនេយ្យធនាគារ។

ឧទាហរណ៍៖ ប្រសិនជាតម្លៃភាគហ៊ុនមានតម្លៃកំណត់ទុក ៤០.០០០ (បួនម៉ឺន) រៀលសម្រាប់មួយហ៊ុន និងមានចំនួន ៥០.០០០ (ប្រាំម៉ឺន)ភាគហ៊ុន ត្រូវបានកំណត់ចេញនោះគឺ ទុនដែលចុះបញ្ជីជាអប្បបរមា នឹងមានចំនួន ២.០០០.០០០.០០០រៀល។

១.១.២ លក្ខខណ្ឌបន្ថែមផ្សេងទៀត

ទោះបីច្បាប់ជាពុំបានចែងជាក់លាក់ថាក្រុមហ៊ុនត្រូវបំពេញនៅលក្ខខណ្ឌបន្ថែមលលក្ខខណ្ឌគ្រឹះដែលមានដូចជា ទ្រង់ទ្រាយ នាមករណ៍ ទីស្នាក់ការ និងថិរវេលា ក៏ដោយ ក៏លក្ខខណ្ឌទាំងអស់នេះបានក្លាយលក្ខខណ្ឌចាំបាច់ ដែលសំគាល់ពីលក្ខខណ្ឌ:នៃក្រុមហ៊ុនទៅតាមប្រភេទដែលមាននៅក្នុងច្បាប់។ រាល់ការស្នើសុំចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម តម្រូវឲ្យមានការបំពេញលក្ខខណ្ឌខាងលើ ដោយក្នុងលក្ខន្តិក:[5] ដែលច្បាប់បានកំណត់អោយក្រុមហ៊ុននីមួយៗត្រូវតែមាន។ យ៉ាងណាមិញចំពោះក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដើម្បីស្នើសុំចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មបាន ក្រុមហ៊ុនត្រូវធ្វើលក្ខន្តិក:ដែលមានបញ្ចូលនូវលក្ខខណ្ឌដូចមានដូចជា ទ្រង់ទ្រាយ (១.១.២.១) នាមករណ៍(១.១.២.២) ទីស្នាក់ការ (១.១.២.៣) និងថិរវេលា (១.១.២.៤)។

---

[1] មាត្រា ៩៣ ចំនុច ឃ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥

[2] មាត្រា ៩៣ ចំនុច ង នៃច្បាប់ដដែល

[3] កៅ មុយថង "ច្បាប់ពាណិជ្ជកម្ម" បោះពុម្ពនៅឆ្នាំ ២០១៥ ទំព័រ ២៣៥

[4] ប្រការ១០ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃ២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

[5] មាត្រា ៩៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥

១.១.២.១ ទ្រង់ទ្រាយ

មុននឹងចាប់ផ្តើមដំណើរការនីតិវិធីចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មបាន បុគ្គលដែលជាម្ចាស់ក្រុមហ៊ុនទាំងអស់ ត្រូវតែកំណត់ទ្រង់ទ្រាយរបស់ក្រុមហ៊ុន ហើយសមាជិកភាគហ៊ុនទាំងអស់ត្រូវយល់ដឹងពីប្រភេទក្រុមហ៊ុនដែលត្រូវបង្កើតស្របតាមលក្ខខណ្ឌកំណត់ដោយច្បាប់។ ផ្អែកតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រុមហ៊ុនមូលធន ត្រូវបានបែងចែកជាពីរគឺ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។ ចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានម្រិត ពុំអាចធ្វើពាណិជ្ជកិច្ចដែល ពាក់ព័ន្ធនឹងអាជីវកម្មធានាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនឥណទានបានឡើយ។ ដោយឡែកក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន បង្កើតឡើងក្នុងគោលបំណង ធ្វើអាជីវកម្មទៅលើការអភិវឌ្ឍលំនៅឋានប៉ុណ្ណោះ ដូច្នេះក្រុមហ៊ុនអភិវឌ្ឍលំនៅឋានជាប្រភេទក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុននេះត្រូវបានគ្រប់គ្រងជាចម្បងដោយច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និង ច្បាប់ស្តីពីវិសោធនកម្ម និងគ្រប់គ្រងដោយច្បាប់ដែលចូលជាធរមានជាច្រើនទៀត។ចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ច្បាប់តម្រូវអោយមានម្ចាស់ភាគហ៊ុនចាប់ពី ០២(ពីរ) រូប ដល់ ៣០ (សាមសិប)រូប ហើយក្នុងករណីមានម្ចាស់ភាគហ៊ុនតែមួយរូបនោះ គេនឹងអោយក្រុមហ៊ុននោះជាសហគ្រាសឯកជនទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនមិនអាចអនុញ្ញាតអោយលក់ភាគហ៊ុនឬមូលប័ត្រដទៃទៀតជាសាធារណៈបានឡើយ ប៉ុន្តែអាចអនុញ្ញាតអោយធ្វើអនុប្បទានទៅសមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន។

១.១.២.២ នាមករណ៍

ការបង្កើតក្រុមហ៊ុនឬសហគ្រាសអភិវឌ្ឍលំនៅឋាន មួយត្រូវយល់អំពីរបៀបចុះបញ្ជីឬការបំពេញបែបបទឯកសារឲ្យស្របតាមច្បាប់ ដើម្បីឲ្យក្រុមហ៊ុនមួយដំណើរការទៅមុខបាន ស្របគ្នានោះ ដែលក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវជ្រើសរើសឈ្មោះដាក់ឲ្យក្រុមហ៊ុនជាមុនសិន ដើម្បីចៀសវាងការដាក់ឈ្មោះជាន់គ្នា ឬស្រដៀងគ្នា ឬគេបានចុះបញ្ជីហើយ។ ក្នុងករណីប្រសិនបើមានឈ្មោះជាន់គ្នាជាមួយឈ្មោះដែលគេបានដាក់ហើយនោះ ឬអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ខាងក្រសួងពាណិជ្ជកម្មនឹងមិនអនុញ្ញាតនោះទេ នឹងតម្រូវឲ្យរកឈ្មោះសារជាថ្មី។ ជាគោលការណ៍ ក្រុមហ៊ុនទាំងអស់ត្រូវមាននាមករណ៍ផ្ទាល់ខ្លួន ដែលជារូបធាតុសម្រាប់សំគាល់ក្រុមហ៊ុនរបស់ខ្លួន។ ចំពោះនាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវ មានកម្រិតចាំបាច់ត្រូវដាក់នូវអក្សរថា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតឬ អក្សរកាត់ (ឯ.ក) ដើម្បីអាចអោយគេកត់សំគាស់បានថាជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលចាំបាច់ត្រូវដាក់នូវខាងចុង ឬខាងក្រោម ហើយនាមករណ៍

ត្រូវប្រើជាភាសាខ្មែរ។ ចំពោះករណីដែលមាននាមករណ៍ជាបរទេស យើងត្រូវដាក់នាមករណ៍ដែលជាអក្សរខ្មែរនៅខាងលើគេបង្អស់ ហើយត្រូវមានទំហំធំជាងគេបំផុតពីលើ នាមករណ៍បរទេស។ នាមករណ៍ជាភាសាបរទេសនោះត្រូវមានសូរស័ព្ទទៅ ពេះនឹងនាមករណ៍ជាភាសាខ្មែរដោយមិនអនុញ្ញាតអោយមានការបកប្រែជាដាច់ខាត[6]។

១.១.២.៣ ទីស្នាក់ការ

ផ្អែកតាមច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្មបានកំណត់អោយក្រុមហ៊ុនពាណិជ្ជកម្មបង្ហាញពីទីតាំងជាក់លាក់ ដែលក្រុមហ៊ុនរបស់ខ្លួនតាំងនៅព្រះរាជាណាចក្រកម្ពុជា។ ការកំណត់ដូចនេះគឺក្នុងគោលបំណងងាយស្រួលក្នុងការគ្រប់គ្រងតាមដាន និងធ្វើទំនាក់ទំនង។ ការបញ្ចូលទីតាំងទៅក្នុងលក្ខន្តិក:នៅពេលមានបំណងប្តូរទីតាំង ទាមទារអោយបុគ្គលជាម្ចាស់ក្រុមហ៊ុនស្នើសុំផ្លាស់ប្តូរ ឬកែប្រែនូវលក្ខន្តិក:របស់ខ្លួនផងដែរ។

បន្ថែមពីនេះទៅទៀត ក្រុមហ៊ុនក៏អាចកំណត់បានថាទីស្នាក់ការនឹងអាចត្រូវបានផ្ទេរទៅនៅកន្លែងផ្សេងតាមការសម្រេច ដោយសេចក្តីសម្រេចមហាសន្និបាតម្ចាស់ភាគហ៊ុន បន្ទាប់ពីមហាសន្និបាតម្ចាស់ភាគហ៊ុនបានចេញសេចក្តីសម្រេច ហើយត្រូវធ្វើការស្នើរទៅ មន្ត្រីមានសមត្ថកិច្ចនៅក្នុងក្រសួងពាណិជ្ជកម្មដើម្បីផ្តល់ជាដំណឹង និងសុំប្តូរទីតាំងក្រុមហ៊ុន។

១.១.២.៤ ថិរវេលា

ទោះបីជាច្បាប់មិនបានកំណត់ពីថិរវេលានៃអាយុជីវិតរបស់ក្រុមហ៊ុនក៏ដោយ យើងឃើញថាភាគច្រើននៃការចុះបញ្ជីពាណិជ្ជកម្ម គ្រប់ក្រុមហ៊ុនទាំងអស់ តែងស្នើសុំចុះបញ្ជីពាណិជ្ជកម្មដោយកំណត់រយ:ពេលនៃសកម្មភាពរបស់ក្រុមហ៊ុនមានចំនួន ៩៩ ឆ្នាំ ដែលត្រូវផ្តើមគិតចាប់ពីថ្ងៃបានចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម។

ជាទូទៅ ការស្នើសុំចុះបញ្ជីនៃក្រុមហ៊ុន មិនថាកម្មវត្ថុអាជីវកម្មមានរយ:ពេលវែង ឬខ្លីគឺសុទ្ធសឹងតែស្នើសុំរយ:ពេល ៩៩ ឆ្នាំ ព្រោះវាបានជួយសម្រួលដល់ដំណើរការ និងសន្សំពេលវេលា និងសោហ៊ុយចំណាយផ្សេងៗជាច្រើនក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្មសារជាថ្មី។

ដូច្នេះក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋានក៏ដូចជាក្រុមហ៊ុនពាណិជ្ជកម្មដទៃ ដែលថរិវេលាអតិបរិមាសម្រាប់កំណត់ជីវិតរបស់ក្រុមហ៊ុនពោលគឺ រយ:ពេល៩៩ឆ្នាំ។

១.១.៣ ការចុះហត្ថលេខាលើលក្ខន្តិក:

លក្ខន្តិក:ក្រុមហ៊ុន អាចត្រូវធ្វើឡើងក្នុងរូបភាពជាលិខិតរវាងឯកជន ឬលិខិតសាការី។គ្រប់ទំព័រនៃលក្ខន្តិក:របស់ក្រុមហ៊ុនត្រូវចុះហត្ថលេខា ឬហត្ថលេខាសង្ខេប ដោយសមាជិកទាំងអស់

[6] មាត្រា ៩២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥

របស់ក្រុមហ៊ុន។ ទោះបីជាតាមទម្រង់ណាមួយក៏ដោយ លក្ខន្តិក:ចំណុចផ្សេងទៀតបានដោយយោងទៅតាមភាពចាំបាច់របស់ក្រុមហ៊ុន។ ក្នុងនោះលក្ខន្តិក:របស់ក្រុមហ៊ុន ត្រូវតែបញ្ចូលនូវលក្ខខណ្ឌសំខាន់ៗមួយចំនួនជាអាទ៍ៃ

- នាមករណ៍របស់ក្រុមហ៊ុន
- ទីស្នាក់ចុះបញ្ជីរបស់ក្រុមហ៊ុន នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន នឹងកំណត់នូវអាជីវកម្មដែលក្រុមហ៊ុនអាចមួយ ឬច្រើនប្រភេទដែលមិនផ្ទុយនឹងបញ្ញត្តិណាមួយនៃច្បាប់
- ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ
- ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឲ្យបោះចេញដោយក្រុមហ៊ុននោះ។
- ក្នុងករណីក្រុមហ៊ុន ត្រូវបានអនុញ្ញាតឲ្យបោះប័ណ្ណភាគហ៊ុន លើសពីមួយប្រភេទ ហ៊ុននោះលក្ខន្តិក:របស់ក្រុមហ៊ុនត្រូវចែងចំនួនអតិបរមា និង តម្លៃចារឹកលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹង ប្រភេទនីមួយៗ នៃប័ណ្ណភាគហ៊ុន។
- ក្នុងករណីប្រភេទភាគហ៊ុន ត្រូវបោះជាស៊ីរី លក្ខន្តិក:ក្រុមហ៊ុននោះ ត្រូវអនុញ្ញាតឲ្យអភិបាលកំណត់ចំនួនភាគហ៊ុននៃស៊ីរីនីមួយ ដើម្បីកំណត់ប្លង់បែងចែងស៊ីរីនីមួយ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌ ដែលភ្ជាប់ទៅនិងស៊ីរីនីមួយៗនោះ។
- ក្នុងករណីការបោះផ្សាយចេញជាការផ្ទេរ ឬ ការកាន់កាប់ប័ណ្ណភាគហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធភាព និងរបាយការណ៍ពីការកម្រិតនោះ។
- ឈ្មោះនិង អាស័យដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ។
- ចំនួនអភិបាល ឬ ចំនួនអប្បរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ។

ក្រៅពីនេះលក្ខន្តិក:របស់ក្រុមហ៊ុនក៏ត្រូវពិចារណាទៅលើការកំណត់នៅក្នុងនោះផងដែរ ដូចជាការចែងឲ្យមានប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ដោយមានបញ្ជាក់ពីលក្ខណ:ដាច់ខាត ឬលក្ខណ:ប្រៀបធៀប។

លក្ខន្តិក: ត្រូវតែមានការចុះហត្ថលេខាដោយសមាជិកភាគហ៊ុនទាំងអស់។ ទម្រង់ការនេះអាចឲ្យក្រុមហ៊ុនមិនចាំបាច់រៀបចំមហាសន្និបាតក្រុមហ៊ុន ដោយសារស្ថាបនិក មានដើមទុនគ្រប់គ្រាន់ក្នុងការជាវភាគហ៊ុនដោយខ្លួនឯង។ ចាប់ពីពេលដែលមានការចុះហត្ថលេខានេះតទៅ បានបញ្ជាក់ពីការ

ជាប់ជំពាក់ជំពិនរបស់អ្នកជាវភាគហ៊ុនជាមួយក្រុមហ៊ុន។ វាក៏បញ្ជាក់ផងដែរ ពីការទទួលស្គាល់គ្នាទៅវិញទៅមក និងការវាយតម្លៃលើភាគទុនជាវត្ថុ។ ហើយចាប់ពីពេលដែលមានការចុះហត្ថលេខានេះ ម្ចាស់ភាគហ៊ុនត្រូវទទួលស្គាល់ និងទទួលខុសត្រូវនៅក្នុងក្រុមហ៊ុន គឺកម្រិតត្រឹមតែតម្លៃភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗប៉ុណ្ណោះ ដែលការទទួលខុសត្រូវនេះកើតឡើងចាប់ពីពេលដែលក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈដោយកាលបរិច្ឆេទដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

តាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានកំណត់ពី ការទទួលខុសត្រូវម្ចាស់ហ៊ុនចំពោះបំណុលនៅក្នុងក្រុមហ៊ុនគឺមានកម្រិតត្រឹមតែលើតម្លៃជាវភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗប៉ុណ្ណោះ។ ចំពោះលក្ខន្តិកៈរបស់ក្រុមហ៊ុន គេអាចធ្វើការកែសម្រួលបានគ្រប់ពេលវេលាទាំងអស់ទោះបីជាក្រុមហ៊ុនបានបង្កើតឡើងរួចហើយក៏ដោយ។

១.២ ការចុះបញ្ជីក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

ដើម្បីឲ្យក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ទទួលបានបុគ្គលិតយុត្តនោះ មិនត្រឹមតែតម្រូវឲ្យបំពេញលក្ខខណ្ឌគ្រឹះប៉ុណ្ណោះទេ គឺថែមទាំងត្រូវបំពេញលក្ខខណ្ឌនៃការចុះបញ្ជីទៀតផង។ ក្រុម-ហ៊ុនត្រូវធ្វើការចុះបញ្ជីដូចជា ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម(១.២.១) និងការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ (១.២.២)។

១.២.១ ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

រាល់ក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយដែលមានទីតាំងនៅ ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមានកាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្ម។ នៅក្នុងពេលបច្ចុប្បន្នការចុះបញ្ជីត្រូវបានធ្វើតាមប្រព័ន្ធស្វ័យ-ប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម។ ការចុះបញ្ជីអាចធ្វើបានគ្រប់ទីន្លែង តាមរយៈគេហទំព័រ www.businessregistration.moc.gov.kh [7] ។

ព័ត៌មានស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ដែលបានបំពេញដោយអភិបាល និងឯកសារតម្រូវសម្រាប់តម្កល់នៅក្រសួងពាណិជ្ជកម្ម ត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម ជាទម្រង់អេឡិចត្រូនិក[8]។ ក្នុងករណី អភិបាល ដែលមិនអាចបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មដោយខ្លួនឯងបាន អាចមកក្រសួងពាណិជ្ជកម្មដើម្បីស្នើឲ្យមន្ត្រីចុះបញ្ជីបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស ចំពោះការទូទាត់កម្រៃសេវាត្រូវធ្វើដោយផ្ទាល់នៅ បញ្ជរបងប្រាក់កម្រៃសេវាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

[7] ប្រការ១ នៃប្រកាសលេខ ២១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
[8] ប្រការ២ នៃប្រកាសដដែល

១.២.១.១ ឯកសារតម្រូវសំរាប់ចុះបញ្ជីពាណិជ្ជកម្ម

ការចុះបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវរៀបចំឯកសារមួយចំនួន ដែលសម្រាប់ដាក់បញ្ចូលក្នុងពេលដំណើរការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដែលមានដូចជា៖

- ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជា វិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក កិច្ចសន្យាជួលផ្ទះឬអាគារ លិខិតប្រៃសណីយ៍ជាដើម
- លក្ខន្តិក:ក្រុមហ៊ុន
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ហ៊ុន និងអភិបាល
- រូបថត ៤x៦
- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អភិបាល ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហ-លក្ខន្តិក:មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ករណីម្ចាស់ហ៊ុនជានិតិបុគ្គលនោះត្រូវបំពេញបន្ថែមនូវឯកសារ៖
  - ច្បាប់ចម្លងកសារគតិយុត្តិនៃ ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
  - សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាម្ចាស់ក្រុមហ៊ុន[9]។

១.២.១.២ របៀបនៃការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

ការណែនាំពីរបៀប នៃការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយយោងតាមឯកសារវីដេអូដែលផលិតដោយក្រសួងពាណិជ្ជកម្មដែលមានឈ្មោះថា វិធីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្ត-កម្មចុះបញ្ជីពាណិជ្ជកម្ម (វីដេអូកំណែ១.៤.២)[10]។ ចំពោះការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្ម តម្រូវឲ្យមានកំព្យូទ័រ ឧបករណ៍ដែលអាចប្រើប្រាស់ភ្ជាប់ជាមួយប្រព័ន្ធអ៊ីនធើណេតបានដើម្បីដំណើរប្រតិបត្តិការណ៍ចុះបញ្ជី។ របៀបចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តកម្មមានបួនដំណាក់កាល ដូចជាបង្កើតគណនីប្រើប្រាស់ប្រព័ន្ធ(ក) ត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍(ខ) ចុះបញ្ជីពាណិជ្ជកម្ម(គ) និងកែប្រែព័ត៌មានក្រុមហ៊ុន និងបោះពុម្ពវិញ្ញាបនបត្រ(ឆ)។

---

[9] ប្រការ៣ នៃប្រកាសលេខ២១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

[10]Youtube គណនី Ministry of Commerce, Cambodia www.youtube.com/watch?v=N7nrp9cvzdY ពិគ្រោះនៃថ្ងៃ ១២ ខែ មិថុនា ឆ្នាំ ២០១៧

ក. ការបង្កើតគណនីប្រើប្រាស់ប្រព័ន្ធ

ដើម្បីអាចប្រើប្រាស់ប្រព័ន្ធចុះបញ្ជីស្វ័យប្រវត្តិកម្មបាន តម្រូវអោយមានគណនី និងលេខសង្កាត់ដើម្បីបើកគណនីជាមុនសិន។ ចំពោះការបង្កើតគណនីប្រើប្រាស់ប្រព័ន្ធ គឺត្រូវបានបែងចែកជា៥ជំហាន ក្នុងការបង្កើតគណនីនេះបានមានដូចខាងក្រោម៖

ជំហានទី១៖ ត្រូវចូលទៅកាន់គេហទំព័រ www.businessregistration.moc.gov.kh

ជំហានទី២៖ ស្វែងរក និងចុចលើពាក្យ ***ចុះឈ្មោះ (Register)*** ដែលមានបង្ហាញខាងស្តាំនៃផ្ទាំងគេហទំព័រ

ជំហានទី៣៖ បន្ទាប់ពីចូលក្នុងប្រព័ន្ធហើយ អ្នកតម្រូវអោយបំពេញ ឈ្មោះប្រើប្រាស់សំរាប់ប្រើគណនី លេខសង្កាត់ ចំនួនពីរដង

ជំហានទី៤៖ បន្ទាប់មកធ្វើការបំពេញព័ត៌មានដែលទាក់ទងនឹងអ្នកប្រើគណនី មានដូចជា ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកណើត ភាសា ជាអាទ៍និងព័ត៌មានដែលសំរាប់ធ្វើការទំនាក់ទំនង ដែលមានដូចជា អ៊ីម៉ែល លេខទូរស័ព្ទ និងអាស័យដ្ឋាន

សំគាល់៖ សំរាប់កន្លែងដែលមានសញ្ញាផ្កាយពណ៌ក្រហមជាពត៌មានចាំបាច់ត្រូវបំពេញ។

ជំហានទី៥៖ អ្នកត្រូវចុចលើប៊ូតុងដែលពាក្យ ***បង្កើត(Create)*** បន្ទាប់ពីអ្នកបង្កើតគណនីបានជោគជ័យ នោះនឹងបង្ហាញទំព័រមុខងារដោយស្វ័យប្រវត្តិ។

ការប្រើប្រាស់គណនីដែលមានបង្កើតហើយដើម្បីចូលទៅកាន់ប្រព័ន្ធ អ្នកត្រូវចុចលើពាក្យ ***ចូលប្រព័ន្ធ*** (***Lo gon***) ដែលមានបង្ហាញលើទំព័រមុខងារដោយស្វ័យប្រវត្តិបន្ទាប់មកធ្វើការវាយបញ្ចូលឈ្មោះគណនី និងលេខសំងាត់ និងចុចប៊ូតុង ***ចូលប្រព័ន្ធ(Lo gon)*** ម្តងទៀត។

ខ. ការត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍

ដើម្បីត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍លើផ្ទាំងមុខងារប្រព័ន្ធគណនីរបស់អ្នក។

ជំហានទី១៖ អ្នកត្រូវចុចលើពាក្យ បម្រុងទុកនាមករណ៍ក្រុមហ៊ុន (*Reserve a Company Name*)

ជំហានទី២៖ ជ្រើសរើសប្រភេទក្រុមហ៊ុន ដោយចុចទៅពាក្យ ***សូមមេត្តាជ្រើសរើស (Please select)*** បន្ទាប់មកនឹងមានការបង្ហាញនូវប្រភេទក្រុមហ៊ុនដែលលោកអ្នកចង់បង្កើត ដែលមានដូចជា ក្រុមហ៊ុនឯកជន ក្រុមហ៊ុនមហាជន ក្រុមហ៊ុនបរទេស ។

ឧទាហរណ៍៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

បំពេញឈ្មោះក្រុមហ៊ុនដែលលោកចង់ដាក់នោះប្រព័ន្ធនឹងផ្តល់ពិនិត្យនាមករណ៍ ជាភាសាខ្មែរ និងភាសាអង់គ្លេសក្នុងពេលតែមួយតែម្តង

សំគាល់៖សំរាប់នាមករណ៍ជាភាសាអង់គ្លេសត្រូវប្រាកដថាបានបញ្ចប់ដោយពាក្យ "*Co., Ltd. or PLC*" ដែលបញ្ជាក់ពីទ្រុងទ្រាយក្រុមហ៊ុន។

ជំហានទី៣៖ បន្ទាប់មកត្រូវចុចទៅលើពាក្យ ***សុពលភាពនាមករណ៍ (Validate Name)*** បន្ទាប់ប្រសិនជានាមករណ៍ទំនេរអាចប្រើប្រាស់បាននោះ នឹងបង្ហាញពាក្យ សុពលភាពនាមករណ៍ ប្រសិនឈ្មោះដែលលោកអ្នកដាក់ស្នើមានសុពលភាព នោះនឹងមានបង្ហាញអក្សរពណ៌ខៀវ ***នាមករណ៍ស្នើសុំ (ជាភាសាខ្មែរ)/(ជាភាសាអង់គ្លេស)*** មានសុពលភាព ***(Proposed Name (In Khmer)/(In English) is Valid)*** នោះអ្នកអាចចុចលើពាក្យ ***ដាក់ស្នើ (Summit)*** ដើម្បីធ្វើការត្រួតពិនិត្យ និងសម្រេច

ជំហានទី៤៖អ្នកត្រូវបង់កម្រៃសេវាសំរាប់ការបម្រុងទុកនាមករណ៍ ដែលអាចធ្វើការទូរទាត់តាមរយៈធនាគារ អេស៊ីលីដា ឬកាណាឌីយ៉ា ហើយនៅពេលអនាគតអាចទូរទាត់ជាមួយធនាគារពាណិជ្ជផ្សេងទៀត។ ចំពោះកម្រៃសំរាប់បម្រុងទុកនាមករណ៍ចំនួន ៤០០.០០០ (សែសិបម៉ឺន)រៀល

សំគាល់៖ តម្លៃដែលត្រូវបង់ជាតម្លៃសាធារណៈដែលមានក្នុងប្រកាសរួមរវាងក្រសួងពាណិជ្ជកម្មនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជំហានទី៥៖ នៅផ្ទាំង ***កម្រៃសេវា (Fee Payment)*** ស្វែងរកពាក្យ ***បែបបទបង់ប្រាក់ (Payment Method)*** បន្ទាប់ចុចលើប្រអប់ដែលនៅជាប់ មានពាក្យ ***សូមជ្រើសរើស (Please Select)*** ដើម្បីលោកអ្នកអាចជ្រើសរើសធនាគារ បន្ទាប់មកចុចប៊ូតុង ***បន្ត (Continue)*** ហើយប៊ូតុង ***យល់ព្រម (OK)***

ជំហានទី៦៖ បន្ទាប់មកនឹងចូលទៅកាន់ប្រព័ន្ធទូរទាត់ប្រាក់របស់ធនាគារ បន្ទាប់មកធ្វើការបង់ប្រាក់តាមប្រភេទដែលធនាគារបានបង្ហាញ ដែលមានដូចជាការទូទាត់ តាមលេខគណនីធនាគា ឬតាមកាត ATM ឬទូរATM ផ្សេងៗទៀតដែល

ឧទាណហ៍៖ ធ្វើការជ្រើសរើសទូរទាត់តាមលេខគណនីធនាគា ដែលជាជំរើសទី១ បន្ទាប់មកចុចលើពាក្យ ***ភ្ជាប់*** (***Proceed***) ហើយធ្វើការវាយលេខគណនីធនាគា នឹងជ្រើសរើសបញ្ជាក់លេខគណនីនោះម្តងទៀត បន្ទាប់មកចុចប៊ូតុង ***បន្ទាប់*** (***Next***) ហើយ ប៊ូតុង ***Request out of band OTP*** ដើម្បីទទួលបានលេខសំងាត់លើទូរស័ព្ទដៃ ដែលភ្ជាប់ជាមួយគណនីធនាគានោះធ្វើការវាយបញ្ចូលលេខសំងាត់ ៦ខ្ទង់ដែលទទួលបាន ក្នុងប្រអប់ ***OTP*** ហើយចុចប៊ូរតុង ***Verify*** បន្ទាប់មកចុចប៊ូតុង ***OK*** នោះនឹងបង្ហាញបញ្ជាក់ពីការទូរទាត់នោះជោគជ័យ បន្ទាប់ចុចលើពាក្យ ***Back to merchant*** ដើម្បីត្រលប់ទៅកាន់ប្រព័ន្ធស្វ័យប្រវត្តកម្មចុះបញ្ជីវិញ។

ជំហានទី៧៖ បន្ទាប់ពីធ្វើការទូទាត់រួចលោកអ្នកអាចទទួលបានបង្កាន់ដៃ ដោយចុចលើប៊ូតុង ***ទីនេះ (Here)*** បង្កាន់ដៃនោះនឹងត្រូវបានផ្ញើរទៅកាន់អ៊ីម៉ែលលោកអ្នកផងដែរ។ បន្ទប់មកលោកអ្នកចុចប៊ូតុង ***យល់ព្រម (OK)*** ដើម្បីបញ្ចប់ប្រតិបត្តិការណ៍ នោះលោកអ្នកនឹងនាំមកមុខងារដោយស្វ័យប្រវត្ត

បន្ទាប់នឹងទទួលបានសារអេឡិតត្រូនិកមួយទៀតពីក្រសួងពាណិជ្ជកម្ម ហើយក៏អាចមើលផ្ទាំងមុខក្នុងប្រអប់ ***ការងារដែលខ្ញុំមិនទាន់បានបញ្ចប់ (My Unfinished Business)*** ដើម្បីបញ្ជាក់ថាការស្នើសុំបម្រុងទុកនាមករណ៍បានផ្ញើរទៅកាន់មន្ត្រីក្រសួងពាណិជ្ជកម្មបានជោគជ័យ។

សំគាល់៖ បង្ហាន់ដៃនេះបញ្ជាក់ពីចំនួនទឹកប្រាក់ដែលបានបង់ទៅក្រសួងពាណិជ្ជកម្ម និងចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយអាចការព្រឿនចេញឬរក្សាទុកជាអំណះអំណាង។

ក្រោយពីក្រសួងពាណិជ្ជកម្មពិនិត្យ និងឯកភាព លើសំណើរបម្រុងទុកនាមករណ៍ហើយ នោះនឹងទទួលបានសារអេឡិចត្រូនិកមួយ ហើយក៏អាចមើលឃើញនៅលើទំព័រមុខងារនៃប្រព័ន្ធស្វ័យប្រវត្តកម្ម នូវឈ្មោះអាជីវកម្មដែលបានបម្រុងទុកនោះក្នុង ***តំបន់ (My Items)*** នោះនាមករណ៍អាជីវកម្មនឹងត្រូវបានរក្សាទុក ដោយមិនអនុញ្ញាតអោយអ្នកប្រើប្រាស់ដទៃទៀត ធ្វើការស្នើសុំ ប្រើនាមករណ៍ ដែលដូច ឬស្រដៀងនឹងនាមករណ៍នេះបានឡើយក្នុងរយៈពេល ៣ខែ។

គ. ការចុះបញ្ជីពាណិជ្ជកម្ម

សំរាប់ការចុះបញ្ជីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតថ្មីមួយ។ ត្រូវចុចលើពាក្យ ***ចុះបញ្ជីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត*** (***Incorporate a private Limited Company***) ដែលនៅខាងឆ្វេងនៃផ្ទាំងមុខងារ។

ជំហានទី១៖ អំពីព័ត៌មានលម្អិត

ក្នុងករណីមានបម្រុងទុកនាមករណ៍ជាមុននោះ គួសសញ្ញាគ្រីសក្នុងប្រអប់ ខាងមុខពាក្យ ***ជ្រើសរើសនាមករណ៍បម្រុងទុក?*** (***Select a Reserved Name?***) ដើម្បីទាញយកនាមករណ៍ដែលបានបម្រុងទុកមកប្រើប្រាស់តែម្តង។

ក្នុងករណីប្រសិនជាមិនទាន់បានត្រួតពិនិត្យ ឬបម្រុងទុកនាមករណ៍ជាមុនទេនោះអាចធ្វើវាក្នុងពេលតែមួយ ជាមួយការបំពេញបែបបទចុះបញ្ជីពាណិជ្ជកម្មដោយបំពេញក្នុងប្រអប់ ***ឈ្មោះដែលបានស្នើ(ជាភាសាខ្មែរ) និង ឈ្មោះដែលបានស្នើ(ជាភាសាអង់គ្លេស)*** (***Proposed name (in Khmer) and Proposed name (in English)***) ។

បញ្ចូលអនុស្សាន:ឬលក្ខន្តិក:ក្រុមហ៊ុន ដោយចុចប៊ូតុង ***បញ្ចូល*** (***Upload***), ធ្វើការជ្រើសរើសកម្មវត្ថុអាជីវកម្មចម្បងមួយឬច្រើនដែលដូចមានចែងក្នុងលក្ខន្តិក:ក្រុមហ៊ុនបញ្ចូលតម្លៃចារឹកលើប័ណ្ណនៃភាគហ៊ុនដែលបានកំណត់ក្នុងលក្ខន្តិក:។ ប្រសិនជាមានព័ត៌មានអំពីបុគ្គលិកនៅក្នុងក្រុមហ៊ុន ត្រូវបញ្ចូលចំនួនបុគ្គលិក និងឯកសារបញ្ជាក់ពីតួនាទីរបស់ពួកគេ។

ជំហានទី២៖ អំពីអាស័យដ្ឋាន

បំពេញព័ត៌មានអាស័យដ្ឋានក្រុមហ៊ុន បញ្ចូលឯកសារបញ្ជាក់អាស័យដ្ឋានក្រុមហ៊ុន ដោយចុច ***បញ្ចូល*** (***Upload***)

បន្ទាប់បំពេញអាស័យដ្ឋានទីស្នាក់ការចុះបញ្ជី ដែលមានដូចជា អ៊ីម៉ែល និងលេខទូរស័ព្ទ ។

ជំហានទី៣៖ អំពីអភិបាល

ជាការបំពេញព័ត៌មានអភិបាលក្រុមហ៊ុន លោកអ្នកបំពេញតាមប្រអប់នៃផ្ទាំងមុខបានបង្ហាញ ឬក៏ចុច ***បន្ថែមខ្ញុំជាអភិបាល (Add Me as Director)*** ប្រសិនបើម្ចាស់គណនីប្រព័ន្ធស្វ័យប្រវត្តកម្មជាអភិបាលក្រុមហ៊ុន

បន្ទាប់មកជ្រើសរើសឯកសារបញ្ជាក់ អត្តសញ្ញាណដែលអាចជា អត្តសញ្ញាណប្លាស្ទិចឆ្លងដែន រួចបំពេញព័ត៌មាន និងបញ្ចូលឯកសារយោង ហើយគូសសញ្ញាគ្រីស លើពាក្យ ***ប្រធានក្រុមប្រឹក្សាភិបាល*** (***Chairman***) ប្រសិនអភិបាលតែមួយរូបឬជាប្រធានក្រុមប្រឹក្សាភិបាល

បន្ទាប់មកគូសសញ្ញាគ្រីសក្នុងប្រអប់ ពីក្រោមពាក្យ ***Consent*** ដើម្បីប្រកាសថាមិនមានជាប់ទោសពៃណរ៍ ឬជាមន្ត្រីរាជការក្នុងស្ថាប័ន្តរដ្ឋណាមួយហើយពត៌មានដែលបានបំពេញផ្តល់ពិតជាត្រឹមត្រូវពិតប្រាកដមែន ហើយធ្វើការ ***Upload*** ឯកសារយោង[11]។

ក្នុងករណីដែលដែលក្រុមមានច្រើនជាងមួយរូប ត្រូវចុច លើពាក្យ ***បន្ថែមអភិបាល*** (***Add another Director***) ។

ជំហានទី៤៖ ជាការបំពេញពត៌មាន ភាគហ៊ុន និងម្ចាស់ហ៊ុន

ករណីដែលក្រុមហ៊ុនមានប្រភេទភាគហ៊ុនច្រើនជាងមួយ ត្រូវចុចពាក្យ ***បាទ/ចាស***(***Yes***) រួចបញ្ចូលព័ត៌មានពីប្រភេទភាគហ៊ុនទាំងនោះ។

ជ្រើសរើសប្រភេទម្ចាស់ភាគហ៊ុនដែលអាចជា រូបវន្តបុគ្គល ឬនីតិបុគ្គល រួចធ្វើបំពេញព័ត៌មានពីម្ចាស់ហ៊ុនទាំងនោះ ចុចទៅលើ ***ជ្រើសរើសអភិបាល Select from list of directors*** ប្រសិនបើ សមាសភាពភាគហ៊ុនដូចទៅនឹង សមាសភាពក្រុមប្រឹក្សា ឬចុចពាក្យ ***បន្ថែមខ្ញុំជាម្ចាស់ហ៊ុន*** (***Add Me as Shareholder***)

ប្រសិនបើម្ចាស់គណនីនៃប្រព័ន្ធស្វ័យប្រវត្តកម្មគឺជាម្ចាស់ភាគហ៊ុន បញ្ចូលពត៌មាននិងឯកសារបញ្ជាក់អត្តសញ្ញាណ និងចំនួនភាគហ៊ុនដែលម្ចាស់ភាគហ៊ុនរូបនេះកាន់កាប់ ចុចប៊ូតុង ***បន្ថែមខ្ញុំជាម្ចាស់ហ៊ុន (Add Another shareholder)*** ប្រសិនជាមានម្ចាស់ភាគហ៊ុនផ្សេងទៀត។

ជំហានទី៥៖ ពិនិត្យឡើងវិញ

[11] មានទំរង់គំរូនៅក្នុងឧបសម្ព័ន្ធ (ចុះបញ្ជីពាណិជ្ជកម្ម)

ពិនិត្យព័ត៌មានដែលបានបញ្ចូលក្នុងជំហានទាំងបួនខាងលើ។ ប្រសិនជាពិនិត្យទៅមានកំហុសឆ្គង ឬខ្វះខាតព័ត៌មានក្នុងជំហានណាមួយ ត្រូវចុចប៊ូតុង ***កែសម្រួល*** (***Edit***) ឬចុច តាមលេខរៀងនៃជំហាននីមួយៗខាងលើ។ បន្ទាប់មកចុច ***រក្សាទុក និងចាកចេញ*** (***Save and Exit***) ប្រសិនបើមានចំនុចណាមួយដែលត្រូវធ្វើការពិចារណា ហើយប្រព័ន្ធនឹងធ្វើការរក្សាទុកព័ត៌មានដែលបានស្នើសុំនេះក្នុងអំឡុងពេល ១៥ថ្ងៃ។

ចុចប៊ូតុង ***ដាក់ស្នើ*** (***Summit***) ដើម្បីបន្តទៅធ្វើការទូរទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្មដូចជាការទូរទាត់សំរាប់ការបម្រុងទុកនាមករណ៍ក្រុមហ៊ុនដែល។ កម្រៃសំរាប់ការចុះបញ្ជីក្រុមហ៊ុនចំនួន ១.៦៨០.០០០ (មួយលាន ប្រាំមួយសែន ប្រាំបីម៉ឺន) រៀល។

ឃ. ការកែប្រែព័ត៌មានក្រុមហ៊ុន និងបោះពុម្ពវិញ្ញាបនបត្រ

បន្ទាប់ពីការទទួលប្រាក់បានជោគជ័យ និងមន្ត្រីក្រសួងពាណិជ្ជកម្មក៏បានត្រួតពិនិត្យ និងឯកភាពសំណើសូមចុះឈ្មោះក្រុមហ៊ុនរួចរាល់។

ដោយនៅលើផ្ទាំងមុខងារមានបង្ហាញឈ្មោះក្រុមហ៊ុន ដោយធ្វើការចុចលើឈ្មោះក្រុមហ៊ុននោះ ដើម្បីចូលទៅកាន់ព័ត៌មានលំអិតទាំងអស់របស់ក្រុមហ៊ុន ហើយអ្នកអាចធ្វើការសុំកែរាល់ពត៌មានលំអិតទាំងនោះដោយចុចទៅប៊ូតុងដែលខាងស្តាំង រាល់ការស្នើសុំកែប្រែតម្រូវអោយបង់តម្រៃសេវាដែលដូចមាននៅក្នុងប្រកាសអន្តរក្រសួង ក្រោយការទូរទាត់ សំណើនោះនឹងត្រូវបញ្ជូនទៅកាន់ក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យនឹងសំរេច។

ចំពោះការទាញយក និងបោះពុម្ពវិញ្ញាបនបត្រ សូមចុចលើប៊ូតុង ***ស្នើសុំដកស្រង់ឬវិញ្ញាបនបត្រ*** (***Request Extract or Certificate)*** បន្ទាប់មក ជ្រើសរើស ប្រភេទ ***(វិញ្ញាបនបត្រ ឬ សម្រង់អាជីវកម្ម)***, វិធីសាស្ត្រចែកចាយ (***អាចបង្ហាញជា PDF ឬ អ៊ីម៉ែលជា PDF)*** បន្ទាប់មកចុចពាក្យ ***ដាក់ពាក្យ (Summit)*** លោកអ្នកនឹងអាចទទួលបានវិញ្ញាបនបត្រឬសម្រង់អាជីវកម្ម ហើយប្រព័ន្ធស្វ័យប្រវត្តិកម្មថ្មីនេះអនុញ្ញាតអោយលោកអ្នកធ្វើការបោះពុម្ព វិញ្ញាបនបត្រដោយខ្លួនឯង។

ការដាក់ស្នើនឹងត្រូវបានដំណើរការដោយស្វ័យប្រវត្តនៅក្នុងម៉ោងធ្វើការធម្មតា (០៧:00-១១:00 និង១៤:00-១៧:00)។ អ្នកនឹងទទួលបានអ៊ីម៉ែលដោយស្វ័យប្រវត្តបញ្ជាក់ថាអ្នកបានបញ្ចប់ទម្រង់ពាក្យសុំរបស់អ្នកយ៉ាងជោគជ័យ បន្ទាប់ពីអ្នកបានបញ្ចប់ការចុះបញ្ជីរបស់អ្នកដោយជោគជ័យ។ ពាក្យសុំដែលបានដាក់ជូននៅក្រៅម៉ោងធ្វើការត្រូវបានដាក់ក្នុងជួរអាទិភាព ហើយបានដំណើរការនៅដើមថ្ងៃធ្វើការបន្ទាប់។

១.២.២. ការចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ

ការចុះបញ្ជីរបស់អ្នកជាប់ពន្ធទាំងឡាយដែលធ្វើសកម្មភាពសេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះសកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រាដើម្បីរក ឬមិនរកចំណេញក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឲ្យ ដល់បុគ្គលដទៃក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។ គោលបំណងនៃការចុះបញ្ជីពន្ធដារដើម្បីគ្រប់គ្រងឲ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យរបស់អ្នកជាប់ពន្ធ គាំទ្រដល់ការផ្តល់សេវាដល់អ្នកជាក់ពន្ធឲ្យបានកាន់តែល្អប្រសើរ គ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធឲ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។ រាល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលពី ការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួលឬការលក់ទ្រព្យសម្បត្តិ លក់លំនៅឋាន ឬសកម្មភាពផ្សេងទៀត ត្រូវមានកាតព្វកិច្ចបង់ពន្ធ។ ហេតុនេះសំរាប់ក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅ ត្រូវតែបំពេញកាតព្វកិច្ចចុះពន្ធដារ ដែលមានលក្ខខណ្ឌដូចជា កាតព្វកិច្ចនៃការចុះបញ្ជីពន្ធដារ (១.២.២.១) ការស្នើសុំការចុះបញ្ជីពន្ធដារ(១.២.២.២) ឯកសារនិងការតម្រូវសម្រាប់ការចុះបញ្ជីពន្ធដារ (១.២.២.៣) កម្រៃសេវាចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធ (១.២.២.៤) រយៈពេលពេលទទួលបានការចុះបញ្ជីពន្ធដារ(១.២.២.៥)។

១.២.២.១ កាតព្វកិច្ចនៃការចុះបញ្ជីពន្ធដារ

ក្រុមហ៊ុនដែលទើបបង្កើតថ្មីៗទាំងអស់តម្រូវឲ្យ ចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីក្រុមហ៊ុននោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ[12]។

១.២.២.២ ការស្នើសុំចុះបញ្ជីពន្ធដារ

ចំពោះកាតព្វកិច្ចចុះបញ្ជីពន្ធដារ ត្រូវធ្វើការស្នើសុំចុះបញ្ជី ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដោយត្រូវបំពេញទម្រង់ ១០១[13] ឲ្យបានត្រឹមត្រូវតាមរយៈសេចក្ដីណែនាំ លេខ២៤៣៩ ស្ដីពី ការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសតាមរបបស្វ័យប្រកាស (ទម្រង់១០១) ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងតម្រូវឲ្យភ្ជាប់មកជាមួយនូវឯកសារ[14]។

---

[12] ប្រការ៥ នៃប្រកាសលេខ ៤៩៦ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៦ ស្ដីពី ការចុះបញ្ជីពន្ធដារ

[13] មានភ្ជាប់គំរូ ទម្រង់ ១០១ នៅឧបសម្ព័ន្ធ

[14] ប្រការ៦ នៃប្រកាសលេខ ៤៩៦ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៦ ស្ដីពី ការចុះបញ្ជីពន្ធដារ

១.២.២.៣ ឯកសារ និងការតម្រូវសម្រាប់ការចុះបញ្ជីពន្ធដារ

ប្រធានក្រុមប្រឹក្សាភិបាល តម្រូវឲ្យមក ថតរូប ស្នែនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។ ករណីប្រធានក្រុមប្រឹក្សាភិបាល ដែលមានសញ្ជាតិបរទេស ហើយស្នាក់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមិនអាចអញ្ជើញមកថតរូប ស្នែនម្រាមដៃ ត្រូវធ្វើលិខិតផ្ទេរសិទ្ធិឲ្យតំណាងណាមួយក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ មកថតរូបនិងស្នែនម្រាមដៃជំនួសបាន និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវប័ណ្ណពន្ធប៉ាតង់ ឬ/និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។ ចំពោះករណីប្រធានក្រុមប្រឹក្សាភិបាល ដែលមានសញ្ជាតិបរទេស តែរស់នៅព្រះរាជាណាចក្រកម្ពុជា ឬប្រធានក្រុមប្រឹក្សាភិបាលមានសញ្ជាតិខ្មែរ ត្រូវបានតម្រូវឲ្យមកថតរូប ស្នែនម្រាមដៃ និងក្នុងសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលបានរៀបរាប់ខាងលើដើម្បីទទួលបាននូវពន្ធប៉ាតង់ ឬ/វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។ ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធអាចស្នើសុំឲ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប និងស្នែនម្រាមដៃ ដល់ទីតាំងសគ្រាស ឬទីកន្លែងសមស្របណាមួយ[15]។

ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានតម្រូវឲ្យបំពេញព័ត៌មានក្នុងទម្រង់ ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកនូវច្បាប់ដើមឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម៖

- **ឯកសារចម្បង**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ
  - លក្ខន្តិក:ក្រុមហ៊ុនសម្រាប់នីតិបុគ្គល
  - ព័ត៌មានគណនីធនាគាររបស់ក្រុមហ៊ុន ដូចជាលិខិតបញ្ជាក់ គណនីធនាគារ របាយ-ការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយ:ពេល ៣ខែ ដែលមានទំហំ ៣៥x៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។
  - ប័ណ្ណសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចនទ្រព្យ

[15] ប្រការ៧ នៃប្រកាសលេខ ៤៩៦ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៦ ស្តីពី ការចុះបញ្ជីពន្ធដារ

- **ឯកសារផ្សេងៗ**
  - វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់ គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់)
  - អាជ្ញាបណ្ណដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច (បើមាន)[16]

១.២.២.៤ កម្រៃសេវាចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធ

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ភាគច្រើនត្រូវបានចូលជាប្រភេទ អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ គ្រប់អាជីវកម្មត្រូវតែបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំដំបូង ដែលពន្ធនេះគឺជាពន្ធចុះបញ្ជីអាជីវកម្មប្រចាំឆ្នាំ។ ប្រសិនបើការចុះបញ្ជីធ្វើនៅ ពាក់កណ្តាលឆ្នាំ នៃឆ្នាំប្រក្រតិទិន (ថ្ងៃទី ០១ កក្កដា ដល់ ៣១ ខែធ្នូ) នោះការបង់ពន្ធត្រូវគិតតែពាក់កណ្តាលឆ្នាំប៉ុណ្ណោះ[17]។ ពន្ធប្រចាំឆ្នាំដែលមានចំនួន ១លាន១សែន៥ម៉ឺនរៀល គឺប្រមាណ ៣០០ដុល្លារ។ ការបង់ពន្ធប៉ាងតង់លើកដំបូងត្រូវធ្វើក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបានចុះបញ្ជីពាណិជ្ជកម្មរួច។ ពន្ធប៉ាតង់ត្រូវបង់ជារៀងរាល់ឆ្នាំសម្រាប់អាជីវកម្មរៀងរាល់ឆ្នាំ សម្រាប់អាជីវកម្មរបស់ក្រុមហ៊ុន។

នៅក្នុងអំឡុងពេលនៃការបំពេញនៅព័ត៌មានបឋម តម្រូវអោយក្រុមហ៊ុនធ្វើការបង់កម្រៃចំពោះកម្រៃសេវាការចុះបញ្ជីពន្ធដារចំនួន ៤០០.០០០រៀល (សែសិបម៉ឺនរៀល) ។

តាមបែបបទរដ្ឋបាលរបស់រដ្ឋបាលសារពើពន្ធ តម្រូវតម្កល់ឯកសារក្រុមហ៊ុន ដែលជាលិខិតមានលក្ខណៈគតិយុត្ត ស្តីពីការបង្កើតក្រុមហ៊ុន ដែលតម្រូវអោយបង់កម្រៃពន្ធប្រថាប់ត្រាចំនួន ១.០០០.០០០ រៀល (មួយលានរៀល)[18]។

១.២.២.៥ រយៈពេលពេលទទួលបានការចុះបញ្ជីពន្ធដារ

រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ ការទទួលសុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ដោយបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារបន្ទាប់ពីបានពិនិត្យឃើញថា សំណុំ ឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់។ ក្រុមហ៊ុនដែលទទួលបានសេចក្តីសម្រេចចុះបញ្ជីពន្ធដារ ០១ថ្ងៃ ទៅ ០៧ថ្ងៃធ្វើការ ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិក (E-registration)។ ចំពោះការចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ រយៈពេល ០៧ ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ។ ក្រោយពីពេលចុះបញ្ជីក្រុមហ៊ុនរួចរាល់ រដ្ឋបាលសារពើពន្ធត្រូវចុះដល់ទីតាំងផ្ទាល់

[16] ប្រការ៧ នៃប្រកាសលេខ ៤៩៦ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៦ ស្តីពី ការចុះបញ្ជីពន្ធដារ

[17] ប្រការ៧ នៃប្រកាសលេខ ១៨២១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី វិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់

[18] មាត្រា២ នៃប្រកាសលេខ ៥០៧ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា

របស់សហគ្រាស ដើម្បីថតរូបទីតាំង និងកត់ត្រាទិន្នន័យរបស់ទីតាំងក្រុមហ៊ុន (GPS) ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រគល់ឯកសារផ្លូវការ ដែលបានចេញដោយរដ្ឋបាលសារពើពន្ធ ដោយមានការចុះហត្ថលេខាទទួលត្រឹមត្រូវពីអ្នកជាប់ពន្ធ។ ឯកសារផ្លូវការនៃការចុះបញ្ជីពន្ធដារ មានដូចជា៖

- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ
- ប័ណ្ណពន្ធប៉ាតង់
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ[19]។

[19] ប្រការ១១ នៃប្រកាសលេខ ៤៩៦ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៦ ស្តីពី ការចុះបញ្ជីពន្ធដារ

ជំពូកទី២

នីតិវិធីតម្រូវបន្ថែមសម្រាប់ក្រុមហ៊ុន អតិថិជនលំនៅឋាន មុនដំណើរការអាជីវកម្ម

ជំពូកទី២
នីតិវិធីតម្រូវបន្ថែមសម្រាប់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានមុនដំណើរការអាជីវកម្ម

បន្ទាប់ពីក្រុមហ៊ុនបានបំពេញបែបបទ និងលក្ខខណ្ឌគ្រប់គ្រាន់តាមច្បាប់តម្រូវនៅក្រសួងពាណិជ្ជកម្ម និងកាតព្វកិច្ចចុះបញ្ជីពន្ធដាររួចរាល់ហើយ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននឹងលេចមកជារូបរាង ប៉ុន្តែពុំទាន់អាចចាប់ផ្តើមប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានបានឡើយ លុះត្រាតែក្រុមហ៊ុនមានគម្រោងអភិវឌ្ឍលំនៅឋាន ច្បាស់លាស់និងទទួលបានលិខិតអនុញ្ញាតសាងសង់ ក៏ដូចជាអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន។ តើក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវបំពេញនូវនីតិវិធីបន្ថែមអ្វីខ្លះមុននឹងដំណើរការអាជីវកម្ម? ដើម្បីធ្វើការបកស្រាយ យើងខ្ញុំនឹងធ្វើការបង្ហាញដូចតទៅពីអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន(២.១)លិខិតអនុញ្ញាតសាងសង់របស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន(២.២)។

២.១. អាជ្ញាបណ្ណអភិវឌ្ឍលំនៅឋាន

អាជ្ញាបណ្ណសំដៅដល់លិខិតគតិយុត្តដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុញ្ញាតឲ្យពាណិជ្ជករ ឬវិនិយោគណាមួយ ប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាននៅព្រះរាជាណាចក្រកម្ពុជា។ តើក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវគោរពតាមបែបបទបែបណាទើបទទួលបានអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ? ដើម្បីធ្វើការបកស្រាយឲ្យលំអិត យើងខ្ញុំនឹងធ្វើការបង្ហាញអំពី ប្រភេទ និងថ្លៃអាជ្ញាបណ្ណ(២.១.១) ការស្នើសុំអាជ្ញាបណ្ណ (២.១.២) ការដក និងការព្យួរ(២.១.៣) ។

២.១.១. ប្រភេទ និងថ្លៃអាជ្ញាបណ្ណ

ជាគោលការណ៍ រាល់អាជីវកម្មអភិវឌ្ឍលំនៅឋាន ដែលមានទំហំចាប់ពី ០៤ ល្វែង ឬ ០៣ ភូមិគ្រឹះ ឬ ០៤យូនីត នៃលំនៅឋានឡើងទៅ ត្រូវមានអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋានជាមុនដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[20]។ ចំពោះការធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋានគ្រប់ប្រភេទ ដែលមានកម្មវត្ថុជាការសាងសង់លំនៅឋានសម្រាប់លក់ ដើម្បីស្វែងរកប្រាក់ចំណេញបានដោយត្រូវជ្រើសរើសប្រភេទអាជ្ញាបណ្ណតាមគម្រោងអាជីវកម្មរបស់ខ្លួន។

២.១.១.១. ប្រភេទអាជ្ញាបណ្ណ

អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅដ្ឋាន ចែកចេញជាពីរប្រភេទ៖

- **<u>អាជ្ញាបណ្ណប្រភេទទី១</u>**៖ផ្តល់ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដែលមានដើមទុនផ្ទាល់ខ្លួនទាំងស្រុង និង/ឬដើមទុនខ្វីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនានា ដើម្បីអភិវឌ្ឍលំនៅឋាន

[20] ប្រការ៦ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០១៦ ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

- និងអាចលក់លំនៅឋានដល់អ្នកប្រើប្រាស់នៅពេល បញ្ចប់ការសាងសង់ជាស្ថាពរ។
- **<u>អាជ្ញាបណ្ណប្រភេទទី២</u>**៖ ផ្តល់ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលមានដើមទុនផ្ទាល់ខ្លួនខ្លះ និងឬដើមទុនខ្ចីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុខ្លះ និង/ឬដើមទុនដែលប្រមូលបានពីអ្នកទិញលំនៅឋានជាមុន ដើម្បីអភិវឌ្ឍលំនៅឋាន ដោយសង់បណ្តើរ លក់បណ្តើរ ស្របទៅតាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។

ក្នុងករណីក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន មានបំណងផ្លាស់ប្តូរប្រភេទអាជ្ញាបណ្ណត្រូវស្នើសុំការសម្រេចពីក្រសួងជាមុន។ ចំពោះអាជ្ញាបណ្ណ ត្រូវបានផ្តល់ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋានតែមួយនៅទីតាំងតែមួយ។ ចំណែកគម្រោងអភិវឌ្ឍលំនៅឋានតែមួយត្រូវបានបែងចែកជាច្រើនដំណាក់កាល អាជ្ញាបណ្ណត្រូវបានផ្តល់សម្រាប់ដំណាក់កាលនីមួយៗនៃគម្រោងអភិវឌ្ឍលំនៅដ្ឋាន[21]។

២.១.១.២. ថ្លៃអាជ្ញាបណ្ណ

ថ្លៃអាជ្ញាបណ្ណ ត្រូវបានកំណត់ទៅតាមប្រភេទ និងទំហំនៃសំណង់ ។ ចំពោះ ប្រភេទអាជ្ញា-បណ្ណសំណង់ផ្ទះល្វែង ដែលមានទំហំ ០១ ល្វែង ថ្លៃអាជ្ញាបណ្ណ ១០០.០០០ រៀល ក្នុងមួយល្វែង។ ចំណែកប្រភេទអាជ្ញាបណ្ណសំណង់ភូមិគ្រឹះ សម្រាប់ទំហំភូមិគ្រឹះភ្លោះ ថ្លៃអាជ្ញាបណ្ណ ១.០០០.០០០ រៀល ក្នុងមួយភូមិគ្រឹះ និងសម្រាប់ទំហំភូមិគ្រឹះទោល ថ្លៃអាជ្ញាបណ្ណ ២.០០០.០០០ រៀលក្នុងមួយភូមិគ្រឹះ។ ចំពោះប្រភេទអាជ្ញាបណ្ណសំណង់អាគារសហកម្មសិទ្ធិ ដែលមានបន្ទប់គេង ០១ទៅ០២ ថ្លៃអាជ្ញាបណ្ណ១.០០០.០០០ រៀលក្នុង១យូនីត និងប្រភេទអាជ្ញាបណ្ណសំណង់អាគារសហកម្មសិទ្ធិ ដែលមានបន្ទប់គេង ០៣ ឡើងទៅ ថ្លៃអាជ្ញាបណ្ណ២០០.០០០រៀលក្នុង១យូនីត។

ក្រុមអភិវឌ្ឍលំនៅឋានត្រូវបង់ប្រាក់ថ្លៃអាជ្ញាបណ្ណដូចខាងលើ ទៅគណនីទោលរតនាគា-រជាតិ នៅធនាគារជាតិនៃកម្ពុជា តាមដីការអមរបស់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

២.១.២ ការស្នើសុំអាជ្ញាបណ្ណ

ក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន ដើម្បីដំណើរការអាជីវកម្មអភិវឌ្ឍលំនៅឋានដោយស្របច្បាប់ ក្រុមហ៊ុនទាំងអស់ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ នៅនាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃនាយកដ្ឋាន ឧស្សាកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធ និងធ្វើការបង់កម្រៃសេវាសាធារណៈ។

[21] ប្រការ៨ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

២.១.២.១ ឯកសារតម្រូវ

ចំពោះការដាក់ស្នើសុំអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋាន រៀបចំឯកសារសម្រាប់ដាក់ការស្នើសុំតាមប្រភេទអាជ្ញាបណ្ណដែលបានជ្រើសរើស មានដូចជា ឯកសារសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រភេទទី១ (ក) និង ឯកសារសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រភេទទី២ (ខ)។

ក. ឯកសារសម្រាក់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រភេទទី១

ចំពោះអាជ្ញាបណ្ណប្រភេទទី១ ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- លិខិត និងពាក្យស្នើសុំអាជ្ញាបណ្ណ[22]
- រូបថតទំហំ ៤x៦ របស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំនួន ៣ សន្លឹក
- លក្ខន្តិក:ក្រុមហ៊ុននិងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម(ថតសម្លង)ដោយមានដើមទុនចុះបញ្ជីអប្បបរមា ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល
- លិខិតថ្កោលទោសរបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណចេញដោយក្រសួងយុត្តិធម៌ (ចំពោះជនជាតិខ្មែរ) ឬចេញដោយរដ្ឋសាមី (ចំពោះជនបរទេស)
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជារបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំពោះជនបរទេស (ថតចម្លង)
- ឯកសារបញ្ជាក់ដើមទុនសម្រាប់អភិវឌ្ឍគម្រោងទាំងមូល ឬតាមដំណាក់កាល[23]
- បណ្ណធានារ៉ាបរងលើភារ:ទទួលខុសត្រូវការដ្ឋានដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយ
- លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន និងគម្រោងប្លង់ស្ថាបត្យកម្ម ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬ សាលារាជធានី-ខេត្ត (ថតចម្លង) ប្រសិនជាមាន
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រជួលរយ:ពេលវែងដែលមានធ្វើនីត្យានុកូលកម្មនៅសាលាធានីធានី-ខេត្ត (ថតចម្លង)
- បណ្ណប៉ាតង់ (ថតចម្លង)
- ផែនការអាជីវកម្ម (ផ្អែកលើរយ:ពេលនៃគម្រោងទាំងមូល)
- គំរូកិច្ចសន្យាលក់-ទិញ មានវាយត្រាក្រុមហ៊ុន

[22] មានភ្ជាប់គំរូនៅឧបសម្ព័ន្ធ(ពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូឯកសារសម្រូវ)

[23] មានភ្ជាប់គំរូនៅឧបសម្ព័ន្ធ(ពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូឯកសារសម្រូវ)

- ឯកសារសម្រាប់ផ្សាយពាណិជ្ជកម្ម និងតារាងតម្លៃលក់
- វិក្កយបត្រថ្លៃអាជ្ញាបណ្ណ និងសេវាសាធារណៈ

ខ.ឯកសារសម្រាក់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រភេទទី២

ចំពោះអាជ្ញាបណ្ណប្រភេទទី២ ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- លិខិត និង ពាក្យស្នើសុំអាជ្ញាបណ្ណ[24]
- រូបថតទំហំ ៤x៦ របស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំនួន ៣ សន្លឹក
- លក្ខន្តិកៈក្រុមហ៊ុននិងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម (ថតសម្លង) ដោយមានដើមទុនចុះបញ្ជីអប្បបរមា ២.០០០.០០០.០០០ (ពីរ៉ៃលាន)រៀល
- លិខិតផ្តោលទោសរបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណចេញដោយក្រសួងយុត្តិធម៌ (ចំពោះជនជាតិខ្មែរ) ឬចេញដោយរដ្ឋសាមី (ចំពោះជនបរទេស)
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជារបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំពោះជនបរទេស (ថតចម្លង)
- ឯកសារបញ្ជាក់ដើមទុនសម្រាប់អភិវឌ្ឍគម្រោងទាំងមូល ឬតាមដំណាក់កាល[25]
- លិខិតបញ្ជាក់ការបើកគណនីអភិវឌ្ឍលំនៅឋាននៅធនាគារពាណិជ្ជកម្មណាមួយ[26]
- លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្ម ២% នៃដើមទុនវិនិយោគ ឬតាមដំណាក់កាល[27]
- ប័ណ្ណធានារ៉ាបរងលើការៈទទួលខុសត្រូវការដ្ឋានដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយ
- លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន និងគម្រោងប្លង់ស្ថាបត្យកម្មដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬ សាលារាជធានី-ខេត្ត (ថតចម្លង) ប្រសិនជាមាន
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រជួលរយៈពេលវែងដែលមានធ្វើនីត្យានុកូលកម្មនៅសាលាធានីធានី-ខេត្ត (ថតចម្លង)

[24] មានភ្ជាប់គំរូនៅឧបសម្ព័ន្ធ(ពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូឯកសារសម្រូវ)
[25] មានភ្ជាប់គំរូនៅឧបសម្ព័ន្ធ(ពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូឯកសារសម្រូវ)
[26] មានភ្ជាប់គំរូនៅឧបសម្ព័ន្ធ(ពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូឯកសារសម្រូវ)
[27] មានភ្ជាប់គំរូនៅឧបសម្ព័ន្ធ(ពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូឯកសារសម្រូវ)

- បណ្ណាប៉ាតង់ (ថតចម្លង)
- ផែនការអាជីវកម្ម (ផ្អែកលើរយៈពេលនៃគម្រោងទាំងមូល)
- គំរូកិច្ចសន្យាលក់-ទិញ មានវាយត្រាក្រុមហ៊ុន
- ឯកសារសម្រាប់ផ្សាយពាណិជ្ជកម្ម និងតារាងតម្លៃលក់
- វិក្កយបត្រថ្លៃអាជ្ញាបណ្ណ និងសេវាសាធារណៈ។

២.១.២.២ កម្រៃសាវាសាធារណៈ

កម្រៃសេវាសាធារណៈលើអាជីវកម្មអភិវឌ្ឍលំនៅឋាន ត្រូវបង់ជាមួយថ្លៃអាជ្ញាបណ្ណ ហើយកម្រៃសាវាសាធារណៈត្រូវបានបែងចែកតាមទំហំនៃសំណង់ដែលមានដូចជា៖

សំណង់ផ្ទះល្វែងដែលមានទំហំចាប់ពី០៤ទៅ១០ល្វែង ត្រូវបង់សេវាសាធារណៈ ៣០០,០០០ រៀល, ទំហំចាប់ពី១១ទៅ៥០ល្វែង ថ្លៃសេវាសាធារណៈចំនួន ៦០០,០០០រៀល, ទំហំចាប់ពី ៥១ទៅ ១០០ល្វែង សេវាសាធារណៈចំនួន ១,០០០,០០០ រៀល និងទំហំចាប់ពី ១០១ល្វែងឡើងទៅថ្លៃសេវាសាធារណៈចំនួន ១,៦០០,០០០ រៀល។

សំណង់ភូមិគ្រឹះត្រូវបានបែងចែកជាពីគឺសំណង់ភូមិគ្រឹះភ្លោះ និងសំណង់ភូមិគ្រឹះទោល។ ចំពោះភូមិគ្រឹះភ្លោះ ចាប់ពី០៣ទៅ១០ភូមិគ្រឹះត្រូវបង់ថ្លៃសេវាធារណៈចំនួន៦០០,០០០រៀល, ភូមិគ្រឹះភ្លោះ ចាប់បើពី១១ទៅ៥០ភូមិគ្រឹះ បង់ថ្លៃសេវាធារណៈចំនួន១,២០០,០០០រៀល, និងភូមិគ្រឹះភ្លោះ ចាប់ពី៥១ភូមិគ្រឹះឡើងទៅ បង់ថ្លៃសេវាសាធារណៈចំនួន២,២០០,០០០រៀល។ ចំណែកភូមិគ្រឹះទោលចាប់ពី០៣ទៅ១០ភូមិគ្រឹះត្រូវបង់ថ្លៃសេវាសាធារណៈចំនួន ៦០០,០០០រៀល, ភូមិគ្រឹះទោលចាប់ពី១១ ទៅ៥០ភូមគ្រឹះត្រូវបង់ថ្លៃសេវាសាធារណៈ១,២០០,០០០រៀល, និងភូមិគ្រឹះទោលចាប់ពី៥១ឡើងទៅ ត្រូវបង់ថ្លៃសេវាសារណៈចំនួន ២,២០០,០០០រៀល។

សំណង់អាគារសហកម្មសិទ្ធិគ្រប់ទំហំ ដែលចាប់ពី០៤ទៅ១០យូនីត ត្រូវបង់សេវាសាធារណៈ ៣០០,០០០រៀល, អាគារសហកម្មសិទ្ធិពី១១ទៅ៥០យូនីតត្រូវបង់សេវាសាធារណៈ ៦០០,០០០រៀល, អាគារសហកម្មសិទ្ធិពី៥១ទៅ១០០យូនីត ត្រូវបង់សេវាសាធារណៈ១,០០០,០០០រៀល, អាគារសហកម្មសិទ្ធិពី១០១ទៅ២០០ យូនីតត្រូវបង់សេវាសាធារណៈ ១,៦០០,០០០រៀល, អាគារសហកម្មសិទ្ធិពី២០១ ទៅ៤០០ត្រូវបង់សេវាសាធារណៈ២,០០០,០០០រៀល, និងអាគារសហកម្មសិទ្ធិពី៤០០ឡើងទៅ ត្រូវបង់ថ្លៃសេវាសាធារណៈ២,២០០,០០០រៀល។

២.១.២.៣ ការត្រួតពិនិត្យ និងសំរេចលើពាក្យស្នើសុំអាជ្ញាបណ្ណ

ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវបំពេញពាក្យស្នើ និងឯកសារតម្រូវតាមប្រភេទនៃអាជ្ញាបណ្ណនៃគម្រោងដែលជ្រើសរើស បន្ទាប់មកត្រូវយកពាក្យស្នើសុំ និង

ឯកសារតម្រូវទៅកាន់ការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។ បន្ទាប់ពីម្ចាស់គម្រោងអភិវឌ្ឍលំនៅឋានដាក់ពាក្យសុំអាជ្ញាបណ្ណ និងសំណុំឯកសារដែលក្រសួងតម្រូវពេញលេញគ្រប់ចំនួនហើយនោះ ក្រសួងនឹងធ្វើការពិនិត្យ និងសម្រេចផ្តល់ ឬមិនផ្តល់អាជ្ញាបណ្ណ ក្នុង រយៈពេលយ៉ាងយូ ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានអាចផ្លាស់ប្តូរប្រភេទអាជ្ញាបណ្ណដោយស្នើសុំការសម្រេចពីក្រសួង។

២.១.៣.ភាពក ឬការព្យួរអាជ្ញាបណ្ណ

ក្រសួងអាចដកហូត ឬព្យួរអាជ្ញាបណ្ណរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានក្នុងករណីណាមួយខាងក្រោម៖

- គម្រោងអភិវឌ្ឍលំនៅឋាន ពុំត្រូវបានចាប់ផ្តើមអនុវត្តន៍ ក្នុងរយៈពេល ០៣(បី) ខែ គិតចាប់ពីកាលបរិច្ឆេទឬនៃការចេញអាជ្ញាបណ្ណ
- គម្រោងអភិវឌ្ឍលំនៅឋាន ពុំត្រូវបានបញ្ចាក់តាមកាលបរិច្ឆេទកំណត់ ឬបន្ទាប់ពីមានការពន្យារពេលដែលត្រូវបានអនុញ្ញាតជាមុនពីក្រសួង
- ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ពុំបានអនុវត្តត្រឹមត្រូវតាមខ្លឹមសារនៃប្រកាស ព្រមទាំងលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយក្រសួងទៅតាមដំណាក់កាលនីមួយៗ
- ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននៅតែប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ ក្រោយទទួលបានការណែនាំ និងការជាកពិន័យរបស់ក្រសួង
- ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ខកខានមិនបានកាន់កាប់បញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ
- ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ខកខានមិនបានបង់ពន្ធប៉ាតង់អាជីវកម្មអភិវឌ្ឍលំនៅឋាន និងមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវ តាមច្បាប់ស្តីពីសារពើពន្ធនិងបទប្បញ្ញត្តិពាក់ព័ន្ធ
- ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានអសាធនភាព ឬក្ស័យធន ឬប្រព្រឹត្តល្មើសក្នុងអាជីវកម្ម ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ
- លទ្ធផលសវនកម្មបង្ហាញឲ្យឃើញថាមានភាពខុសគ្នាពាក់ព័ន្ធនឹងរបាយការណ៍ប្រចាំខែ និងប្រចាំឆមាស, របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ, និងរបាយការណ៍ដកសាច់ប្រាក់ពីគណនីអភិវឌ្ឍលំនៅឋាន
- ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយ ដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច។

២.២ លិខិតអនុញ្ញាតសាងសង់របស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

លិខិតអនុញ្ញាតសាងសង់ គឺជាលិខិតមួយដែលមានអត្ថប្រយោជន៍យ៉ាងខ្លាំងសំរាប់ ការងារសាងសង់ ហើយក៏ជាលិខិតបទដ្ឋានគតិយុត្តមួយ ដែលបង្ហាញពីគ្រឹះស្របច្បាប់ សម្រាប់ការងារសាងសង់ មានន័យថា ប្រជាពលរដ្ឋគ្រប់រូបទាំងរូបវន្ត៍បុគ្គល ឬបុគ្គលសាធារណ: និងឯកជនមានសិទ្ធិពេញលេញ ក្នុងការសាងសង់សំណង់គ្រប់ប្រភេទ នៅលើដីធ្លីដែលជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួនដែលមានការ ការពារនិងទទួលស្គាល់ដោយអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់។ រាល់សំណង់ទាំងឡាយណា ដែលធ្វើការសាងសង់ទាំងក្នុងទីក្រុង និងទីប្រជុំជន អោយតែសំណង់នោះមានលក្ខណ:រឹងមាំ គឺសុទ្ធតែទាមទារអោយមានការផ្តល់លិខិតអនុញ្ញាតសាងសង់ជាមុន រួមទាំងការផ្លាស់ប្តូរទ្រង់ទ្រាយ អាគារ ដែលមានស្រាប់ដែលពាក់ពន្ធ័នឹងផ្នែកសំខាន់ៗមួយចំនួន[28]។ ចំពោះលំនៅឋានដែលបានកំនត់ក្នុងអាជីវកម្មអិវឌ្ឍលំនៅឋានគឺសំដៅដល់គម្រោងសាងសង់ ផ្ទះល្វែង ខុនដូ ភូមិគ្រឹះ អាគារសហកម្មសិទ្ធិសំណង់ផ្សេងទៀតដែលមានគោលដៅបម្រើឱ្យការស្នាក់នៅ។ ដូចនេះ លិខិតអនុញ្ញាតសាងសង់ពិតជាមានសារ: សំខាន់ណាស់សម្រាប់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ក្នុងការធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋានព្រោះទាល់តែក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទទួលស្គាល់ ចេញលិខិតអនុញ្ញាតអោយ ទើបអាចប្រកបអាជីវកម្មរបស់ខ្លួនបាន។ ម្ចាស់អាជីវកម្មអភិវឌ្ឍលំនៅត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុនសិន ដើម្បីអោយក្រសួងត្រួតពិនិត្យពីប្លង់នៃគម្រោងអភិវឌ្ឍលំនៅឋានមានបច្ចេកទេស ស្តង់ដា ក៏ដូចជា ការរៀបចំទៅតាមច្បាប់ដែរឬទេ ។

លិខិតអនុញ្ញាតសាងសង់ជាផ្នែកមួយនៃ ការចាប់ផ្តើមអភិវឌ្ឍលំនៅឋាន ហើយមានអាជ្ញាធរខុសៗគ្នាជាច្រើនធ្វើការពិនិត្យនឹងសំរេចលើលិខិតនេះ ហេតុនេះយើងត្រូវស្វែងយល់ឱ្យច្បាស់ទៅលើ នីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ (២.២.១) និងសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ (២.២.២) បន្ថែមពីនេះទៅទៀត ក៏ត្រូវសិក្សាបន្តនៅពេលដែរចេញ លិខិតអនុញ្ញាតសាងសង់ហើយក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវស្នើសុំពាក្យបើកការដ្ឋាន បិទការដ្ឋាន និងវិញ្ញាបនបត្របញ្ជាក់សំណង់ ត្រឹមត្រូវ (២.២.៣) ដោយការដាក់ពាក្យស្នើសុំបិទ ការដ្ឋាន និងវិញ្ញាបនបត្រសម្គាល់សំណង់ត្រឹមត្រូវ នេះគឺត្រូវធ្វើនៅពេល ដែលគម្រោង អភិវឌ្ឍលំនៅឋានបានបញ្ចប់ជាស្ថាពរ ។

[28] មាត្រា ២ នៃអនុក្រឹត្យលេខ៨៦ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៧ស្តីពីលិខិតអនុញ្ញាតសាងសង់

២.២.១. ការស្នើសុំលិខិតអនុញ្ញាតសាងសង់

មុនពេលចាប់ផ្តើមការសាងសង់គម្រោងអភិវឌ្ឍលំនៅឋាន ម្ចាស់អភិវឌ្ឍលំនៅឋាន ដែលត្រូវអនុវត្ត ការងារសាងសង់សំណង់ថ្មី ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់នៅរដ្ឋបាលសំណង់សម្រាប់ការងារសាងសង់ដែលបានស្នើនោះ។ ការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់គឺត្រូវធ្វើឡើងទៅតាមអាជ្ញាធរដែលមានសមត្ថកិច្ចផ្សេងៗគ្នា មុននឹងដាក់ទៅអាជ្ញាធរម្ចាស់ស្នើសុំត្រូវយល់ពីខ្លឹមសារនៃពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ (២.២.១.១) បន្ទាប់មកការចុះហត្ថលេខារបស់ម្ចាស់គម្រោងលើពាក្យស្នើសុំ (២.២.១.២) ការដាក់ពាក្យស្នើសុំនៅសាលាខេត្តក្រុង(២.២.១.៣) ការដាក់ពាក្យស្នើសុំ នៅសាលារាជធានីភ្នំពេញ (២.២.១.៤) និងការដាក់ពាក្យស្នើសុំទៅអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម និងឧន្ទកាល័យ (២.២.១.៥) ។

២.២.១.១ ខ្លឹមសារនៃពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់

រាល់ការសាងសង់ក្នុងទីក្រុងទីប្រជុំជន និងរាល់សំណង់ថ្មីទាំងអស់ ដែលជាប្រភេទសំណង់ នៃអាជីវកម្មអភិវឌ្ឍលំនៅឋាន សុទ្ធតែត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់។ មុននឹងដាក់ពាក្យសុំអ្នកអភិវឌ្ឍលំនៅឋានត្រូវស្វែងយល់ពីខ្លឹមសារនៃពាក្យស្នើសុំនោះជា មុនសិនថាត្រូវភ្ជាប់ឯកសារអ្វីខ្លះ ក៏ដូចជាលក្ខខណ្ឌបែបណាដែលត្រូវរៀបចំពាក្យស្នើសុំនេះ ។ ដោយយោងតាមមាត្រា ៩ (បណ្តាឯកសារនៃពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់) នៃអនុក្រឹតស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ បានកំនត់យ៉ាងច្បាស់ថា មុននឹងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ម្ចាស់គម្រោងអភិវឌ្ឍលំនៅឋានត្រូវភ្ជាប់មក ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម ៖

- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់អចលនវត្ថុ ឬបណ្ណ្ណសំគាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ឬ វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រអនុញ្ញាតកាន់កាប់បណ្តោះអាសន្ន។
- សាលកបត្រ៍ដីឡូត៍ៈប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬលេខាគណិតឯកជន ។ ប្លង់នេះត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខា ដោយអ្នកធ្វើ និងអនុម័តដោយមន្ទីរសុរិយោដី។ នៅលើប្លង់នេះមានបញ្ជាក់ដែលមានដូចជាៈ
    - ទីតាំងនៃដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំទីតាំងនៃដីឡូត៍ដែលនៅជាប់គ្នា ផ្លូវចូលទៅដីឡូត៍នោះ ហើយនឹងលក្ខណៈរបស់ផ្លូវនោះ (សាធារណៈ ឬឯកជនឈ្មោះម្ចាស់កម្មសិទ្ធិ)
    - ឈ្មោះ ឬលេខ ផ្លូវធំ និងផ្លូវតូច

- ផ្ទៃក្រឡាដីឡូត៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ (ទីតាំង និងកម្ពស់)
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និងកម្ពស់របស់វា
- មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំណុចនឹងថ្ពល់សម្រាប់សម្គាល់កម្ពស់ ដែលបោះនៅដីឡូត៍
- បន្ទាត់ជួរតម្រង់ផ្លូវការសាធារណៈ។

- ប្លង់ទីតាំងអាគារដីឡូត៍ៈ មាត្រាដ្ឋាន១:២០០ (ឬ១:៥០០ ក្រោយទទួលការយល់ព្រមពី ប ណ្តាមន្ទីរទទួលបន្ទុកដីឡូត៍ធំៗ)។ នៅលើប្លង់នេះមានបញ្ជាក់អំពីដែលមានដូចខាងក្រោមៈ
  - ការបោះទីតាំងនៃសំណង់ក្នុងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានការ បញ្ជាក់ អំពីចម្ងាយរវាងអាគារមួយ ឬច្រើន និងព្រំប្រទល់ដីឡូត៍ ហើយនិង ចម្ងាយទៅបណ្តាអាគារ នៅជិតខាងដែលមានស្រាប់
  - រាល់ការរៀបចំផែនដីទំនេរ ដោយបញ្ជាក់ប្រភេទដី និងដំណាំមានស្រាប់ និង ទៅអនាគត បណ្តាកន្លែងចតឡានឡានរថយន្ត និងរបង (កម្ពស់ និងទីតាំង)
  - បំពង់លូក្រៅអាគារ (រូបធាតុ វិជ្ជមាត្រ ចំណោត កំរិតកំពស់ រណ្តៅពិនិត្យ) រហូតដល់ កន្លែងតភ្ជាប់ទៅបណ្តាញសាធារណៈ សំរាប់បណ្តាញទឹកស្អុយ និង សំរាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង ។
  - ចំណុចនឹងថ្ពល់នៃកំពស់ដីឡូត៍ ក្រោយការងាររៀបចំហើយ ។
- ប្លង់អាគារគ្រប់ជាន់ មាត្រដ្ឋាន ១:១០០ នៅលើប្លង់នេះមានបញ្ជាក់ពី

-គោលដៅប្រើប្រាស់រាល់បន្ទប់ និង ផ្ទៃក្រលារបស់វា

-បណ្តាបបនភណ្ឌអនាម័យ និងកន្លែងដាក់បំពង់លូ

-ចំពោះការរៀបចំទីតាំងឧស្សាហកម្ម : របៀបរៀបចំទីតាំងគ្រឿងយន្ត

- ប្លង់ផ្ទៃកបណ្តាញក្រោមដីនានា និងអាងបង្គន់អនាម័យ មាត្រដ្ឋាន ១:១០០
- ប្លង់មុខភាពនៃអាគារ (facades) មាត្រដ្ឋាន ១:១០០ នៅលើបណ្តាប្លង់មុខភាពមាន បង្ហាញអំពីៈ

- កម្រិតកម្ពស់កំរាលនីមួយៗ កំរិតកំពស់ដីនៅជើងអាគារ ដោយបញ្ជាក់កំរិតកំពស់ដីធម្មជាតិ ដីចាក់បំពេញ ឬដីចូកចេញ ។
- កំរិតកំពស់ដំបូល និងព្រំដំបូល ឬ កំរិតកំពស់នៅពេលសង់ហើយនៃដំបូលតែរ៉ាស់ និងក្បាំងក្បាលជញ្ជាំង
- កំរិតកំពស់សង់ហើយនៃទ្រើងផ្ការ
- រូបធាតុសំរាប់មុខភាព

- ប្លង់ពុះពីរយ៉ាងតិច មាត្រាដ្ឋាន១:១០០ ៖ នៅលើប្លង់ពុះមានការបង្ហាញដូចប្លង់មុខភាព ពុះមួយបង្ហាញអាងបង្គន់អនាម័យ
- តារាងផ្ទៃក្រលាមួយសំរាប់ជាន់នីមួយៗ
- សលាកបត្រគណនាផ្ទៃបាតដី និងសន្ទស្សន៍នៃការប្រើប្រាស់៖ ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតឡើងលើ ប្លង់ត្រូវបង្ហាញរបៀបខុសពីគ្នា ចំពោះផ្នែកមានពីមុន ការរុះរើ និងសភាពគ្រោងធ្វើ។ សាលាក្រុង និងសាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និងឯកសារបន្ថែម ពាក់ពន្ធ័នឹងសំណុំលិខិតអនុញ្ញាតសាងសង់។អាចអោយអ្នកស្នើសុំសាងសង់ផ្តល់បណ្តាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្ត្រ ផ្នែកការពារប្រឆាំងធាតុរំខានគ្រប់ប្រភេទ ផ្នែកសណ្តាប់ធ្នាប់សាធារណ: ការពារបេតិកភណ្ឌ និងទេសភាព ។ក្រោយពីទទួលបានលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្ទុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និងដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ ។

ដើម្បីផ្តល់ភាពងាយស្រួល និងចំនេញពេលវេលាដល់ម្ចាស់សំណង់ដែលនៅតាមបណ្តាលខេត្ត-ក្រុង អាចដាក់ពាក្យស្នើសុំនៅសាលាខេត្ត-ក្រុងបានដោយមិនចាំបាច់រងចាំការសំរេច ពីអាជ្ញាធរនៅរាជធានីភ្នំពេញទេ តែដោយឡែកចំពោះសំណង់ដែលមានទីតាំងនៅក្នុងរាជធានី ភ្នំពេញ ចាំបាច់ត្រូវតែដាក់ពាក្យសុំ នៅសាលារាជធានីភ្នំពេញ ។ តែបើចំពោះប្រភេទសំណង់ដែល សាងសង់លើផ្ទៃដីលើសពី ៣ ០០០ម៉ែត្រទ្វេរគុណ ចាំបាច់ត្រូវដាក់ពាក្យសុំទៅក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ។

២.២.១.២ ការចុះហត្ថលេខារបស់ម្ចាស់គម្រោងលើពាក្យសុំ

រាល់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគម្រោងស្នើសុំ ។ កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវ

ចុះហត្ថលេខាលើសំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ដែរ [29] ។ អ្នកធ្វើគម្រោងស្នើសុំត្រូវតែជាអ្នកប្រកបវិជ្ជាជីវៈសាងសង់មានសញ្ជាតិខ្មែរដែលមានអាជ្ញាបណ្ណ ឬនីតិបុគ្គលសញ្ជាតិខ្មែរដែលបានចុះបញ្ជី និងមានអាជ្ញាបណ្ណ។ ផ្អែកតាមអនុក្រឹត្យស្តីពីលិខិតអនុញ្ញាត សាងសង់ ពាក្យសុំលិខិតអនុញ្ញាតសាងសង់ត្រូវធ្វើឡើងជាភាសាខ្មែរទាំងស្រុង។ សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ត្រូវជាភាសារខ្មែរ ចំពោះអត្ថបទអង់គ្លេស ឬបារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះ[30]។ ឯកសារទាំងឡាយ ដែលជាផ្នែកមួយ ឬជាឯកសារដែលត្រូវដាក់ជូនរដ្ឋបាលសំណង់ធ្វើឡើងជាភាសាបរទេស ដែលត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាខ្មែរ។ ឯកសារដែលបានភ្ជាប់បន្ថែមជាឯកសារយោង អាចធ្វើឡើងជាភាសាបរទេស ។

២.២.១.៣ ការដាក់ពាក្យសុំនៅសាលាខេត្ត-ក្រុង

ការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់នៅសាលាខេត្ត-ក្រុង ម្ចាស់សំណើរ ត្រូវប្រតិបត្តិតាម នីតិវិធីដូចខាងក្រោម ៖

ក. បរិបថនៃការត្រួតពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

ម្ចាស់សំណើរត្រូវដាក់ពាក្យសុំទៅអាជ្ញាធរមូលដ្ឋាននៃទីតាំងសំណង់ ហើយអាជ្ញាធរ និងបញ្ជូនពាក្យសុំនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ពិនិត្យ រយៈពេល ៥ថ្ងៃ (មិនគិតករណីការបញ្ជូនទៅអង្គភាពពាក់ពន្ធ័ក្នុងករណីចាំបាច់) រួមមន្ទីរ និងបញ្ជូនទៅសាលាខេត្ត-ក្រុង ពិនិត្យនិងសំរេចក្នុងរយៈពេល ០៥ថ្ងៃ ទើបបញ្ជូនទៅម្ចាស់សំណើវិញ គឺមានរយៈពេលសរុប ៣០ថ្ងៃនៃថ្ងៃធ្វើការ[31]។

ខ. រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

ចំពោះការពិនិត្យ និងសំរេចលំអិតនៅថ្នាក់មូលដ្ឋាន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង រយៈពេល២៥ថ្ងៃ ដោយម្ចាស់សំណើរដាក់ ពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅសាលាឃុំ សង្កាត់របស់ខ្លួន ។ បន្ទាប់មកសាលាឃុំ សង្កាត់ បញ្ជូនទៅការិយាល័យដែនដី នគរូបនីយកម្ម សំណង់ ភូមិសាស្ត្រ ស្រុក ខណ្ឌដើម្បីត្រួតពិនិត្យលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមតារាងត្រួតពិនិត្យ ចុះហត្ថលេខា សង្ខេបលើតារាងពិនិត្យ ចុះលេខ ចុះកាលបរិច្ឆេទចូល និងការប្រថាប់ត្រាចេញបង្កាន់ដៃជូនម្ចាស់ សំណើ (បើមានឯកសារគ្រប់គ្រាន់តាមការកំណត់ដូចខាងលើ) ពិ

[29] មាត្រា ១១ នៃអនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

[30] មាត្រា ១០ នៃអនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

[31] សេចក្តីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

និត្យលក្ខណៈគតិយុត្ត នៃ ឯកសារចុះវាស់ដីនិងគូរប្លង់ដីកាន់កាប់ពិនិត្យទីតាំងព្រំដី និងធ្វើកំណត់ហេតុ ចម្បងជាមួយដី ជិតខាងធ្វើជំនួសសេចក្ដីព្រាងបញ្ជាក់ពីតំបន់ទីតាំងសាងសង់ និងគម្លាតអាគារ ។

ក្រោយពីពិនិត្យចប់ការិយាល័យនេះ បញ្ជូនឯកសារទៅសាលាស្រុក-ខណ្ឌ ពិនិត្រ្យយ:ពេល ០៣ថ្ងៃ ដើម្បីចុះលេខ ចុះកាលបរិច្ឆេទចូលនិងប្រថាប់ត្រាពិនិត្យលក្ខណៈគតិយុត្ត នៃឯកសារ និង បញ្ជាក់លើលិខិតស្នាមផ្សេងៗ ហើយសាលាស្រុក-ខណ្ឌ និងបញ្ជូនត្រលប់ទៅ ការិយាល័យដែនដី នគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រ ស្រុក-ខណ្ឌវិញ ។ ហើយការិយាល័យត្រូវបញ្ជូនឯកសារបន្ត ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត-ក្រុង ពិនិត្យក្នុងរយៈពេល០៧ថ្ងៃ បន្ទាប់ពីមន្ទីរពិនិត្យហើយការិយាល័យរដ្ឋ បាលទទួលនិងបញ្ជូនឯកសារទទួល ក្នុងរយៈពេល០២ថ្ងៃ ហើយដោយក្រុមទាំងពីរនេះ ធ្វើការពិនិត្យលើលក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវតាមតារាងត្រួត ពិនិត្យ ហើយចុះ ហត្ថលេខាសង្ខេបលើតារាង ត្រួតពិនិត្យចុះលេខ ចុះកាលបរិច្ឆេទចូល និងការ ប្រថាប់ត្រា ពិនិត្យលក្ខណៈគតិយុត្តនៃឯកសារពិនិត្យទំរង់ផ្លូវការច្បាប់នៃឯកសារធ្វើលិខិត ផ្ដល់មតិ យោបល់ជូនសាលាខេត្ត-ក្រុង ។

បន្ទាប់មកការិយាល័យរដ្ឋបាលនេះ ត្រូវបញ្ជូនឯកសារទៅកាន់ ការិយាល័យសំណង់ និង ការិយាល័យដែនដី នគរូបនីយកម្ម ពិនិត្យក្នុងរយៈពេល ០៧ថ្ងៃ ដោយពិនិត្យសំរេចមើល លើនគរូប នីយកម្មបញ្ញត្តិ គម្លាតអាគារនិងប្លង់ប្រើប្រាស់ដីធ្លី បទបញ្ជានៃការប្រើប្រាស់ដី ធ្លីដែរឬទេ ? ការពិនិ ត្យលក្ខណៈបច្ចេកទេសនៃសំណង់ដូចជា សោភណ្ឌភាពរចនាបថ ស្ថាបត្យកម្ម ប្លង់គ្រប់ជាន់ គំហើ ញអាគារ ទាំង ៤ទិសពុះបណ្ដោយ ពុះទទឹង និងបទដ្ឋាន ប្រើប្រាស់សំភារៈសំណង់ ។ ការិយាល័យ ទាំងពីរបញ្ជូនត្រលប់ទៅថ្នាក់ដឹកនាំមន្ទីរ ដើម្បីផ្ដល់យោបល់ និងធ្វើមូយវិចារភ្ជាប់នឹងសំណុំឯកសារ នៃពាក្យសុំដើម្បីបញ្ជូនទៅសាលា ខេត្ត-ក្រុង ពិនិត្យ និងសំរេចទុកជាស្ថាពរក្នុងរយៈពេល ០៥ថ្ងៃ។ ប៉ុន្តែបើក្នុងករណីចាំបាច់ដែល តម្រូវឱ្យមានការវិភាគ និងពិនិត្យពីអង្គភាពជំនាញដែល ពាក់ពន្ធ័នឹង ការសាងសង់នោះទៀត ដូចជា ការពិនិត្យលើផ្លូវទឹកដើម្បីរៀបចំលូបង្ហូរទឹកស្អុយ ដែលត្រូវទាក់ទង ជាមួយក្រុមការងារអភិវឌ្ឍ ជនបទជាដើម ថ្នាក់ដឹកនាំមន្ទីរអាចបញ្ជូនឯកសារនេះទៅអង្គភាពពាក់ព ន្ធ័ពិនិត្យក្នុងរយៈពេល ៥ថ្ងៃ ដោយពិនិត្យលើលក្ខណៈបច្ចេកទេសគំរោងស្នើសុំស្ថិតនៅក្នុងតំបន់ នោះ ពាក់ពន្ធ័និង បញ្ហាបរិស្ថាន ទេសចរណ៍ ប្រឡាយទឹក លូទឹកផ្លូវថ្នល់ ឬតំបន់ហាមឃាត់ ហើយ អង្គភាពពាក់ ពន្ធ័នឹងបញ្ជូនត្រលប់ទៅថ្នាក់ដឹកនាំមន្ទីរដើម្បីផ្ដល់យោបល់និងធ្វើមូលវិចារភ្ជាប់ និង សំណុំឯកសារនៃពាក្យសុំដើម្បីបញ្ជូនទៅសាលាខេត្ត ក្រុងពិនិត្យនិងសំរេចជាស្ថាពរ[32]។

[32] សេចក្ដីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្ដីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំ លិខិតអនុញ្ញាតសាងសង់

សាលាខេត្ត-ក្រុងពិនិត្យ និងសំរេចជាស្ថាពរក្នុងរយៈពេល០៥ថ្ងៃដោយពិនិត្យលើ លក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវតាមតារាងត្រួតពិនិត្យចុះហត្ថលេខាសង្ខេបលើតារាង ត្រួតពិនិត្យ និងសំរេចចុះហត្ថលេខាយល់ព្រម ឬមិនយល់ព្រមនិងបញ្ជូនសំណុំឯកសារដែល អនុញ្ញាតនោះមកម្ចាស់សំណើវិញ។ ក្រៅពីការដាក់ពាក្យសុំ ម្ចាស់សំណង់ត្រូវបង់ពន្ធលើ សោហ៊ុយសេវាសំណង់ក្នុងការពិនិត្យ និងសំរេចលើការសុំលិខិតអនុញ្ញាតសាងសង់ផងដែរ។ បន្ទាប់ពីក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានទទួលបានលិខិតអនុញ្ញាតសាងសង់ ម្ចាស់សំណង់ត្រូវជូន ដំណឹងទៅសាលាស្រុក-ខណ្ឌ និងចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ចហើយត្រូវតម្កល់ទុកនូវ ឯកសារចម្លងលិខិតអនុញ្ញាតនេះ នៅការដ្ឋានមួយច្បាប់[33] ។

២.២.១.៤ ការដាក់ពាក្យសុំនៅសាលារាជធានីភ្នំពេញ

ចំពោះការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់នៅសាលារាជធានីភ្នំពេញ ម្ចាស់គម្រោងអាជីវកម្មអភិវឌ្ឍលំនៅឋានត្រូវអនុវត្តដូចខាងក្រោម :

ក. បរិបថនៃការពិនិត្យនិងសំរេចលើពាក្យសុំ

ម្ចាស់សំណើរត្រូវដាក់ពាក្យសុំ នៅការិយាល័យរដ្ឋបាល នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី សង្កាត់ ខណ្ឌ ហើយអាជ្ញាធរសង្កាត់ ខណ្ឌ និងបញ្ជូនទៅថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងការិយាល័យរដ្ឋបាលទទួលនិងបញ្ជូនឯកសារទទួលក្នុងរយៈពេល ២៥ថ្ងៃ និងបញ្ជូនទៅសាលា រាជធានីភ្នំពេញពិនិត្យក្នុងរយៈពេល ៥ថ្ងៃ រួចចុងក្រោយបញ្ជូនទៅម្ចាស់សំណើរវិញ ។

ខ. រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំ

ក្រោយពេលដែលមន្ទីររៀបចំដែនដីបានទទួលពាក្យ ស្នើសុំលិខិតអនុញ្ញាតសាងសង់ពីម្ចាស់គម្រោងអភិវឌ្ឍលំនៅឋាន មន្ទីរនឹងធ្វើការពិនិត្យ និងសំរេចលើលិខិតអនុញ្ញាតទៅតាមសេចក្តីសំរេចលេខ ០៥ សសរ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និសំរចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ។ ចំពោះការពិនិត្យ និងសំរេចលំអិតនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ រយៈពេល ២៥ថ្ងៃ ក្រោយពីបានទទួលបានសំណុំលិខិតពីសាលា សង្កាត់ ខណ្ឌ ថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុងពិនិត្យរយៈពេល ០៦ថ្ងៃ និងការិយាល័យរដ្ឋបាលទទួល និងបញ្ជូនឯកសារទទួលក្នុងរយៈពេល ០២ ថ្ងៃសរុប ០៨ថ្ងៃ ធ្វើការពិនិត្យលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមតារាង

[33] មាត្រា ១៧ នៃអនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៩៧ស្តីពីលិខិតអនុញ្ញាតសាងសង់

ត្រួតពិនិត្យ ចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យចុះលេខ ចុះកាលបរិច្ឆេទចូលនិងការ ប្រថាប់ត្រា និងចេញបង្កាន់ដៃ បញ្ជូនទៅអនុប្រធានមន្ទីរ ទទួលបន្ទុករដ្ឋបាលហើយចារ។ បញ្ជូនទៅការិយាល័យដែនដីនគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រ ខណ្ឌដើម្បីពិនិត្យ ។ ការិយាល័យដែនដី នគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រខណ្ឌពិនិត្យរយៈពេល ០៦ថ្ងៃ ដោយចុះ ហត្ថលេខាសង្ខេបលើតារាងពិនិត្យ ចុះលេខ ចុះកាលបរិច្ឆេទចូល និងការប្រថាប់ត្រា បញ្ជូនទៅ អនុការិយាល័យហើយបញ្ជូនទៅប្រធានការិយាល័យ ដើម្បីចារបញ្ជូនទៅផ្នែកជំនាញតាមមុខការ ហើយជាផ្នែកសុរិយោដី និងផ្នែកដែនដី នគរូបនីយកម្ម និងសំណង់ ចុះពិនិត្យវាស់វែងគូរប្លង់ដី កាន់កាប់ ដើម្បីធ្វើសាលាកប័ត្រដី និងគណនាផ្ទៃក្រឡា ។

ហើយការិយាល័យនេះបញ្ជូនបន្ត គឺបញ្ជូនទៅការិយាល័យសុរិយោដី និងការិយាល័យបច្ចេកទេស សុរិយោដី និងភូមិសាស្ត្រ ពិនិត្យរយៈពេល ០៤ថ្ងៃដោយពិនិត្យលើឯកសារកាន់កាប់ដីនោះ មានពាក់ព័ន្ធការហាមឃាត់ ឬដីមានទំនាស់ ពិនិត្យសំណុំឯកសារការវាស់វែងដីទំហំដី និងទីតាំងដី ជាការិយាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលលើការងារបង់ពន្ធដី និងបង់ពន្ធសេវាសុរិយោដី។ បន្ទាប់មកទើបបញ្ជូនទៅ ការិយាល័យសំណង់ និងការិយាល័យដែនដី នគរូបនីយកម្ម ពិនិត្យរយៈពេល ០៧ថ្ងៃ ដោយពិនិត្យទៅលើលក្ខណៈនគរូបនីយកម្មបញ្ញត្តិ គម្លាត កំពស់ តំបន់ និង សន្ទស្សន៍នៃការប្រើប្រាស់ដីនិងពិនិត្យលើលក្ខណៈបច្ចេកទេសសំណង់ សោភណ្ឌ៍ភាព រចនាបថស្ថាបត្យកម្ម និងប្លង់ ស្ថាបត្យកម្ម រួចទើបការិយាល័យនេះបញ្ជូនទៅថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុងវិញ។ ហើយថ្នាក់ដឹកនាំមន្ទីរបញ្ជូនទៅអង្គភាពពាក់ពន្ធ ក្នុងករណីចាំបាច់ពិនិត្យរយៈពេល ០៧ថ្ងៃ ដោយពិនិត្យទៅលើគំរោងសាងសង់មានភាពពាក់ពន្ធ៍និងបញ្ហាបរិស្ថាន និងត្រឹមត្រូវតាមតារាងត្រួតពិនិត្យ ហើយអង្គភាពពាក់ពន្ធ៍បញ្ជូនត្រលប់ទៅថ្នាក់ដឹកនាំមន្ទីរដើម្បីផ្តល់យោបល់ និងធ្វើមូលវិចារភ្ជាប់និងសំណុំឯកសារនៃពាក្យស្នើសុំដើម្បីបញ្ជូនទៅសាលារាជធានីភ្នំពេញ ពិនិត្យក្នុងរយៈពេល ០៥ថ្ងៃដោយពិនិត្យលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមតារាងត្រួតពិនិត្យចុះហត្ថលេខាសង្ខេបលើតារាងត្រួតពិនិត្យ ចុះលេខ ចុះកាលបរិច្ឆេទចូល និងការប្រថាប់ត្រា និងពិនិត្យសំរេចចុះហត្ថលេខាយល់ព្រម ឬមិនយល់ព្រមក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន បន្ទាប់មកត្រូវបញ្ជូនលិខិតទៅម្ចាស់សំណើវិញ ។[34]

[34] សេចក្តីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

ក្រោយពេលទទួលបានលិខិតអនុញ្ញាតសាងសង់ ម្ចាស់សំណង់ត្រូវជូនដំណឹងទៅសាលារាជធានីភ្នំពេញ និងចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ច ហើយនឹងត្រូវតម្កល់ទុកនូវឯកសារចម្លងលិខិតអនុញ្ញាតនេះនៅការដ្ឋានមួយច្បាប់ ។

២.២.១.៥ ការដាក់ពាក្យសុំទៅអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម និងខុទ្ទកាល័យទេសរដ្ឋមន្ត្រី

ចំពោះករណីដែលប្រភេទសំណង់ជាសមត្ថកិច្ចរបស់ក្រសួងដែនដី នគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រ ទោះបីជាទីតាំងនៃសំណង់នោះនៅខេត្ត ក្រុង ឬនៅរាជធានីភ្នំពេញ ។ ហើយការដាក់ពាក្យសុំនោះធ្វើឡើងនៅសាលាខេត្ត ក្រុង ឬនៅសាលារាជធានីភ្នំពេញក៏ដោយ ក៏សាលាទាំងពីរនេះត្រូវបញ្ជូនឯកសារនៃពាក្យសុំមកក្រសួងដើម្បីធ្វើការពិនិត្យនិងសំរេចជានិច្ច មិនអាចចេញលិខិតអនុញ្ញាតក្រោមសមត្ថកិច្ចរបស់ខ្លួនបានឡើយ ។ ហេតុនេះយើងខ្ញុំនឹងធ្វើការបងស្រាយ ពីបរិបថនៃការពិនិត្យ និងសំរេចលើពាក្យ សុំលិខិតអនុញ្ញាតសាងសង់ (ក)និង រយៈពេលនៃ ការត្រួតពិនិត្យ និងសំរេចលើលិខិតអនុញ្ញាត សាងសង់ (ខ) នៅអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម និង ខុទ្ទកាល័យទេសរដ្ឋមន្ត្រី ដូចខាងក្រោម :

ក. បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

ម្ចាស់សំណើរត្រូវដាក់ពាក្យសុំទៅអាជ្ញាធរមូលដ្ឋាននៃទីតាំងសំណង់ ហើយអាជ្ញាធរ និងបញ្ជូនពាក្យនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ពិនិត្យរយៈពេល ២៥ថ្ងៃ រួចមន្ទីរនឹងបញ្ជូនទៅសាលាខេត្ត ក្រុង ពិនិត្យក្នុងរយៈពេល ០៥ថ្ងៃ រួចបញ្ជូនទៅអគ្គ-នាយកដ្ឋានរដ្ឋបាលពិនិត្យរយៈពេលកន្លះថ្ងៃ បន្ទាប់មកបញ្ជូនទៅអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ពិនិត្យរយៈពេល ១២ថ្ងៃ ហើយបញ្ជូនបន្តទៅខុទ្ទកាល័យទេសរដ្ឋមន្ត្រីពិនិត្យរយៈពេល០២ថ្ងៃ បន្តទៅអគ្គនាយកដ្ឋានរដ្ឋបាលប្រថាប់ត្រា និងប្រគល់ឯកសាររយៈពេលកន្លះថ្ងៃ ទើបបញ្ជូនមកសាលាខេត្ត ក្រុង ដែលបានបញ្ជូនឯកសារនៃពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់វិញ ហើយចុងក្រោយសាលាខេត្ត ក្រុង ត្រូវបញ្ជូនឯកសារទៅម្ចាស់សំណើរវិញ ។

ខ. រយៈពេលនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

ចំពោះការត្រួតពិនិត្យនិងសំរេចលំអិត លើរយៈពេលលើពាក្យសុំម្ចាស់សំណើរត្រូវដាក់ពាក្យសុំទៅ សាលាខេត្ត-ក្រុង ឬសាលារាជធានីភ្នំពេញ មានរយៈពេលសរុប ៣០ថ្ងៃដូចគ្នា ហើយចំពោះរបៀបនៃការពិនិត្យនិងសំរេចគឺធ្វើតាមដំណាក់កាលបន្តបន្ទាប់ដូចបានរៀបរាប់ខាងលើដដែល ប៉ុន្តែនៅ សាលាខេត្ត-ក្រុង ឬសាលារាជធានីភ្នំពេញ ត្រូវធ្វើលិខិតផ្តល់មតិយោបល់ ភ្ជាប់សំណុំឯកសារ

និង គម្រោងប្លង់ផ្ញើរជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ជាអ្នកពិនិត្យ និង សំរេច។ ហើយការផ្ញើរជូននេះ គឺផ្ញើរទៅអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មពិនិត្យ រយៈ ពេល ១២ថ្ងៃដោយនៅក្នុងផ្នែកនេះមានការត្រួតពិនិត្យនិងសំរេចជា ៦ដំណាក់កាលដូចជា :

- នាយកដ្ឋានស្រាវជ្រាវបទប្បញ្ញត្តិ : រយៈពេលពិនិត្យកន្លះថ្ងៃ ជាអ្នកពិនិត្យលក្ខណៈ គ្រប់គ្រាន់និងត្រឹម ត្រូវតាមតារាងត្រួតពិនិត្យ និងចុះហត្ថលេខាសង្ខេប ចុះលេខ ចុះកាលបរិច្ឆេទ ចូលនិងប្រថាប់ត្រានិងជាអ្នកបញ្ជូនសំណុំឯកសារ ទៅអគ្គនាយកដ្ឋានសំណង់ និងអគ្គ នាយកដ្ឋាន នគរូបនីយកម្មដើម្បី ពិនិត្យ ។
- នាយកដ្ឋាននគរូបនីយកម្ម : ធ្វើការរយៈពេល ០៥ថ្ងៃដោយពិនិត្យលក្ខណៈគតិយុត្តនៃឯក សារពិនិត្យ គម្លាតអាគារ និងការរៀបចំប្លង់ក្នុងដីឡូត៍គណនាសន្ទស្សន៍នៃការប្រើប្រាស់ដី ពិនិត្យមើលទៅលើ ហេដ្ឋារចនាចម្ពន្ធ ពិនិត្យលើខ្សែទូរគមនាគមន៍មានផ្លូវថ្នល់ លូទឹក ទឹក ស្អាត អគ្គីសនី ។ល។ ជាអ្នក សំយោគមតិរបស់អគ្គនាយកដ្ឋានជំនាញទាំងពីរ និងព្រាង លិខិតអនុញ្ញាតសាងសង់ ដាក់ជូនឯកឧត្តម ទេសរដ្ឋមន្ត្រីពិនិត្យ និងសំរេច ។
- អគ្គនាយក និងអគ្គនាយកដ្ឋានរងនៃអគ្គនាយកដ្ឋានដែនដី នគរូបនីយកម្ម : មានរយៈពេល ពិនិត្យ០៣ថ្ងៃ ហើយធ្វើការជាអគ្គនាយកដ្ឋានរងទទួលបន្ទុក ពិនិត្យទៅលើឯកសារគតិយុត្ត និងផ្តល់មតិលើលក្ខណៈ បច្ចេកទេសដើម្បីដាក់ជូនអគ្គនាយក និងជាអគ្គនាយកពិនិត្យ និង ផ្តល់យោបល់ជូនអនុរដ្ឋលេខាធិការ និងរដ្ឋលេខាធិការទទួលបន្ទុកដើម្បីផ្តល់មតិបន្ថែម ។
- រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការទទួលបន្ទុក : ពិនិត្យរយៈពេល ០៣ថ្ងៃ អនុរដ្ឋលេខាធិការ ទទួល ហើយបន្ទុកពិនិត្យ និងផ្តល់មតិយោបល់លើលក្ខណៈបច្ចេកទេសជូន រដ្ឋលេខាធិការ ។ ហើយរដ្ឋលេខាធិការពិនិត្យ និងផ្តល់មតិសំរាប់អគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនី យកម្ម ដាក់ជូនឯកឧត្តមទេសរដ្ឋ មន្ត្រីពិនិត្យ និងសំរេច ។
- នាយកដ្ឋាននគរូបនីយកម្ម : ពិនិត្យរយៈពេល ០១ថ្ងៃ ដោយមានភារៈកិច្ចជាអ្នកធ្វើមតិសំយោគ របស់អគ្គនាយកដ្ឋានទាំងពីរ និង ពង្រាងលិខិតអនុញ្ញាតសាងសង់ដាក់ឆ្លង អគ្គនាយកដ្ឋាន រៀបចំដែនដី និងនគរូបនីយកម្ម ពិនិត្យនិងចុះហត្ថលេខាសង្ខេប ។
- នាយកដ្ឋានស្រាវជ្រាវបទប្បញ្ញត្តិ : រយៈពេលពិនិត្យកន្លះថ្ងៃ សំរាប់ការចុះលេខចេញប្រថាប់ ត្រា និង បញ្ជូនទៅខុទ្ទកាល័យទេសរដ្ឋមន្ត្រី ។

នៅពេលដែលឯកសារទាំងអស់ បានបញ្ជូនទៅខុទ្ទកាល័យទេសរដ្ឋមន្ត្រី ពិនិត្យសំរេចក្នុង រយៈពេល ០២ថ្ងៃ ដោយពិនិត្យលើភាពគ្រប់គ្រាន់នៃឯកសារ ធ្វើកំណត់បង្ហាញរឿងដាក់ជូនឯក

ឧត្តមទេសរដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខាយល់ព្រម ឬក៏មិនយល់ព្រម ហើយប្រថាប់ត្រាទេសរដ្ឋមន្ត្រី បញ្ជូនទៅអគ្គនាយកដ្ឋានរដ្ឋបាលពិនិត្យក្នុងរយៈពេល ០១ថ្ងៃ ដោយចុះលេខចេញ ប្រគល់លិខិតអនុញ្ញាតសាងសង់ និងប្លង់ស្ថាបត្យកម្ម ក្នុងករណីយល់ព្រមត្រូវជូនទៅសាលាខេត្ត-ក្រុងវិញ។ រៀបចំរក្សានិង ប្រគល់លិខិតអនុញ្ញាតសាងសង់ និងប្លង់ទុកជាឯកសារនៅអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម ០១ច្បាប់ និងអគ្គនាយកដ្ឋានសំណង់ ០១ច្បាប់ ។ សាលាខេត្ត-ក្រុង ឬសាលារាជធានីភ្នំពេញ ក្រោយពេលបាន ទទួលបានលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបញ្ជូនទៅឱ្យម្ចាស់សំណើវិញ [35]។

២.២.២ សមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់

សមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតសាងសង់ ត្រូវពិនិត្យមើលគំរូប្លង់ស្ថាបត្យកម្ម និងឯកសារដែលភ្ជាប់មកជាមួយឲ្យបានជាក់លាក់ ជាពិសេសគឺទីតាំងនៃការសាងសង់ថា នៅទីកន្លែងណា និងជាប្រភេទសំណង់បែបណា ហើយសំណង់នោះអាចសាងសង់នៅតំបន់នោះ បានទេ? ដើម្បីកុំអោយប៉ះពាល់ដល់ប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លីព្រោះថាគ្មានលិខិតអនុញ្ញាតសាងសង់ណាមួយអាចចេញអោយបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាម ប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី ឬប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាតត្រូវ អនុវត្តតាមបទបញ្ជាទូទៅស្តីពីការអនុវត្តដីធ្លី។ សមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតសាងសង់គឺជា សមត្ថកិច្ចរបស់សាលារាជធានី ខេត្ត ក្រុង (២.២.២.១) និងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល (២.២.២.២) ។

២.២.២.១ សមត្ថកិច្ចរបស់សាលារាជធានី ខេត្ត-ក្រុង

សាលារាជធានី-ខេត្ត មានសមត្ថកិច្ចក្នុងការចេញ លិខិតអនុញ្ញាតសាងសង់ក្រោម ការទទួលខុសត្រូវរបស់ខ្លួន។ លិខិតអនុញ្ញាតសាងសង់ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានី ឬអភិបាលខេត្ត-ក្រុង ឬអភិបាលរងដែលទទួលសិទ្ធិប្រទាន។ ចំណែកការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរ និងមូលហេតុច្បាស់លាស់[36]។

២.២.២.២ សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលមានសមត្ថកិច្ច សំរេចផ្តល់លិខិតអនុញ្ញាតសាងសង់ ឱ្យដល់អ្នកស្នើសុំសំរាប់សំណង់ធំៗ ទាក់ទងនិងការធ្វើអាគារពាណិជ្ជកម្ម ជំនួញ សណ្ឋាគារជាដើម។ ហើយប្រភេទ

[35] សន្លឹកទី៦ នៃឧបសម្ព័ន្ធ២នៃសេចក្តីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

[36] មាត្រា ៤ នៃអនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

សំណង់ទាំងនោះរួមមាន បណ្តាអាគារឧបនិស្សៃ្ស យខាងពាណិជ្ជកម្ម និងឧស្សាហកម្មដែលមានក្រឡាផ្ទៃកម្រាលលើសពី ៣០០ម៉ែត្រ ទ្វេរគុណ រាល់សណ្ឋាគារត្រូវចាត់ទុកជាអាគារមានឧបនិស្សៃ្ស យខាងពាណិជ្ជកម្ម ហើយបណ្តាអាគារសំរាប់បង្កបង្កើតផលកសិកម្មសំរាប់ធ្វើអាជីវកម្មពី ៥.០០០ហិចតា ឡើងទៅ និងបណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម៉ុយយាន និងស្ថានីយរថយន្ត បណ្តាសំណង់សាធារណ: និងឯកជនដែលមានក្រឡាផ្ទៃលើសពី ៣.000 ម៉ែត្រ ទ្វេរគុណ (រឫធ្ងមិ អប់រំ កីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពលទឹក...) បណ្តា ប្រវត្តិ-សាស្ត្របុរាណវត្ថុ និងរឫធ្ងមិ ការកែប្រែបណ្តាអាគារជាផលប្រយោជន៍បេតិកភណ្ឌដែលបានកំណត់ទុក បណ្តាសំណង់ លើទឹកដីក្នុងភាពមើលឃើញទៅវិញទៅមកជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ បណ្តាសំណង់ និងការ្យសំរាប់ការពារ និងអាគារយោធា ។

រដ្ឋាភិបាលបានដាក់កំណត់បែបនេះ ព្រោះតែអាគារខាងលើនោះចាំបាច់ត្រូវតែដាក់ឱ្យរដ្ឋ-ភិបាលពិនិត្យឱ្យបានជាក់លាក់ ហើយម្យ៉ាងទៀតអាគារទាំងនោះជាប្រភេទអាគារធំ១តំរូវ ឱ្យមានការពិនិត្យយ៉ាងយកចិត្តទុកដាក់អំពីការសាងសង់ ភាពរឹងមាំនៃសំណង់ និងមាត្រដ្ឋាន ដែលរៀបចំចេញប្លង់ដោយស្ថាបត្យករ។ សំរាប់លិខិតអនុញ្ញាតសាងសង់ប្រភេទនេះត្រូវចុះ ហត្ថលេខាដោយប្រធានគណ:កម្មាធិការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បន្ទាប់ពីបានទទួលយោបល់ឯក-ភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ[37]។

រាល់បណ្តាម្ចាស់សំណង់នីមួយ១ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ថា លិខិតអនុញ្ញាតសាងសង់បានចេញ និងអនុញ្ញាតត្រឹមត្រូវរួចហើយ ចំនែកអ្នកកាន់លិខិតអនុញ្ញាតសាងសង់ត្រូវតម្កល់ទុកនៅការដ្ឋាន នូវសេចក្ដីចម្លងឯកសាររដ្ឋបាល ពីការចេញលិខិតអនុញ្ញាតសាងសង់មួយ ច្បាប់សំរាប់មន្ទីរក្រុង ឬខេត្តត្រួតពិនិត្យ ។ ប្លង់ស្ថាបត្យកម្ម និងប្លង់គ្រឿងផ្ទុំលំអិត សំណង់មួយច្បាប់១ ត្រូវតំកល់ទុកប្រចាំការដ្ឋាន និងសំរាប់មន្ទីរ ឬខេត្តត្រួតពិនិត្យ។ ក្រោយពី បានទទួលលិខិតអនុញ្ញាតសាងសង់ និងប្លង់លំអិតគ្រឿងផ្ទុំសំណង់ ហើយម្ចាស់សំណង់ត្រូវជូន ដំណឹងទៅសាលាស្រុក ខណ្ឌ និងចុះទិដ្ឋការនៅមន្ទីរមានសមត្ថកិច្ច ។

២.២.៣ ការសុំលិខិតបើកការដ្ឋាន

ការបើកការដ្ឋានអាចចាប់ផ្ដើមបានក្រោយពេលទទួលបានលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុញ្ញាតលើប្លង់លំអិតគ្រឿងផ្ទុំសំណង់ដែលបានពិនិត្យដោយ ក្រសួងសាធារណ:ការដឹកជញ្ជូន ។ ការសុំលិខិតអនុញ្ញាតបើកការដ្ឋានគឺជាតួនាទីរបស់ម្ចាស់ សំណង់ក្នុងការដាក់ពាក្យស្នើសុំ ។ ដោយការអភិវឌ្ឍន៍លំនៅឋាន គឺជាការដ្ឋានសំណង់ថ្មី (ព្រោះជាគម្រោង

[37] មាត្រា ៧នៃអនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់

សាងសង់សម្រាប់លក់) ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតសាងសង់ពីសាលា រាជធានី ឬ សាលាខេត្ត-ក្រុង បញ្ជាក់ពីភាពរឹងមាំនៃសំណង់ ប្លង់សំណង់ទុកប្រចាំនៅការដ្ឋាន អចិន្ត្រៃយ៍ និង មានកិច្ចសន្យាទទួលសាងសង់ពីក្រុមហ៊ុន ឬពីសហគ្រាសសាងសង់ណាដែល ទទួលស្គាល់ដោយ ច្បាប់ភ្ជាប់ទៅជាមួយ ។ រាល់ការសាងសង់ទាំងអស់អាចធ្វើទៅបាន ទាល់តែមានការអនុញ្ញាតឱ្យ បើកការដ្ឋាន និងទទួលបទបញ្ជាស្តីពីការរៀបចំការដ្ឋាន ។

របៀបនៃការដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋានម្ចាស់សំណង់ ឬម្ចាស់សំណើរជា អ្នក ដាក់ពាក្យសុំនេះត្រូវធ្វើតាមបរិបថពីរ គឺការដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាននៅ មន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង (២.២.៣.១) និងការដាក់ពាក្យសុំលិខិត អនុញ្ញាតបើកការដ្ឋាន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២.២.៣.២) ។

២.២.៣.១ការដាក់ពាក្យសុំលិខិតបើកការដ្ឋានៅ មន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង

ចំពោះម្ចាស់សំណង់ ដែលបានរៀបចំគម្រោងអភិវឌ្ឍលំនៅឋាន នៅតាមបណ្តាខេត្ត-ក្រុង អាចដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋានបាន ហើយការដាក់ពាក្យសុំនេះត្រូវចំនាយពេល យ៉ាងយូរ ០៦ថ្ងៃ។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងទទួលការ ដាក់ពាក្យសុំរបស់ម្ចាស់សំណើ ហើយនឹងពិនិត្យនូវរាល់ឯកសារដែលពាក់ពន្ធ័ ក៏ដូចជាពិនិត្យទៅ លើបច្ចេកទេសនៃ ការសាងសង់ទៅតាមផ្នែកនីមួយៗផងដែរ ដើម្បីសម្រេចចេញលិខិតអនុញ្ញាត បើកការដ្ឋាន គឺមាន ៦ ដំណាក់កាលទៅតាមផ្នែកនីមួយៗដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល : ជាអ្នកត្រួតពិនិត្យលក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវតាម តារាងត្រួតពិនិត្យ ចុះលេខចូល និងបោះត្រាចូល ចុះហត្ថលេខាបង្រួម និងចេញ បង្ហាន់ដៃ (បើឯកសារគ្រប់គ្រាន់) បញ្ជូនសំណុំឯកសារទៅអនុប្រធានមន្ទីរទទួល បន្ទុកការងាររដ្ឋបាល ។
- អនុប្រធានមន្ទីរទទួលបន្ទុករដ្ឋបាល : គឺជាអ្នកចំណារបញ្ជូនទៅអនុប្រធានមន្ទីរ ទទួល ការងារសំណង់ ឬទទួលបន្ទុកការងារដែនដី នគរូបនីយកម្ម។
- ការិយាល័យសំណង់ ឬការិយាល័យដែនដីនគរូបនីយកម្ម : ជាអ្នកត្រួតពិនិត្យសំណុំ ឯកសារនិងបំពេញនូវបែបបទបើកការដ្ឋាន ពិនិត្យប្លង់គ្រឿងផ្ទុំសំណង់ ចុះបោះ បង្គោល ដោយសហការជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រ ស្រុក-ខណ្ឌ រៀបចំលិខិតបើកការដ្ឋានសាងសង់ និងរូបថតជាក់ ស្តែងនៅការដ្ឋានសាងសង់ ។

- អនុប្រធានមន្ទីរទទួលបន្ទុកសំណង់ : ជាអ្នកពិនិត្យសំណុំឯកសារស្នើសុំបើកការដ្ឋាន សាងសង់ ពិនិត្យលើលិខិតស្នើសុំបើកការដ្ឋានសាងសង់ និងចុះហត្ថលេខាបង្រួមលើលិខិត បើកការដ្ឋានសាងសង់ ។
- ប្រធានមន្ទីរ : ពិនិត្យសំណុំឯកសារបើកការដ្ឋានសាងសង់ និងចុះហត្ថលេខាលើលិខិត បើកដ្ឋានសាងសង់ ។
- ការិយាល័យរដ្ឋបាល : គឺជាអ្នកវាយត្រាចេញ និងចុះលេខចេញ បញ្ជូនទៅម្ចាស់សំណើរ។

ក្រោយពីទទួលបានលិខិតអនុញ្ញាតបើកការដ្ឋាន ម្ចាស់សំណង់អាចយកទៅតម្កល់នៅមុខទីតាំងនៃការដ្ឋានរបស់ខ្លួន ហើយនិងអាចដំណើរការដ្ឋាន ដែលមានវិស្វករជំនាញជាអ្នកអនុវត្តការសាងសង់[38]។

២.២.៣.២ ការដាក់ពាក្យសុំបើកការដ្ឋានៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ចំពោះម្ចាស់ ដែលបានរៀបចំគម្រោងអភិវឌ្ឍលំនៅឋាន នៅក្នុងរាជធានីភ្នំពេញ វិញនោះអាចដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាននៅនាយកដ្ឋានសំណង់ នៃអគ្គនាយកដ្ឋានសំណង់បាន ហើយការដាក់ពាក្យសុំនេះ ត្រូវចំនាយរយៈពេលយ៉ាងយូរ ០៨ថ្ងៃ ។ ចំពោះការពិនិត្យ និង សំរេចលើការសុំនេះមាន ៨ ដំណាក់កាលតាមផ្នែកនីមួយៗដូចខាងក្រោម ៖

- ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យ : ជាអ្នកត្រួតពិនិត្យលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមតារាងត្រួតពិនិត្យ ចុះលេខចូល និងបោះត្រាចេញ ចុះហត្ថលេខា បង្រួមចេញ បង្កាន់ដៃ (បើឯកសារគ្រប់គ្រាន់) បញ្ជូនទៅថ្នាក់ដឹកនាំនាយកដ្ឋាន ។
- ថ្នាក់ដឹកនាំនាយកដ្ឋាន : ជាអ្នកត្រួតពិនិត្យសំណុំឯកសារ ធ្វើមូលវិចារបញ្ជូនទៅការិយាល័យបច្ចេកទេស និងត្រួតពិនិត្យដើម្បីមុខការ ។
- ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យ : គឺត្រួតពិនិត្យសំណុំឯកសារពាក្យស្នើសុំ លិខិតអនុញ្ញាតបើកការដ្ឋាន ចុះត្រួតពិនិត្យ ចុះវាស់វែង និងចុះបង្គោលកំណត់ព្រំដល់ការដ្ឋានសាងសង់ ពិនិត្យកិច្ចសន្យារវាងម្ចាស់សំណង់ និងអ្នកមៅការសាងសង់ ។
- នាយកដ្ឋានសិក្សាគម្រោងប្លង់ : ជាអ្នកត្រួតពិនិត្យពាក្យស្នើសុំ និងពិនិត្យប្លង់គ្រឿងផ្ទុំសំណង់។

[38] សេចក្តីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់

- លោកអគ្គនាយករង : ធ្វើការត្រួតពិនិត្យ និងមានមូលវិចារលើកំណត់បង្ហាញសំណុំរឿងរួចបញ្ជូនទៅឯកឧត្តមអគ្គនាយក ។
- ឯកឧត្តមអគ្គនាយក : ធ្វើការត្រួតពិនិត្យ និងមានមូលវិចារលើកំណត់បង្ហាញសំណុំ រឿងរួចបញ្ជូនទៅឯកឧត្តមអនុរដ្ឋលេខាធិការ ។
- ឯកឧត្តមអនុរដ្ឋលេខាធិការ : ធ្វើការត្រួតពិនិត្យ និងមានមូលវិចារលើកំណត់បង្ហាញ សំណុំ រឿងរួចបញ្ជូនទៅឯកឧត្តមអគ្គនាយក ដើម្បីចុះហត្ថលេខាលើលិខិតអនុញ្ញាតបើកការដ្ឋាន។
- នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ : វាយត្រាចេញ និងចុះលេខចេញ ហើយបញ្ជូនទៅម្ចាស់សំណើរ[39]។

២.២.៣.៣ ការរៀបចំបើកការដ្ឋាន

នៅពេលចាប់ផ្តើមដំណើរការបើកការដ្ឋានសំណង់ អាចនឹងកើតមានផលប៉ះពាល់ដល់បរិស្ថានដែលនៅជុំវិញការដ្ឋាននោះ។ ប្រសិនបើការដ្ឋាននោះមានទីតាំង នៅតំបន់ទីប្រជុំជន និងអាចធ្វើឱ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដូចជាធ្វើចរាចរដោយរថយន្ត ឬ ម៉ូតូ ឬដោយថ្មើរជើងជាដើម ដើម្បីជៀសវាងនូវបញ្ហាដែលនាំឱ្យទីក្រុង ឬភូមិរបស់ប្រជាជនរងនូវ ការប៉ះពាល់ម្ចាស់សំណង់ និងអ្នកមៅការសំណង់ត្រូវតែមានវិធានការចូលរួម សហការណ៍គ្នា រៀបចំការដ្ឋានរបស់ខ្លួនឱ្យបានល្អ ។

រាល់ការដ្ឋានសាងសង់ទាំងអស់ ម្ចាស់ប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានត្រូវរៀបចំការ ដ្ឋានឱ្យមានសណ្តាប់ធ្នាប់ និងសំរាប់ការដាក់គរសំភារៈសំណង់នៅលើផ្លូវសាធារណៈត្រូវបាន ហាមឃាត់។ ការដាក់គរសំភារៈសំណង់លើផ្លូវសាធារណៈត្រូវហាមឃាត់ កាលណាសំណង់ត្រូវការ កន្លែងតាំងការដ្ឋានលយទៅលើផ្លូវសាធារណៈកន្លែងលយនោះ ត្រូវកំណត់ត្រឹម ២ម៉ែត្រ ទៅលើ ចិញ្ចើមផ្លូវ ។ កន្លែងនោះត្រូវហ៊ុំពទ្ធ័ក្នុងរយៈពេលដំណើរការរបស់ការដ្ឋាន។ រាល់ការតាំងការដ្ឋានត្រូវរុះរើចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយចប់ការដ្ឋាន។ គំនរសំភារៈកាកសំណល់បានមក ពីការសាងសង់ ឬការជួសជុលត្រូវយកចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការងារ។ ក្នុងករណីពុំបានរើយកសំភារៈកាកសំណល់ចេញពីកន្លែងតាំងការដ្ឋានទេ សាលាខណ្ឌ ឬសាលាក្រុងមានកាតព្វកិច្ចចាត់ចែងដឹកជញ្ជូនចេញដោយស្វ័យប្រវត្តិ។ ចំនែកចំណាយជាបន្ទុករបស់ម្ចាស់សំណង់[40]។ ក្រៅពីនេះចំពោះអាគារដែលមានកំពស់លើសពី ៤ម៉ែត្រ ម្ចាស់សំណង់និង អ្នកមៅការសំណង់ ត្រូវធ្វើ

[39] សេចក្តីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការត្រួតពិនិត្យនិងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

[40] មាត្រា ១៩ នៃអនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

រនាំងបាំងជុំវិញដើម្បីការពារសម្ភារៈសំណង់ និងកំទេចសម្ភារៈ ការហ៊ុយ ធូលីដីបានមួយផ្នែកតូច ដែលអាចជួយកាត់បន្ថយការប៉ះពាល់បរិស្ថានជុំវិញទីតាំងការដ្ឋាននោះបានដែរ [41] ។ ចំពោះកន្លែងតាំងការដ្ឋានសាងសង់ ម្ចាស់សំណង់ត្រូវធ្វើកិច្ចសន្យាហ៊ុំពទ្ធ័ការដ្ឋានក្នុង រយៈពេលដំណើរការរបស់ការដ្ឋាន ។

២.២.៤ ការសុំបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់សម្គាល់សំណង់ត្រឹមត្រូវ

បន្ទាប់ពីធ្វើការសាងសង់រួចរាល់ជាស្ថាពរ បុគ្គលអភិវឌ្ឍលំនៅឋាន ប្រភេទ ១ និងប្រភេទ ២ ត្រូវធ្វើរបាយការណ៍បញ្ជាក់ពីការបញ្ចប់គម្រោងសាងសង់រួចរាល់ហើយ ម្ចាស់គម្រោងអភិវឌ្ឍលំនៅឋាន ត្រូវតែធ្វើការស្នើសុំលិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្រសម្គាល់ ភាពត្រឹមត្រូវនៃសំណង់ទៅមន្ទីរ ឬក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអោយមន្ត្រី មានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យពីភាពត្រឹមត្រូវនៃសំណង់ធៀបទៅតាមប្លង់ស្ថាបត្យកម្ម នៃម្ចាស់គម្រោងដែលបានផ្តល់ទៅឱ្យមន្ទីរ និងក្រសួងធ្វើការសម្រេចផ្តល់ជូនឱ្យលិខិត អនុញ្ញាតបិទការដ្ឋាននោះហើយទើបអាចធ្វើការប្រកាសលក់លំនៅឋានបានដោយស្របតាមការ កំណត់របស់ច្បាប់ ។

២.២.៥. សហគ្រាស ក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ និងក្រុមជាងសាងសង់

បន្ទាប់ពីបានទទួលលិខិតអនុញ្ញាតសាងសង់ ម្ចាស់សំណង់អាចយកលិខិតអនុញ្ញាតសាងសង់ដើម្បីចាប់ផ្តើមដំណើរការបើកការដ្ឋានសាងសង់របស់ខ្លួនបាន ហើយម្ចាស់សំណង់ត្រូវតែឲ្យឬមានការចូលរួមត្រួតពិនិត្យពីអាជ្ញាធរ ដើម្បីអោយមានការសាងសង់លក្ខណៈត្រឹមត្រូវ។ ម្យ៉ាងទៀតនៅក្នុងការសាងសង់ម្ចាស់សំណង់ មានសិទ្ធិជ្រើសរើសនូវសហគ្រាស ក្រុមហ៊ុនសិក្សា គំរោងប្លង់ និងសាងសង់ និងក្រុមជាងសំណង់ត្រូវតែមានលិខិតបើកការដ្ឋាន ទើបអាចចាប់ផ្តើម ការងាររបស់ខ្លួនបាន ។

ម្យ៉ាងទៀត ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់ៈ ១ ១ ១

២.២.៥.១ សមត្ថកិច្ចផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្ម

ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ គឺជាអ្នកមានសមត្ថកិច្ចក្នុងការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ និងក្រុមជាងសំណង់ទាំងអស់ ។ ចំពោះការបើក បិទ ផ្អាក តាមដាន និងត្រួតពិនិត្យសកម្មភាពប្រកបអាជីវកម្មរបស់សហគ្រាស ក្រុមហ៊ុនសិក្សាគំរោង ប្លង់ និងសាងសង់វិញ ត្រូវបានកំនត់ផងដែរ នូវសមត្ថកិច្ចរវាងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង ។ ប៉ុន្តែបើយើងត្រួតពិនិត្យជារួមវិញ គឺជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរគ្រាន់តែជាអ្នកសំរបសំរួល និងលើកសំណើរ អោយក្រសួងតែប៉ុណ្ណោះ ហើយសហគ្រាស ឬក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់បានចែកជាពីរដែលមាននៅក្នុងការបែងចែកជាផ្នែកតូចៗបន្តទៀត ។

ចំនែកឯប្រធានសហគ្រាស ក្រុមហ៊ុន និងអ្នកបច្ចេកទេសនៃក្រុមហ៊ុន គឺត្រូវតែមានសញ្ជាតិខ្មែរ ហើយត្រូវយកពាក្យសុំវិញ្ញាបនបត្រប្រកបអាជីវកម្ម មកដាក់ដោយខ្លួនឯង (ប្រធាន) ហើយត្រូវ បំពេញនូវសំណុំឯកសារពាក់ពន្ធ័មួយចំនួនទៀតដូចជា៖

- ពាក្យសុំប្រកបអាជីវកម្ម
- ជីវប្រវត្តិរបស់ប្រធានសហគ្រាស និងក្រុមហ៊ុននិងនាយកបច្ចេកទេស
- ច្បាប់ចំលងអត្តសញ្ញាណបណ្ណរបស់ប្រធានសហគ្រាស និងក្រុមហ៊ុនដែលបានធ្វើនីតានុកូលកម្មនៅសាលាខេត្ត ក្រុង
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- បង្ហាន់ដីពន្ធអាករ និងលិខិតថ្លៃលទោសរបស់ប្រធានសហគ្រាស និងក្រុមហ៊ុនមួយចំនួន ។
- កិច្ចសន្យាការងាររវាង សហគ្រាស និងក្រុមហ៊ុនជាមួយអាជ្ញាធរមានសមត្ថកិច្ច ផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្ម និងជាមួយវិស្វករដែលជានាយកបច្ចេកទេស
- ឯកសារធនាគារ និងលក្ខន្តិក:របស់ សហគ្រាស និងក្រុមហ៊ុនទាំងពីរ ។

មិនតែប៉ុណ្ណោះសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ អាចសុំតម្លើងហាន:របស់ខ្លួនបាន ក្នុងករណីដែលសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់មានលក្ខណ:សម្បត្តិគ្រប់គ្រាន់ តាមការកំណត់ហើយត្រូវមានលិខិតបញ្ជាក់ពីការបង់ប្រាក់ជូនរដ្ឋទៀតផង ។

២.២.៥.២ សមត្ថកិច្ចទទួលពាក្យសុំវិញ្ញាបនបត្រប្រកបអាជីវកម្ម

ចំពោះការគ្រប់គ្រងទៅលើសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ គឺនៅក្នុងប្រកាសក៏ បានធ្វើការបែងចែករវាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសមត្ថកិច្ចរបស់ មន្ទីរ

រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយាដីខេត្តក្រុងទាក់ទងនឹងការទទួលពាក្យសុំវិញ្ញាបនបត្រប្រកបអាជីវកម្ម របស់សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងនិងសាងសង់ទាំងអស់ ដែលមានបំណងចង់ប្រកបអាជីវកម្មត្រូវដាក់ពាក្យនៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ។

ចំនែកឯកសារបវន្តបុគ្គល និងក្រុមជាងសំណង់វិញ ត្រូវដាក់ពាក្យនៅមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយាដីខេត្ត-ក្រុង ។

ម្យ៉ាងវិញទៀតការកំណត់នេះក៏មានអានុភាពទៅលើសហគ្រាស ឬក្រុមហ៊ុនសិក្សាគំរោងប្លង់ ឬ រូបវន្តបុគ្គល និងក្រុមជាងសំណង់ ដែលពីមុនធ្លាប់ទទួលបានលិខិតអនុញ្ញាតពីស្ថាប័នផ្សេងៗនោះក៏ ត្រូវមកដាក់ពាក្យប្តូរយកវិញ្ញាបនបត្រថ្មីវិញពី អាជ្ញាធរមានសមត្ថកិច្ចទើបអាចបន្តការងាររបស់ខ្លួន ដោយស្របច្បាប់ទៀតបាន ។

២.២.៥.៣ សមត្ថកិច្ចចុះបញ្ជីប្រកបអាជីវកម្ម

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកទទួលបន្ទុកចុះបញ្ជីរាល់សហគ្រាស និង ក្រុមហ៊ុនបរទេសតែបើតាមការស្ទើបអង្កេតឃើញថា សមត្ថកិច្ចហាក់ដូចជាតម្រូវតែលើរាល់សហគ្រាស និងក្រុមហ៊ុនបរទេសទាំងឡាយណាដែលមានបំណងចង់ប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬផ្ត្រល់ យោបល់ពិគ្រោះបច្ចេកទេស និងសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។ កាតព្វកិច្ច នេះក៏មានអានុភាពអនុវត្តរាល់សហគ្រាស និងក្រុមហ៊ុនបរទេស ដែលមានអនុញ្ញាតប្រកប អាជីវកម្មពីស្ថាប័នផ្សេងៗ ហើយកំពុងតែប្រកបអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ត្រូវចុះបញ្ជីប្រកប អាជីវកម្មសារជាថ្មីនៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ដែរ។ ម្យ៉ាងទៀតរាល់ការចុះបញ្ជីការ ចេញលិខិតអនុញ្ញាត សហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ រូបវន្តបុគ្គល និងក្រុមជាងសំណង់ត្រូវតែបង់ពន្ធអាករផ្សេងៗស្របតាមការកំណត់ នៃសហគ្រាស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី៣

ភាពព្យាកិច្ចនៅពេលប្រតិបត្តិ

ការអាជីវកម្ម

និង ការដោះស្រាយវិវាទ

ជំពូកទី៣

កាតព្វកិច្ចនៅពេលប្រតិបត្តិការអាជីវកម្ម និង ការដោះស្រាយវិវាទ

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានគឺជា ក្រុមហ៊ុនមួយដែលធ្វើសកម្មភាពពាណិជ្ជកម្មឬវិនិយោគគ្រប់ប្រភេទដែលមានកម្មវត្ថុជាការសាងសង់លំនៅឋានសម្រាប់លក់ ដើម្បីស្វែងរកផលចំនេញ។ ចំពោះលំនៅឋានទាំងនោះ គឺសំដៅដល់សំណង់ក្រោមទម្រង់ជាផ្ទះល្វែង អាគារសហកម្មសិទ្ធិ ភូមិគ្រឹះគ្រប់ប្រភេទ និងសំណង់ផ្សេងៗទៀតដែលមានគោលដៅបម្រើដល់ការស្នាក់នៅ។ ក្រោយពេលក្រុមហ៊ុនអភិវឌ្ឍលំនៅឋានទទួលបានអាជ្ញាបណ្ណដើម្បី ប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងទទួល បាននូវលិខិតអនុញ្ញាតសាងសង់ពីក្រសួងដែនដីនគរូបនី-យកម្ម និងសំណង់ហើយ ក្រុមហ៊ុនក៏ចាប់ផ្តើមមាន កាតព្វកិច្ចនៅពេលប្រតិបត្តិការអាជីវកម្ម (៣.១) ហើយនៅក្នុងអំឡុងពេលនៃការ ចាប់ផ្តើមដំណើរអាជីវកម្មនេះយើងសង្កេតឃើញថា តែងមានវិវាទ ឬក៏អំពើបំពានទៅ លើការប្រកបអាជីវកម្មនេះផងដែរ ដូច្នេះហើយទើបប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន ក៏បានកំនត់អំពី ការដោះស្រាយវិវាទ (៣.២) ទៅលើបញ្ហាខាងលើនេះ ។

៣.១ កាតព្វកិច្ចនៅពេលប្រតិបត្តិការអាជីវកម្ម

ដើម្បីងាយស្រួលដល់ការគ្រប់គ្រងនិងត្រួតពិនិត្យលើអាជីវកម្មអភិវឌ្ឍលំនៅឋាន ក៏ដូចជាធានាដល់ផលប្រយោជន៍រវាងក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអ្នកប្រើប្រាស់ [42] ហើយនឹងទប់ ស្កាត់ដល់ហានិភ័យណាមួយដែលអាចកើតមានទៅលើវិស័យអាជីវកម្មអភិវឌ្ឍលំនៅឋាននេះ ទើបក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុបាន សម្រេចចេញសេចក្តីប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។ ក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានត្រូវគោរពទៅតាមគោលការណ៍ក៏ដូចជាកាតព្វកិច្ចផ្សេងៗទៅតាមសេចក្តីប្រកាសខាងលើនេះ ដែលមានខ្លឹមសារដូចខាងក្រោម ៖

៣.១.១ កាតព្វកិច្ចជំហ៊ីងរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

ប្រការ១៤ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន បានកំនត់ថា ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានមានកាតព្វកិច្ចដូចខាងក្រោម ៖

- ត្រូវប្រកាសប្រាប់អ្នកទិញលំនៅឋានអំពីប្រភេទក្បាលដីដែលខ្លួនបានសាងសង់ថាជាក្បាលដី កម្មសិទ្ធិរបស់ខ្លួន ឬក្បាលដីជួលអចិន្ត្រៃយ៍ពីអ្នកដទៃ ឬក្បាលដីជាប់បន្ទុកផ្សេងៗ

[42] សំដៅលើ អតិថិជន ឬអ្នកទិញលំនៅឋាន ពីក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

- ត្រូវទទួលខុសត្រូវចំពោះអ្នកទិញលំនៅឋានពាក់ពន្ធ័ទៅ នឹងសំណង់លំនៅឋានដែលខ្លួនបានលក់ព្រមទាំងក្នុងករណីអចលនវត្ថុដែលជាកម្មវត្ថុនៃការអភិវឌ្ឍន៍ ត្រូវបានជាប់បន្ទុកជាអាទ៍ ៖ ការរិតត្បិត, សិទ្ធិឃាត់ទុក, ការបញ្ចាំ, ហ៊ីប៉ូតែក, ការដាក់ធានា ឬវិវាទដែលកំពុងដំណើរការ ឬការផ្ទាកបណ្តោះអាសន្នណាមួយ
- ត្រូវអនុវត្តទៅតាមស្តង់ដារនៃកិច្ចសន្យាលក់-ទិញលំនៅឋាន
- ត្រូវអនុវត្តទៅតាមកាលវិភាគបង់ប្រាក់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ
- ត្រូវបំពេញកាតព្វកិច្ចឲ្យបានចប់សព្វគ្រប់ ដូចមានចែងក្នុងកិច្ចសន្យាលក់-ទិញលំនៅឋានជា មួយអ្នកទិញលំនៅឋាន
- ត្រូវផ្តល់របាយការណ៍ឲ្យបានទៀងទាត់ និងទាន់ពេល ។

៣.១.២ ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីគម្រោងអភិវឌ្ឍលំនៅឋាន

ការផ្សព្វផ្សាយពាណិជ្ជកម្មគឺ ដៅដល់ការផ្សព្វផ្សាយពត៌មានតាមរយៈមធ្យោបាយផ្សព្វផ្សាយសាធារណៈ ឬឯកជនផ្សេងៗទៀត ដើម្បីជួនដំណឹងឬបញ្ជុះបញ្ចូលអ្នកទិញលំនៅឋាន ឬសាធារណជនក្នុងការទិញលំនៅឋានរបស់ក្រុមហ៊ុនប្រកបអជីវកម្មអភិវឌ្ឍលំនៅឋាន [43] ។ ក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មអំពីគម្រោងអភិវឌ្ឍលំនៅឋានតាមគ្រប់រូបភាព ត្រូវបានហាមឃាត់ ចំពោះបុគ្គលណាដែលពុំទាន់ទទួលបានអាជ្ញាបណ្ណពីក្រសួង។ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ១ និងប្រភេទ ២ អាចធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មបាន[44]។ ហេតុដូច្នេះ ដើម្បីធ្វើការផ្សព្វផ្សាយបាន ក្រុមហ៊ុនត្រូវធ្វើទៅតាម (១.២.១) លក្ខខណ្ឌនៃការផ្សព្វផ្សាយ និង(១.២.២)ការទទួលខុសត្រូវ លើការផ្សព្វផ្សាយពាណិជ្ជកម្ម ដូចខាងក្រោម ៖

៣.១.២.១ លក្ខខណ្ឌនៃការផ្សព្វផ្សាយ

លក្ខខណ្ឌនៃការផ្សព្វផ្សាយពាណិជ្ជកម្ម អំពីគម្រោងអភិវឌ្ឍលំនៅឋានរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានធ្វើឡើងយ៉ាងទូលំទូលាយទៅតាមប្រពន្ធ័ផ្សព្វផ្សាយផ្សេងៗ ដែលមានក្នុងសង្គមបច្ចុប្បន្នដូចជាកាសែត ទស្សនាវដ្ដី វិទ្យុ ឬទូរទស្សន៍ជាដើម ។ ចំពោះការផ្សព្វផ្សាយពាណិជ្ជកម្ម ត្រូវបង្ហាញនូវពត៌មានអប្បបរមាមួយចំនួនដូចខាងក្រោម៖

- ទីតាំងគម្រោង
- អាជ្ញាបណ្ណ៍អភិវឌ្ឍលំនៅឋាន
- ឈ្មោះគម្រោងអភិវឌ្ឍលំនៅឋាន

[43] ប្រការ ៤ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍ លំនៅឋាន

[44] ប្រការ ១៦ នៃប្រកាសដដែល

- តម្លៃនៃប្រភេទលំនៅឋាននីមួយៗដែលត្រូវលក់
- កាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់នៃគម្រោងអភិវឌ្ឍលំនៅឋាន
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ។ ប្រសិនបើអចលនវត្ថុនោះ ត្រូវបានជួលពីរដ្ឋ ឬ ឯកជន ត្រូវបង្ហាញអំពីកាលបរិច្ឆេទផុតកំណត់ នៃការជួលនោះ [45]។

៣.១.២.២ ការទទួលខុសត្រូវលើការផ្សព្វផ្សាយ

រាល់ការផ្សព្វផ្សាយរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវតែទទួលខុសត្រូវដោយខ្លួនឯងផ្ទាល់ចំពោះមុខច្បាប់ប្រសិនបើ ក្រុមហ៊ុនបានល្មើសទៅលើការផ្សព្វផ្សាយណាមួយដែលច្បាប់បានហាមឃាត់ ។ ការផ្សព្វផ្សាយពាណិជ្ជកម្ម ដែលមានលក្ខណៈជាការឆបោក ឬនាំឲ្យមានការយល់ខុស ឬធ្វើឲ្យ មានផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ត្រូវបានហាមឃាត់ និងត្រូវទទួលពិន័យដូចមាន ចែងក្នុងប្រការ ៤២នៃប្រកាសស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន និងបទប្បញ្ញត្តិពាក់ពន្ធ័ផ្សេងៗទៀតជាធរមាន ។

៣.១.៣ កិច្ចសន្យាលក់-ទិញលំនៅឋាន

ចំពោះអាជ្ញាបណ្ណដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយផ្តល់ជូនឲ្យក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដើម្បីប្រកបអាជីវកម្មរបស់ខ្លួនបានគឺមាន ២ប្រភេទរួមមាន អាជ្ញាបណ្ណប្រភេទ ១ និងអាជ្ញាបណ្ណប្រភេទ ២ ហេតុនេះហើយចំពោះកិច្ចសន្យាលក់-ទិញលំនៅឋានក៏ប្រព្រឹត្តទៅខុសគ្នាតាមប្រភេទអាជ្ញាបណ្ណដែរ។ អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋានទាំងពីរប្រភេទនេះត្រូវបានកំណត់ នៅក្នុងប្រការ ៧ នៃប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋានចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦។ ការចុះកិច្ចសន្យាលក់-ទិញលំនៅឋាន ត្រូវបានអនុញ្ញាតចំពោះតែក្រុមហ៊ុនអភិវឌ្ឍលំនៅឋានណា ដែលជាម្ចាស់កម្មសិទ្ធិលើដីធ្លីគម្រោង អភិវឌ្ឍលំនៅឋាននោះ តែប៉ុណ្ណោះ ។ ចំពោះក្រុមហ៊ុនអភិវឌ្ឍលំនៅឋានណា ដែលជាម្ចាស់កម្មសិទ្ធិ លើដីធ្លី អាចចុះកិច្ចសន្យាលក់-ទិញបាន លុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីម្ចាស់ កម្មសិទ្ធិលើដីធ្លីនោះស្របទៅតាមនីតិវិធីច្បាប់ជាធរមាន[46]។ ដូចនេះកិច្ចសន្យានៃការលក់-ទិញលំនៅឋានរវាងក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន និងអ្នកប្រើប្រាស់ប្រព្រឹត្តទៅតាមលក្ខខណ្ឌដែលច្បាប់បានកំនត់ មានដូចជា កិច្ចដំណើរការប្រតិបត្តិការលក់-ទិញ (៣.១.៣.១) និងការបំពេញលក្ខខណ្ឌលក់-ទិញ (៣.១.៣.២)។

[45] ប្រការ ១៧ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍ លំនៅឋាន

[46] ប្រការ ២២ ប្រកាសដដែល

៣.១.៣.១ ការប្រតិបត្តិការលក់-ទិញ

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ១ អាចដំណើរការប្រតិបត្តិការលក់-ទិញបាន លុះត្រាតែក្រុមហ៊ុនបានបញ្ចប់ការសាងសង់គម្រោង ជាស្ថាពរដែលមានការបញ្ជាក់ ដោយលិខិតបិទការដ្ឋាន និង/ឬមានការវាយតម្លៃពីមន្ត្រីជំនាញរបស់នាយកដ្ឋានជាមុន[47]។ ចំនែកក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ ២ អាចដំណើរការប្រតិបត្តិការលក់-ទិញបាន លុះត្រាតែក្រុមហ៊ុនមានលិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ។ នៅពេលដែលមិនទាន់ទទួលបានលិខិតអនុញ្ញាតសាងសង់ ក្រុមហ៊ុនមានសិទ្ធិទទួល ត្រឹមតែប្រាក់កក់ដំបូងយ៉ាងច្រើន ១% នៃតម្លៃលក់ពីអ្នកទិញលំនៅឋានតែប៉ុណ្ណោះ។ ប្រាក់កក់ដំបូង នេះត្រូវទុកនៅក្នុងគណនីអភិវឌ្ឍលំនៅឋាន និងមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ រហូតដល់ទទួល បានលិខិតអនុញ្ញាតសាងសង់។ ក្នុងករណីមិនទទួលបានលិខិតអនុញ្ញាតសាងសង់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវប្រគល់ប្រាក់កក់ដំបូងនេះជូនអ្នកទិញលំនៅឋានវិញទៅតាមលក្ខខណ្ឌកំណត់របស់គូភាគី [48]។

៣.១.៣.២ ការបំពេញលក្ខខណ្ឌលក់-ទិញ

ប្រការ២១ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវ-កម្មអភិវឌ្ឍលំនៅឋាន បានចែងថា ក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន ត្រូវរៀបចំកិច្ចសន្យាលក់-ទិញជាមួយអ្នកទិញលំនៅឋានដោយ ត្រូវបំពេញលក្ខខណ្ឌឲ្យបានច្បាស់លាស់នូវពត៌មានអប្បបរមាមួយចំនួនដូចខាងក្រោម ៖

- ឈ្មោះរបស់អ្នកលក់ និងឈ្មោះរបស់អ្នកទិញលំនៅឋាន ដោយបញ្ជាក់អំពីអត្តសញ្ញាណ និង អាស័យដ្ឋានរបស់ភាគីទាំងពីរឲ្យបានច្បាស់លាស់ និងមានសាក្សីដឹងឮ
- ទីតាំង ទំហំដី ទំហំសំណង់ និងតម្លៃលក់-ទិញដែលបានព្រមព្រៀងគ្នា
- កាតព្វកិច្ចរបស់ភាគីដែលទទួលបន្ទុកបង់ពន្ធប្រថាប់ត្រា និងបង់កម្រៃសេវាផ្សេងៗទៀត
- កាលបរិច្ឆេទគម្រោង
- ឈ្មោះ ទីតាំងរបស់ធនាគារ និងលេខគណនីអភិវឌ្ឍលំនៅឋាន ដែលក្រុមហ៊ុនត្រូវបើកតាមប្រការ ២៥ នៃប្រកាសនេះ (ចំពោះក្រុមហ៊ុនអាជ្ញាបណ្ណប្រភេទ២)
- នីតិវិធី និងកាលវិភាគបង់ប្រាក់រួមមាន រយៈពេលនៃការបង់ប្រាក់ដំបូងនិងការបង់រំលស់ បន្ត បន្ទាប់

[47] ប្រការ១៩ ប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍ លំនៅឋាន

[48] ប្រការ២០ ប្រកាសដដែល

- កាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យា ក្នុងករណីយឺតយ៉ាវក្នុងការបង់ប្រាក់ និងយឺតយ៉ាវក្នុងការសាងសង់
- សិទ្ធិក្នុងការរំលាយកិច្ចសន្យា
- ការធានាខុសត្រូវលើគុណភាព និងសុវត្ថិភាពសំណង់
- ប្រសិនបើដីអភិវឌ្ឍលំនៅឋាននោះ ជាដីជួលពីរដ្ឋ ឬឯកជនត្រូវបញ្ជាក់អំពីរយៈពេលដែលអ្នកទិញលំនៅឋានមានសិទ្ធិកាន់កាប់លើលំនៅឋាន សិទ្ធិលើដីនោះ និងអំពីថ្ងៃខែចាប់ផ្តើម និង ថ្ងៃខែដែលត្រូវបញ្ចប់សិទ្ធិនៃការជួលដីនោះ
- ប្រសិនបើដីអភិវឌ្ឍលំនៅឋាននោះជាដីជាប់បន្ទុក ត្រូវប្រកាសប្រាប់អ្នកទិញលំនៅឋាន អំពីក្បាលដីជាប់បន្ទុកផ្សេងៗ និងត្រូវធានានូវការផ្ទេរកម្មសិទ្ធិស្របច្បាប់ បន្ទាប់ពីអ្នកទិញលំនៅឋាន អំពីក្បាលដីជាប់បន្ទុកផ្សេងៗ និងត្រូវធានានូវការផ្ទេរកម្មសិទ្ធិស្របច្បាប់ បន្ទាប់ពី អ្នកទិញលំនៅឋាន បានអនុវត្តកាតព្វកិច្ចបង់ប្រាក់រួចរាល់
- លិខិតអនុញ្ញាតសាងសង់ ។

៣.១.៤ លំនៅឋានគំរូ

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវរៀបចំលំនៅឋានគំរូឱ្យបានរួចរាល់ មុនធ្វើការប្រកាសលក់លំនៅឋាន ។ លំនៅឋានគំរូត្រូវរៀបចំជាក់ស្តែង ឱ្យស្របទៅតាមគំរូប្លង់ ទំហំ ការតុបតែង និង បំពាក់សម្ភារៈសំណង់ ដូចគម្រោងលំនៅឋានដែលនឹងត្រូវសាងសង់ ដើម្បីលក់ជូនអ្នកទិញ លំនៅឋាន ។ ចំពោះសម្ភារៈបំពាក់ និងគ្រឿងសង្ហារឹមដែលមិនផ្តល់ជូនត្រូវសរសេរស្លាកបិទឱ្យបានច្បាស់លាស់ [49]។

៣.១.៥ ប្រាក់តម្កល់អាជីវកម្ម

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវតែមានប្រាក់តម្កល់អាជីវកម្ម និងគណនីអភិវឌ្ឍលំនៅឋានដើម្បី ធានាដល់អាជីវកម្មរបស់ខ្លួនទៅលើគម្រោងអភិវឌ្ឍលំនៅឋាន។ ចំពោះប្រាក់តម្កល់ អាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានច្បាប់កំណត់ពីនីតិវិធី និងចំនួននៃ ការតម្កល់ប្រាក់អាជីវកម្ម (៣.១.៥.១) និងការដកប្រាក់តម្កល់ប្រាក់អាជីវកម្ម (៣.១.៥.២)ជាដើម ដើម្បីងាយស្រួលដល់ ការគ្រប់គ្រងអាជីវកម្មនេះ ។

៣.១.៥.១ ការតម្កល់ប្រាក់អាជីវកម្ម

ប្រាក់តម្កល់អាជីវកម្មគឺសំដៅដល់ចំនួនសាច់ប្រាក់ដែល ក្រុមហ៊ុនត្រូវតម្កល់សម្រាប់ជាប្រាក់ធានាដែលត្រូវយកមកប្រើប្រាស់ដើម្បីអាជីវកម្ម។ ប្រាក់តម្កល់នេះត្រូវតម្កល់នៅក្នុងធនាគារជាតិ

[49] ប្រការ ២៦ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

កម្ពុជា ឬ ធនាគារពាណិជ្ជកម្មក្នុងស្រុកណាមួយ ។ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ១ មិនតម្រូវអោយមានប្រាក់ តម្កល់អាជីវកម្ម។ ចំនែកក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ២ ត្រូវតម្កល់ប្រាក់តម្កល់អាជីវកម្ម ២% នៃតម្លៃគម្រោងវិនិយោគសរុប ឬតម្លៃវិនិយោគគម្រោងតាម ដំណាក់កាលនីមួយៗទៅតាមវិធីសាស្ត្រដូចជា តម្កល់ជាប្រាក់សុទ្ធក្នុងគណនីទោលរតនាគាជាតិទៅធនាគារជាតិកម្ពុជា ឬលិខិតធានាពីធានាគារពាណិជ្ជកម្មក្នុងស្រុកណាមួយ ។ ប្រាក់តម្កល់ខាងលើនេះមិនអាចដកវិញបានឡើយ លុះត្រាតែក្រុមហ៊ុនអភិវឌ្ឍលំនៅឋានបានបញ្ចប់គម្រោងជាស្ថាពរ ឬបាន ដោះស្រាយសោធនភាពរបស់ខ្លួនតាមការវាយតម្លៃរបស់ក្រសួង[50]។

ប៉ុន្តែប្រសិនបើក្នុងករណីដែលគម្រោងអភិវឌ្ឍលំនៅឋាន សម្រាប់ដំណាក់កាលមុនបានសាងសង់ចប់ជាស្ថាពរ ដោយមានការវាយតម្លៃដល់ទីកន្លែងពីមន្ត្រីជំនាញរបស់នាយកដ្ឋាន ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានអាច ស្នើសុំបង្វែលប្រាក់តម្កល់ធានាអាជីវកម្ម សម្រាប់គម្រោងអភិវឌ្ឍលំនៅឋាននៅ ដំណាក់កាលនោះ ទៅជាប្រាក់តម្កល់ធានាអាជីវកម្មអភិវឌ្ឍលំនៅឋានដំណាក់កាលផ្សេងទៀតបាន ដោយតម្រូវអោយមានលិខិតស្នើសុំជាលាយលក្ខណ៍អក្សរមកក្រសួងជាមុន[51]។

៣.១.៥.២ ការដកប្រាក់តម្កល់

ក្រោយពីគម្រោងបានបញ្ចប់ជាស្ថាពរ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវធ្វើលិខិតស្នើសុំដកប្រាក់ តម្កល់មកក្រសួងដោយភ្ជាប់មកជាមួយនូវ របាយការណ៍បញ្ចប់គម្រោងទៅតាមគំរូរបស់ក្រសួង ។ ក្រសួងនឹងសម្រេចអោយដកប្រាក់តម្កល់វិញ ប្រសិនបើពិនិត្យឃើញថា គម្រោងសាងសង់នេះ ពិតជាបានបញ្ចប់ជាស្ថាពរ ក្រោយពីមានការចុះវាយតម្លៃជាក់ស្តែងដល់ទីកន្លែងពីមន្ត្រីជំនាញរបស់ នាយកដ្ឋាន និង/ឬ ដោយមានលិខិតបិទការដ្ឋានសាងសង់ភ្ជាប់មកជាមួយ ។ ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួល និងឯកសារតម្រូវផ្សេងៗ ក្រសួងនឹងចេញលិខិតឲ្យដកឬមិនដកប្រាក់ តម្កល់អាជីវកម្មពីធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជកម្មដែលក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន បានដាក់ប្រាក់តម្កល់ធានាអាជីវកម្ម [52]។

៣.១.៦ គណនីអភិវឌ្ឍលំនៅឋាន

គណនីអភិវឌ្ឍលំនៅឋាន សំដៅដល់គណនីចរន្តដែលបើកដោយ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននៅធនាគារពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមទៅតាមលក្ខខណ្ឌតម្រូវនៃប្រកាសនេះ

[50] ប្រការ ២៣ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍ លំនៅឋាន

[51] ប្រការ ២៥ ប្រកាសដដែល

[52] ប្រការ ២៦ នៃប្រកាសដដែល

ដើម្បីរក្សាទុកប្រាក់ដែលបង់ដោយអ្នកទិញលំនៅឋាន ជាអាទ៍ប្រាក់កក់, ប្រាក់កក់ដំបូង និង/ឬប្រាក់បង់បន្តបន្ទាប់ និង/ឬប្រាក់បង់សរុប ព្រមទាំងប្រាក់ជាកម្រៃផ្សេងទៀត ពាក់ពន្ធ័នឹង ការទិញលំនៅឋាន[53]។ ដូច្នេះក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវរៀបចំការបើក គណនីអភិវឌ្ឍលំនៅឋាន (៣.១.៦.១) និង ការដកប្រាក់គណនីអភិវឌ្ឍលំនៅឋាន (៣.១.៦.២) ដូចខាងក្រោម :

៣.១.៦.១ ការបើកគណនីអភិវឌ្ឍលំនៅឋាន

ចំពោះក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ ២ ត្រូវបើកគណនីអភិវឌ្ឍលំនៅឋាន នៅធនាគារពាណិជ្ជកម្មណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ រក្សាប្រាក់កក់ដំបូង ឬប្រាក់ត្រូវបង់តាមដំណាក់កាល ឬប្រាក់បង់គ្រប់ប្រភេទរបស់អ្នកទិញលំនៅឋាន ។ គណនីនេះត្រូវស្ថិតនៅក្រោមការតាមដានជាប្រចាំពីក្រសួង និងអាចបិទបានលុះត្រាតែគម្រោងអភិវឌ្ឍលំនៅឋាននោះបាន បញ្ចប់ជាស្ថាពរ និងឯកភាពពីក្រសួង[54]។ ប្រាក់កក់ដំបូង ឬប្រាក់ត្រូវបង់តាមដំណាក់កាល ឬប្រាក់បង់គ្រប់ប្រភេទរបស់អ្នកទិញលំនៅឋានត្រូវ បង់ដោយផ្ទាល់ទៅក្នុងគណនីអភិវឌ្ឍលំនៅឋានរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដូចមានចែងក្នុង កិច្ចសន្យាលក់-ទិញ[55]។ រីឯក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានដែលទទួលអាជ្ញាបណ្ណប្រភេទ១ មិនតម្រូវអោយបើកគណនីអភិវឌ្ឍ លំនៅឋានឡើយ ។

៣.១.៦.២ ការដកប្រាក់ពីគណនីអភិវឌ្ឍលំនៅឋាន

ការដកប្រាក់ពីគណនីអភិវឌ្ឍលំនៅឋាន ត្រូវបានអនុញ្ញាតសម្រាប់តែការបម្រើឲ្យគោលបំណង នៃការសាងសង់គម្រោងអភិវឌ្ឍលំនៅឋាននោះតែប៉ុណ្ណោះ ។ ការដកប្រាក់ពីគណនីអភិវឌ្ឍលំនៅឋាន នោះត្រូវតែសមាមាត្រទៅនឹងទំហំការងារដែលក្រុមហ៊ុនអភិវឌ្ឍលំនៅឋានសាងសង់បាន និងត្រូវមានលិខិតបញ្ជាក់ពីវិស្វករត្រួតពិនិត្យគម្រោងរបស់ ក្រុមហ៊ុនអំពីភាគរយនៃលទ្ធផលការងារដែលក្រុមហ៊ុនអភិវឌ្ឍលំនៅឋានបានអនុវត្តកន្លងមក។ វិស្វករដែលចេញលិខិតបញ្ជាក់នោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ពាក់ពន្ធ័ជាធរមាន ក្នុងករណីចេញលិខិតបញ្ជាក់មិនត្រឹមត្រូវ ឬក្លែងបន្លំ[56] ។ ក្រសួងមានសិទ្ធស្នើសុំ បង្កើតគណនីអភិវឌ្ឍលំនៅឋានរបស់ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានក្នុងករណីដែលក្រសួងពិនិត្យឃើញថា ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននោះពុំមានលទ្ធភាពសាងសង់ ឬបោះបង់ ចោលសាងសង់គម្រោងអភិវឌ្ឍលំនៅឋានរបស់ខ្លួនឬប្រធានសក្តិឬដែលធ្វើឲ្យខូចប្រយោជន៍របស់អ្នកទិញលំនៅឋាន[57]។

---

[53] ប្រការ ៤ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍ លំនៅឋាន

[54] ប្រការ ២៧ នៃប្រកាសដដែល

[55] ប្រការ ២៨ នៃប្រកាសដដែល

[56] ប្រការ ២៩ នៃប្រកាសដដែល

[57] ប្រការ ៣០ នៃប្រកាសដដែល

៣.១.៧ ការធ្វើរបាយការណ៍

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវធ្វើរបាយការណ៍ជូនទៅ នាយកដ្ឋានគ្រប់គ្រងអចលនវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការត្រួតពិនិត្យទៅលើដំណើរការនៃគម្រោងអាជីវកម្មអភិវឌ្ឍលំនៅឋានទៅតាមកាលកំណត់របស់ក្រសួង ដែលក្នុងនោះសង្កេតឃើញថាមានរបាយការណ៍ប្រចាំខែ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍ស្តីពីការបញ្ចប់គម្រោង និង របាយការណ៍ហិរញ្ញវត្ថុ ។

- របាយការណ៍ប្រចាំខែ ផ្អែកតាមប្រការ ៣១នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន បានកំនត់ថា ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវផ្តល់ជូននាយកដ្ឋាននូវរបាយការណ៍ដូចខាងក្រោម ៖
  - · របាយការណ៍ប្រចាំខែ ស្តីពីវឌ្ឍនភាពនៃការសាង់សង់(ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ប្រភេទ២)
  - · របាយការណ៍ប្រចាំខែ ស្តីពីចលនាសាច់ប្រាក់នៅក្នុងគណនីអភិវឌ្ឍលំនៅឋាន (ក្រុមហ៊ុន ដែលទទួលអាជ្ញាបណ្ណប្រភេទ២)
  - · របាយការណ៍ប្រចាំខែ ស្តីពីលក់-ទិញគម្រោង ។

របាយការណ៍ប្រចាំខែខាងលើ ត្រូវផ្តល់អោយបានមុនថ្ងៃទី ០៧ នៃថ្ងៃធ្វើការ នៃខែបន្ទាប់ ។ ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំនត់ ទៅតាមគំរូដែលក្រសួងបានផ្តល់ជូន [58]។

- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស ប្រការ ៣២នៃប្រកាសលេខ ៩៦៥សហវ.ប្រកបានកំណត់ថាក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវផ្តល់របាយការណ៍ប្រចាំឆមាសមកក្រសួង ឲ្យបានមុនថ្ងៃទី ១៥ នៃខែទី ១នៃឆមាសបន្ទាប់ ។
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងរយៈពេល ៣ខែ គិតចាប់ពីការបិទកាលបរិច្ឆេទ នៃឆ្នាំហិរញ្ញវត្ថុនីមួយៗ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវផ្តល់របាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំមកក្រសួង ។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនេះ ត្រូវតែបានធ្វើសវកម្មរួចដោយសវនករឯករាជ្យ ដោយមានការទទួលស្គាល់ដោយក្រសួងឬដោយ អាជ្ញាធរមានសមត្ថកិច្ច [59]។
- របាយការណ៍ស្តីពីការបញ្ចប់គម្រោង ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវធ្វើរបាយការណ៍ស្តីពីការបញ្ចប់គម្រោង និងរបាយការណ៍ហិរញ្ញវត្ថុមកក្រសួងក្នុងរយៈពេលមួយខែ ក្រោយកាលបរិច្ឆេទបញ្ចប់គម្រោងទៅតាមគម្រោងដែល ក្រសួងបានផ្តល់ជូន[60]។

---

[58] ប្រការ ៣១នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

[59] ប្រការ ៣៣នៃប្រកាសដដែល

[60] ប្រការ ៣៤ នៃប្រកាសដដែល

៣.២ ការដោះស្រាយវិវាទអាជីវកម្មអភិវឌ្ឍលំនៅឋាន

ប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវ-កម្មអភិវឌ្ឍលំនៅឋាន បានកំនត់យ៉ាងច្បាស់ពី ការដោះស្រាយវិវាទ និងទោសប្បបញ្ញត្តិទៅលើអាជីវកម្មអភិវឌ្ឍលំនៅឋាន ។ ដូច្នេះយើងនឹងធ្វើការបកស្រាយយ៉ាងលម្អិត ពីការដោះស្រាយវិវាទលើអាជីវកម្មអភិវឌ្ឍលំនៅឋាន (៣.២.១) និងទោសប្បបញ្ញត្តិ (៣.២.២) ដែលមានដូចខាងក្រោម

៣.២.១ ការដោះស្រាយវិវាទលើអាជីវកម្មអភិវឌ្ឍលំនៅឋាន

៣.២.១.១ ការផ្សះផ្សា

វិវាទរវាងក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន និងរវាងក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននិងអ្នកប្រើប្រាស់ ៣ក់ ពន្ធ័កិច្ចសន្យាលក់ទិញលំនៅឋាន អាចជាកម្មវត្ថុនៃការសម្រុះសម្រួលនិងផ្សះផ្សាដោយអគ្គនាយក ដ្ឋាន ។ ក្រសួងសម្រុះសម្រួលនិងផ្សះផ្សាវិវាទ តាមការស្នើសុំរបស់ភាគីវិវាទ ក្នុងរយៈពេល ០២ ខែ យ៉ាងយូរ ។ ការផ្សះផ្សាវិវាទអាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខា ដោយគូភាគីវិវាទ ដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋាន ។ កិច្ចព្រមព្រៀងផ្សះផ្សាមានអានុភាព អនុវត្តភ្លាមៗចំពោះគូភាគី[61]។

៣.២.១.២ ការដោះស្រាយវិវាទ

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ឬអ្នកប្រើប្រាស់ ដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការ លើកលែងរឿងព្រហ្មទណ្ឌ ។ ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល ៩០ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ាក្នុងរយៈពេលមួយសមរម្យ។ក្នុងការដោះស្រាយវិវាទក្រុមប្រឹក្សានីតិកម្ម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចអញ្ជើញភាគីពាក់ពន្ធ័វិវាទ ដើម្បីសាកសួរ ឬផ្តល់ភស្តុតាង តាមការចាំបាច់ ។

សេចក្តីសម្រេចចេញពីការដោះស្រាយវិវាទត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អង្គហេតុ សំអាងហេតុ និងការសន្និដ្ឋាន។ ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភាគីវិវាទអាចដាក់ពាក្យបណ្តឹងទៅតុលាការ មាន សមត្ថកិច្ចដោយអនុលោមតាមបទប្បបញ្ញាត្តិជាធរមាន[62]។

---

[61] ប្រការ ៣៧ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

[62] ប្រការ ៣៨ នៃប្រកាសដដែល

៣.២.២ ទោសប្បញ្ញត្តិ

បច្ចុប្បន្នវិស័យអភិវឌ្ឍលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាកំពុងតែមាន ការរីកដុះ ដាលពាសពេញទីក្រុងគួរអោយកត់សម្គាល់ ក្នុងនោះដែរយើងសង្កេតឃើញថាក្រុមហ៊ុនអភិវឌ្ឍលំនៅឋានខ្លះក៏បាន អនុវត្តអាជីវកម្មរបស់ខ្លួនស្របទៅតាមបទប្បញ្ញត្តិរបស់ក្រសួង រីឯក្រុមហ៊ុនមួយចំនួនទៀតនៅតែមិន អនុវត្តទៅតាមបទប្បញ្ញត្តិច្បាប់ឡើយ ដែលជាហេតុបង្កអោយមានផលប៉ះពាល់ទៅដល់អ្នកទិញ លំនៅឋានក៏ដូចជាប៉ះពាល់ដល់ប្រទេសជាតិផងដែរ ។ ដូច្នេះហើយទើបក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ពី យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រងនិងការ ត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍលំនៅឋាន នៅព្រះរាជាណាចក្រកម្ពុជាដែលមាននៅក្នុងប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។ ជំពូកទី ៨នៃប្រកាសខាងលើនេះបានកំណត់ពីទោសប្បញ្ញត្តិ ទៅលើអំពើបំពានទាំងឡាយដែលក្រុមហ៊ុនអភិវឌ្ឍលំនៅឋានណាដែលបានបង្កឡើងដោយខុសទៅនឹង បទប្បញ្ញាត្តិច្បាប់ ។ ចំពោះអំពើទាំងនោះ យើងនឹងធ្វើការបកស្រាយទៅពីនៅចំនុចខាងក្រោម អំពើបំពានទៅលើអាជីវកម្ម (៣.២.២.១) និងការទទួលទោស (៣.២.២.២)។

៣.២.២.១ អំពើបំពានទៅលើអាជីវកម្ម

ប្រការ ៣៩ នៃប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន បានកំណត់ថា អំពើដែល ត្រូវបានចាត់ទុកថាជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះមានដូចខាងក្រោម៖

- ធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋានដោយគ្មានអាជ្ញាបណ្ណ ក្លែងបន្លំអាជ្ញាបណ្ណ ឬប្រើប្រាស់អាជ្ញាបណ្ណហួសសុពលភាព
- ពុំទិញកិច្ចសន្យាធានារ៉ាប់រងទទួលខុសត្រូវការដ្ឋាន
- ប្រើប្រាស់គណនីផ្សេងពីគណនីអភិវឌ្ឍលំនៅឋានសម្រាប់ទទួលប្រាក់ពីអ្នកទិញ ចំពោះ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានប្រភេទ ២
- ផ្សព្វផ្សាយពាណិជ្ជកម្មដែលលក្ខណៈជាការឆបោក ឬនាំឲ្យមានការយល់ច្រឡំ
- លក់លំនៅឋានមុនពេលការបញ្ចប់គម្រោងសាងសង់ ចំពោះក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ប្រភេទ១
- ក្លែងបន្លំ យឺតយ៉ាវ ឬការខកខានមិនផ្តល់របាយការណ៍តាមការកំណត់របស់ក្រសួងដូចមាន ចែងនៅក្នុងប្រកាស
- ពុំបានអនុវត្តតាមខ្លឹមសារសៀវភៅបន្ទុក

- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង ដោយអនុលោមតាមច្បាប់ជាធរមាន។

៣.២.២.២ ការទទួលទោស

រាល់អំពើបំពានដែលក្រុមហ៊ុនអភិវឌ្ឍលំនៅឋានបានប្រព្រឹត្តដូចអំពើខាងលើនេះ ត្រូវតែទទួលទោស ដែលមានកំនត់នៅជំពូកទី ៨ (ទោសបញ្ញត្តិ) ពីប្រការ ៣៩ ដល់ប្រការ ៤៩នៃប្រកាសស្តីពីការគ្រប់ គ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ដែលមានជាទោសរដ្ឋបាល (ក) និងពិន័យជាអន្តរកាណ៍ (ខ)។

ក. ទោសរដ្ឋបាល

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានទាំងឡាយណាដែលបានប្រព្រឹត្តកំហុស ដូចមានចែងក្នុងប្រការ ៣៩ នៃប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង អាជីវកម្មអភិវឌ្ឍលំនៅឋាននឹងត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលណាមួយដូចខាងក្រោម ៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការបង្កកគណនីអភិវឌ្ឍលំនៅឋាន
- ហាមឃាត់ការធ្វើប្រតិបត្តិការ ឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណបណ្ណោះអាសន្ន ពី ០៦ ខែ ទៅ ០១ ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ[63]។

ខ. ទោសជាពិន័យអន្តរការណ៍

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានទាំងឡាយណា ដែលបំពានទៅនឹងបទប្បញ្ញត្តិនៃច្បាប់ជាធរមាន មិនត្រឹមតែទទួលរងនូវទណ្ឌកម្មរដ្ឋបាលប៉ុណ្ណោះទេក៏ត្រូវទទួលនូវពិន័យអន្តរការណ៍ផងដែរ។ ពិន័យអន្តរកាណ៍ទៅលើក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននេះ គឺពិន័យទៅតាម អំពើបំពានផ្សេងៗគ្នាមាន ដូចជា៖

ខ.១. ការប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានគ្មានអាជ្ញាបណ្ណ

នាពេលបច្ចុប្បន្ននេះទោះបីជាក្រសួងបានរៀបចំឱ្យមានការរឹតបន្តឹង ទៅលើអាជីវកម្ម អភិវឌ្ឍលំនៅឋានក៏ពិតមែន ប៉ុន្តែនៅតែមានជនឆ្លៀតឱកាសមួយចំនួនបានធ្វើអាជីវកម្មនេះ ដោយគ្មានការសុំអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ ឬក៏បានដាក់ពាក្យ ស្នើសុំអាជ្ញាបណ្ណតែក្រសួងមិនអនុញ្ញាតជាដើម ។ ដូច្នេះយោងតាមប្រការ ៤១ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែសីហា

[63] ប្រការ ៤០ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ខែសីហាឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

ឆ្នាំ០១៦ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន បានកំនត់ថា ការប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានគ្មានអាជ្ញាបណ្ណ ត្រូវទទួលរងពិន័យអន្តរកាណ៍ពីក្រសួង ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល។ នៅក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

ខ.២. ការមិនគោរពតាមបទប្បញ្ញត្តិនៃការលក់ ឬផ្សាយពាណិជ្ជកម្មលក់លំនៅឋាន

ច្បាប់បានតម្រូវឱ្យក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ធ្វើការផ្សព្វផ្សាយពីអាជីវកម្មលំនៅឋាននិងការលក់ យ៉ាងទូលំទូលាយទៅតាមប្រពន្ធ័ផ្សព្វផ្សាយជាច្រើនពេលបច្ចុប្បន្ននេះ ប៉ុន្តែការផ្សព្វផ្សាយ ការលក់អាជីវកម្មនេះត្រូវតែទៅគោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។ ក្នុងករណីបើក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដោយមិនគោរពតាមច្បាប់កំនត់ទេនោះក្រសួងនឹងធ្វើការពិន័យទៅលើក្រុមហ៊ុននោះ។ អំពើលក់ ឬផ្សាយពាណិជ្ជកម្មលក់លំនៅឋាន ដោយមិនអនុលោមតាម ប្រការ ១៦, ប្រការ ១៧, ប្រការ ១៨, ប្រការ ១៩, ប្រការ ២០ និងប្រការ ២៦ នៃប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្ម អភិវឌ្ឍលំនៅឋាន ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួនពី ១ លានរៀល ក្នុង ០១ថ្ងៃ សម្រាប់ រយៈពេល ៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ជាកពិន័យនេះត្រូវ គុណទ្វេដងក្នុង ០១ថ្ងៃ [64]។

ខ.៣. ការបើកដំណើរការគណនីផ្សេង និងការប្រើប្រាស់ប្រាក់ពីគណនីអភិវឌ្ឍលំនៅឋានផ្ទុយពី ប្រការ ២៩ នៃប្រកាសស្តីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

- **ការបើកដំណើរការគណនីផ្សេងពីគណនីអភិវឌ្ឍលំនៅឋាន៖** ប្រការ ៤៣ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន បានកំនត់ថា ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានប្រភេទ ២ ដែលបើក និងដំណើរការគណនីផ្សេង ដើម្បីទទួលប្រាក់របស់អ្នកទិញ ក្រៅពីគណនីអភិវឌ្ឍលំនៅឋាន ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ដប់លានរៀល ។
- **ការប្រើប្រាស់ប្រាក់គណនីអភិវឌ្ឍលំនៅឋានផ្ទុយនឹងប្រការ ២៩នៃប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្ម អភិវឌ្ឍលំនៅឋាន៖** ប្រការ ៤២នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ស្តីពីការគ្រប់គ្រងអាជីវកម្ម អភិវឌ្ឍលំនៅឋាន បានកំនត់ថា ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានប្រភេទ ២ ដែលប្រើប្រាក់ក្នុងគណនីអភិវឌ្ឍលំនៅឋាន ដោយផ្ទុយ នឹងប្រការ ២៩ ត្រូវទទួលពិន័យអន្តការណ៍ពីក្រសួងចំនួន ១០ លានរៀល ក្នុង ០១ករណី [65] ។ ក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន មិនអាចដកប្រាក់ពីគណនីអភិវឌ្ឍលំនៅឋានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពី ការសាងសង់គម្រោង

[64] ប្រការ ៤២ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្ររអាជីវកម្មអភិវឌ្ឍ លំនៅឋាន

[65] ប្រការ ៤៤ នៃប្រកាសដដែល

អភិវឌ្ឍលំនៅឋានបានឡើយ ប៉ុន្តែបើការដកប្រាក់នេះសម្រាប់គម្រោងសាងសង់គឺត្រូវតែសមាមាត្រទៅនឹងទំហំការងារ ដែលក្រុមហ៊ុនសាងសង់បាន និងត្រូវមានលិខិតបញ្ជាក់ពីវិស្វករត្រួតពិនិត្យគម្រោងរបស់ ក្រុមហ៊ុនអំពីលទ្ធផលការងារនេះ។

ខ.៤. ការខកខានពុំបានផ្តល់របាយការណ៍

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានប្រភេទ ២ ត្រូវតែធ្វើរបាយការណ៍ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមការកំនត់របស់ច្បាប់ ។ ប្រសិនបើក្រុមហ៊ុនអភិវឌ្ឍលំនៅឋានប្រភេទ ២ ដែលខកខានពុំបានផ្តល់របាយការណ៍តាមការកំណត់ដូច មានចែងក្នុងរបាយការណ៍ ត្រូវទទួលពិនិយ័អន្តរការណ៍ពីក្រសួងចំនួន ៥ ពាន់រៀល ក្នុង ០១ថ្ងៃ សម្រាប់រយៈពេល ៣០ថ្ងៃដំបូង ។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យ នេះត្រូវគុណទ្វេដងក្នុង ០១ថ្ងៃ [66]។

ខ.៥. ការមិនបានបន្តសុពលភាពបណ្ណាធានារ៉ាប់រងលើការៈទទួលខុសត្រូវការដ្ឋាននិងលិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្ម

- **ការមិនបានបន្តសុពលភាពបណ្ណាធានារ៉ាប់រងលើការៈទទួលខុសត្រូវការដ្ឋាន៖** ក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន ដែលមិនបានបន្តសុពលភាពបណ្ណាធានារ៉ាប់រងលើការៈទទួលខុសត្រូវ ការដ្ឋាន តាមកាលបរិច្ឆេទកំណត់ ឬមានការយឺតយ៉ាវ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ចំនួន ៥ ពាន់រៀល ក្នុង ០១ថ្ងៃ សម្រាប់រយៈពេល ៣០ថ្ងៃដំបូង ។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះត្រូវគុណទ្វេដងក្នុង ០១ថ្ងៃ[67]។
- **ការមិនបន្តលិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្ម៖** ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដែលមិនបន្តសុពលភាពលិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្ម តាមកាលបរិច្ឆេទកំណត់ ឬមានការយឺតយ៉ាវ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥ពាន់រៀល ក្នុង ០១ថ្ងៃ សម្រាប់រយៈពេល ៣០ថ្ងៃដំបូង ។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យ នេះ ត្រូវគុណទ្វេដងក្នុង ០១ថ្ងៃ [68]។

ខ.៦. ការដកប្រាក់តម្កល់ធានាអាជីវកម្មដោយគ្មានការអនុញ្ញាតពីក្រសួង

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដែលដកប្រាប់តម្កល់ធានាអាជីវកម្មដោយគ្មានការអនុញ្ញាតពីក្រសួងត្រូវទទួលពិន័យអន្តរកាលចំនួនទ្វេដង នៃប្រាក់តម្កល់ [69]។

---

[66] ប្រការ ៤៥ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

[67] ប្រការ ៤៦ នៃប្រកាសដដែល

[68] ប្រការ ៤៧ ប្រកាសដដែល

[69] ប្រការ ៤៨ នៃប្រកាសដដែល

ខ.៧. ការសាងសង់លំនៅឋានលើសចំនួនដែលមាននៅក្នុងអាជ្ញាបណ្ណ

ប្រការ ៤៩ នៃប្រកាសលេខ ៩៦៥ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៦ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដែលសាងសង់លំនៅឋានលើសចំនួនដែលមាននៅក្នុងអាជ្ញាបណ្ណ ត្រូវទទួលពិន័យអន្តរការណ៍ ចំនួន ២ លានរៀល ក្នុង ០១ ឯកតា។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះត្រូវគុណទ្វេដង ក្នុង ០១ ឯកតា។

សេចក្តីសន្និដ្ឋាន
និង អនុសាសន៍

សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវនិងបកស្រាយទៅលើប្រធានបទស្តីពី "**ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន**" យើងអាចសន្និដ្ឋានបានថា ដើម្បីបង្កើតបានជាក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលមានបុគ្គលគតិយុត្តនោះ ត្រូវឆ្លងកាត់តាមការសម្រេចយល់ព្រមទៅតាមបទគតិយុត្តទាំងឡាយដែលជាធរមានរបស់ក្រសួងដែលពាក់ពន្ធ័ទៅលើអាជីវកម្មអភិវឌ្ឍលំនៅឋាននេះ។

ដំណាក់ដំបូងនៃការបង្កើត ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន សមាជិកទាំងអស់ត្រូវធ្វើការស្វែងយល់ពីលក្ខណៈទូទៅនៃបង្កើតក្រុមហ៊ុន និងធ្វើការចុះហត្ថលេខលើលក្ខន្តិកៈក្រុមហ៊ុន។ ដើម្បីអាចអាចក្លាយជាក្រុមហ៊ុន អភិវឌ្ឍលំនៅឋានម្ចាស់អភិវឌ្ឍលំនៅឋានត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្ម ទៅក្រសួងពាណិជ្ជកម្មដោយធ្វើការដាក់ពាក្យស្នើសុំ ដែលបំពេញបែបបទទៅតាមលក្ខខណ្ឌច្បាប់តម្រូវម៉ាងវិញទៀត ចំពោះការស្នើសុំចុះបញ្ជីពាណិជ្ជកម្មនាពេលបច្ចុប្បន្ន យើងអាចធ្វើការចុះបញ្ជីពាណិជ្ជកម្មតាមប្រពន្ធ័ស្វ័យប្រវត្តកម្ម ដោយមិនចាំបាច់ទៅដល់ក្រសួងផ្ទាល់បន្ទាប់ពី ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានបានចុះបញ្ជីពាណិជ្ជកម្មរួចរាល់ ១៥ថ្ងៃបន្ទាប់ពីទទួលវិញ្ញាបនបត្រហើយ ម្ចាស់ក្រុមហ៊ុនត្រូវបំពេញកាតព្វកិច្ចទៅចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ។ ក្រោយពីក្រុមហ៊ុនអភិវឌ្ឍលំនៅឋានបំពេញនូវដំណាក់កាលដំបូងខាងលើរួចរាល់ ក្រុមហ៊ុនចាប់ផ្តើមលេចចេញជារូបរាង ប៉ុន្តែមិនទាន់អាចដំណើរការអាជីវកម្មរបស់ខ្លួនបានឡើយ ក្រុមហ៊ុនត្រូវបន្តនីតិវិធីតម្រូវបន្ថែមដើម្បីទទួលបានអាជ្ញាបណ្ណអភិវឌ្ឍលំនៅដ្ឋានចេញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលិខិតអនុញ្ញាតសាងសង់ពីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ជាមុខសិន។ ចំពោះការស្នើសុំអាជ្ញាបណ្ណ គឺដើម្បីបញ្ជាក់អំពីប្រភេទ និងទំហំ របស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន និងបញ្ជាក់ពីលក្ខខណ្ឌដែលផ្តល់នត្ថិភាពដល់ក្រុមហ៊ុនដែលមានសិទ្ធិក្នុងការធ្វើអាជីវកម្មនេះ។ ចំនែកឯការស្នើសុំលិខិតអនុញ្ញាតសាងសង់ក៏ជាផ្នែកមួយដ៏សំខាន់ ទៅលើអាជីវកម្មអភិវឌ្ឍលំនៅឋានព្រោះលិខិតអនុញ្ញាតសាងសង់ដែលទទួលស្គាល់ដោយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ជាលក្ខខណ្ឌសំខាន់មួយក្នុងចំណោមលក្ខខណ្ឌផ្សេងទៀតដើម្បី ទទួលបានការអនុញ្ញាតធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋានដោយក្រសួងនឹងធ្វើការត្រួតពិនិត្យទៅលើប្លង់ និងការសាងសង់របស់ក្រុមហ៊ុននោះមានស្តង់ដារ និងបច្ចេកទេសក្នុងការសាងសង់ត្រូវតាមការកំនត់ របស់ច្បាប់ដែរឬទេ។ បន្ទាប់ពីបានទទួលលិខិតការអនុញ្ញាតសាងសង់ ម្ចាស់សំណង់អាចយកលិខិតអនុញ្ញាតសាងសង់ ដើម្បីចាប់ផ្តើមដំណើរការបើកការដ្ឋានសាងសង់របស់ខ្លួនបានហើយម្ចាស់សំណង់ត្រូវតែអោយ ឬមានការចូលរួមត្រួតពិនិត្យពីអាជ្ញាធរ ដើម្បីអោយមានការសាងសង់លក្ខណៈត្រឹមត្រូវ។ ម៉ាងទៀតនៅក្នុងការសាងសង់ម្ចាស់សំណង់ មានសិទ្ធិជ្រើសរើសនូវសហគ្រាស ក្រុមហ៊ុនសិក្សា គំរោងប្លង់ និងសាងសង់ និងក្រុម

ជាងសំណង់ត្រូវតែមានលិខិតបើការការដ្ឋាន ទើបអាចចាប់ផ្តើម ការងាររបស់ខ្លួនបាន បើគម្រោងសាងសង់ចប់ជាស្ថាពរ ក៏ត្រូវធ្វើលិខិតស្នើសុំបិទការដ្ឋានទៅក្រសួងផងដែរ ។ នៅក្នុងដំណាក់កាលនៃដំណើរប្រតិបត្តិការអាជីវកម្ម ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានក៏ចាប់ផ្តើម មានកាតព្វកិច្ចជាច្រើនដើម្បីរៀបចំអាជីវកម្មអភិវឌ្ឍលំនៅឋាន មានដូចជា ប្រកាសប្រាប់អ្នកទិញ លំនៅឋានអំពីប្រភេទដីដែលបានសាងសង់ ទទួលខុសត្រូវចំពោះអ្នកទិញលំនៅឋានពាក់ព័ន្ធនឹង សំណង់លំនៅឋាន ក៏ដូចជាអនុវត្តទៅតាមស្តង់ដារនៃកិច្ចសន្យាលក់-ទិញ និងធ្វើរបាយការណ៍ជូនទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

បច្ចុប្បន្ននេះរដ្ឋាភិបាល បានដាក់ចេញនូវអនុក្រឹត្យ ប្រកាស សារាចរ ជាច្រើនក្នុងការគ្រប់គ្រង អាជីវកម្មអភិវឌ្ឍលំនៅឋាន ដើម្បីជំរុញឱ្យការអនុវត្តមានប្រសិទ្ធភាពនិងឆាប់រហ័ស ។ ដូច្នេះ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវតែអនុវត្តអាជីវកម្មនេះ ទៅតាមមាគ៌ាច្បាប់ដើម្បីជាផលប្រយោជន៍ ផ្ទាល់ដល់ក្រុមហ៊ុនក៏ដូចជា ម្ចាស់គម្រោងអភិវឌ្ឍលំនៅឋាន ដែលទទួលបាននូវការអនុវត្តដោយ មានប្រសិទ្ធភាព ទទួលបានអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋានដោយស្របច្បាប់ដើម្បីយកទៅធ្វើអាជីវកម្ម។ បន្ថែមពីនេះទៅទៀត ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានក៏បានចូលរួមចំណែកអភិវឌ្ឍប្រទេស តាមរយៈការ បង់ពន្ធរបស់ខ្លួន និងចូលរួមក្នុងការរៀបចំអភិវឌ្ឍន៍ក្រុងឱ្យមានអាគារប្រណីតៗមានសោភណ្ឌ៍ភាពល្អ រឹងមាំ និងផ្តល់សុខមាលភាពក្នុងការរស់នៅឱ្យប្រជាពលរដ្ឋតាមរយៈគម្រោងអភិវឌ្ឍលំនៅឋាន របស់ខ្លួន ជាពិសេសគឺជួយទាក់ទាញ ការវិនិយោគពីបរទេសក៏ដូចជាជួយឱ្យប្រទេសអាចប្រកួតជែងផ្នែកអចលនវត្ថុជាមួយ នឹងប្រទេសដទៃទៀតដែល។

ទោះជាយ៉ាងណាក៏ដោយយើងសង្កេតឃើញថាមានផលវិបាកមួយចំនួន ដែលកើតមានលើវិស័យនេះ ដែលរួមមាន ដូចជានៅមានក្រុមហ៊ុនអភិវឌ្ឍលំនៅឋានមួយចំនួនពុំមានអាជ្ញាបណ្ណត្រឹមត្រូវ ដោយសារការគេចវេសពីការស្នើសុំអាជ្ញាបណ្ណ ការស្វែងរកព័ត៌មានអំពីអាជ្ញាបណ្ណអាជីវកម្មរបស់ ក្រុមហ៊ុនអភិវឌ្ឍលំនៅនូវពុំទាន់មានលក្ខណៈងាយស្រួលនៅឡើយចំពោះបែបបទនូវ ការស្នើសុំលិខិតសាងសង់នៅមានលក្ខណៈស្មុគស្មាញ និងអ្នកប្រើប្រាស់លំនៅមួយចំនួនប្រឈមមុខបញ្ហា ទៅលើការសម្រេចចិត្តឆាប់រហ័សក្នុងការទិញលំនៅឋានផងដែរ។

អនុសាសន៍

តាមរយៈការសរសេរសារណានេះ ព្រមទាំងទទួលបានព័ត៌មានមួយចំនួននោះ នឹងការបកស្រាយខាងលើ បង្ហាញឱ្យឃើញនូវផលពិបាកមួយចំនួន យើងខ្ញុំសូមលើកយកនូវអនុសាសន៍ដ៏ស្ពួចស្ពើងដើម្បីចូលរួមចំនែកក្នុងការអភិវឌ្ឍលំនៅឋាននៅកម្ពុជាឱ្យឆ្ពោះទៅកាន់ភាពរីកចំរើនមួយកម្រិតទៀតដែលមានដូចជា៖

១/ ចំពោះព័ត៌មាននៃការស្នើសុំអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន ក្រសួងគួរតែមានយុន្តការនៃការបង្ហាញព័ត៌មានអំពីអាជ្ញាបណ្ណអាជីវកម្មរបស់ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននៅតាមប្រពន្ធ័ស្វ័យប្រវត្តកម្ម (ប្រពន្ធ័អនឡាញ) ដើម្បីបង្កើតភាពងាយស្រួល និងឆាប់រហ័សក្នុងការស្វែងរកព័ត៌មានរបស់ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។ លើសពីនេះទៅទៀតការ បង្កើតនូវប្រព័ន្ធស្វ័យប្រវត្តកម្មក៏ផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រង និងត្រួតពិនិត្យដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនមួយចំនួន ដែលមិនទាន់មានអាជ្ញាបណ្ណបណ្ណត្រឹមត្រូវ។ ម្យ៉ាងទៀតប្រព័ន្ធនេះគួរដាក់បញ្ចូលកាតព្វកិច្ចរបស់ក្រុមហ៊ុនក្នុងពេលដំណើរដែលបានតម្រូវពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធ្វើបច្ចុប្បន្នភាពរបស់ក្រុមហ៊ុន ដើម្បីចំនេញពេលវេលា និងប្រាក់។

២/ រដ្ឋាភិបាលគួរតែរៀបចំនីតិវិធីនៃការត្រួតពិនិត្យ និងការសំរេចលើលិខិតអនុញ្ញាតសាងសង់របស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានឱ្យមានភាពឆាប់រហ័សជាងមុន។

៣/រដ្ឋាភិបាលគួរតែបង្កើនទីផ្សារបន្ថែម ដើម្បីឲ្យទីផ្សារអាជីវកម្មនឹងនរ និងសមស្របតាមការរីកចំរើននៃវិស័យនេះ។

៤/ រដ្ឋាភិបាលគួរតែមានយន្តការទប់ស្កាត់ឲ្យបានតឹងរ៉ឹង ចំពោះសំណង់ណាដែលគ្មានលិខិតអនុញ្ញាតសាងសង់ និងម្ចាស់សំណង់ដែលគ្មានអាជ្ញាបណ្ណត្រឹមត្រូ រដ្ឋចជា: បញ្ឈប់មិនឲ្យសាងសង់ ផាកពិន័យ និងណែនាំឲ្យពួកគេយល់ពីសារៈប្រយោជន៍ នៃអគារដែលមានលិខិតអនុញ្ញាតត្រឹមត្រូវ និងជាពិសេសលើកទឹកចិត្តដល់ ក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅដែលមានអាជ្ញាបណ្ណត្រឹមត្រូវឲ្យមានទឹកចិត្តធ្វើការ។

៥/ ចំពោះនៅក្នុងវិស័យអភិវឌ្ឍលំនៅ អ្នកប្រើប្រាស់ មុននិងសម្រេចចិត្តទិញលំនៅឋានពីក្រុមហ៊ុនប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានណាមួយ ត្រូវពិនិត្យមើលនូវភាពស្របច្បាប់របស់ក្រុមហ៊ុនឲ្យបានច្បាស់លាស់ ក៏ដូចជាពិចារណាពីគោលបំណងនៃការទិញនេះដើម្បីទទួលបានផលចំនេញពីការវិនិយោគឬសម្រាប់ ការរស់នៅ ដែលពុំឲ្យជបការខាតបង់ និងបញ្ហានាពេលអនាគត។ ដូចនេះក្រោយពេលស្វែងយល់ពីបំណងរបស់ខ្លួនហើយ អ្នកទិញចាំបាច់ត្រួតពិនិត្យមើលលំនៅឋាននោះ និងភ្នែកហើយអ្នកប្រាស់ប្រើលំនៅឋានត្រូវមានចិត្តអំណត់ដោយមិនគួរប្រញាប់ទិញភ្លាមៗនោះទេ។

ឯកសារយោង

ឯកសារយោង

ក.បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥
- ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីវិសោធនកម្ម ថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៥
- **អនុក្រឹត្យ**
  - អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - អនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- **ប្រកាស**
  - ប្រកាសលេខ ៩៦៥ ចុះថ្ងៃ២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន
  - ប្រកាសលេខ ២១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពី ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស័យប្រវត្តកម្មរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
  - ប្រកាសលេខ ៤៩៦ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៦ស្តីពី ការចុះបញ្ជីពន្ធដារ
  - ប្រកាសលេខ ១៨២១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី វិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់
  - ប្រកាសលេខ ៥០៧ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
  - ប្រកាសរួមលេខ ១៦៤៣ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពី ការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួម លេខ៩៨៥ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
  - ប្រកាសអន្តរក្រសួងលេខ ០៣៣ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០០៦ ស្តីពីសោហ៊ុយសេវាសំណង់
  - ប្រកាសលេខ១០២ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពី ការផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនវិស្វកម្មឯករាជ្យ សម្រាប់គ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- **សេចក្តីសំរេច**

- សេចក្តីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

- **សេចក្តីជូនដំណឹង**
  - សេចក្តីជូនដំណឹងលេខ ១៦១៥ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម

- **សេចក្តីណែនាំ**
  - សេចក្តីណែនាំលេខ០១ ស្តីពីការរៀបចំ និងត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ សំរាប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង
  - សេចក្តីណែនាំ លេខ២៤៣៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ស្តីពី ការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសតាមរបបស្វ័យប្រកាស (ទម្រង់១០១)

ខ. សៀវភៅ

- ភៅ មុយថង ច្បាប់ពាណិជ្ជកម្ម បោះពុម្ពនៅឆ្នាំ ២០១៥

គ. គេហទំព័រ

- Youtube គណនី Ministry of Commerce Cambodia " www.youtube.com/watch?v=N7nrp9cvzdY " ចូលពិគ្រោះនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ

- ប្រកាសលេខ ៩៦៥ ចុះថ្ងៃ២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន
- តារាង ការកំណត់ថ្លៃ អាជ្ញាបណ្ណ សុពលភាព ថ្លៃសេវាសាធារណៈ និងរយៈពេលផ្តល់សេវាសាធារណៈរបស់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រតិភោគដោយអនុប្បទាន
- សៀវភៅបន្ទុក សម្រាប់អ្នកកាន់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន និង ពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូឯកសារតម្រូវ
- ប្រកាសលេខ ២១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពី ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្មរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- គំរូផ្ទាំងប្រព័ន្ធស្វ័យប្រវត្តកម្មនៃរប្រៀបចុះបញ្ជីពាណិជ្ជកម្ម
- សេចក្តីជូនដំណឹងលេខ ១៦១៥ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម
- គំរូ សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អភិបាល ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋ ឬវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ ៤៩៦ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៦ស្តីពី ការចុះបញ្ជីពន្ធដារ
- សេចក្តីណែនាំ លេខ២៤៣៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ស្តីពី ការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសតាមរបបស្វ័យប្រកាស (ទម្រង់១០១)
- ពាក្យស្នើសុំ ទម្រង់១០១
- ប្រកាសលេខ ១៨២១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់
- ប្រកាសលេខ ៥០៧ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- អនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតសាងសង់
- ប្រកាសអន្តរក្រសួងលេខ ០៣៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០០៦ស្តីពី សោហ៊ុយលើសេវាសំណង់
- សេចក្តីសំរេចលេខ ០៥ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

- សេចក្តីណែនាំលេខ០១ ស្តីពីការរៀបចំ និងត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ សំរាប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង
- គំរូនៃការដាក់ពាក្យ ដែលពាក់ព័ន្ធលិខិតអនុញ្ញាតសាងសង់

ក្រសួងសេដ្ឋកិច្ច និង
ហិរញ្ញវត្ថុ

- ប្រកាសលេខ ៩៦៥ ចុះថ្ងៃ២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពី ការគ្រប់គ្រងអាជីវកម្មអតិវឌ្ឍ លំនៅឋាន
- តារាង ការកំណត់ថ្លៃ អាជ្ញាបណ្ណ សុពលភាព ថ្លៃសេវាសាធារណៈ និងរយៈពេលផ្តល់សេ វាសាធារណៈរបស់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ជាំ និងប្រតិភោគ ដោយអនុប្បទាន
- ~~ទម្រង់ស្នើ សម្រាប់ស្នើសុំអាជ្ញាបណ្ណអាជីវកម្មអតិវឌ្ឍលំនៅឋាន~~ និង ពាក្យស្នើ សុំអាជ្ញាបណ្ណ និងកំរងឯកសារតម្រូវ

តារាងវិភាគបង់ប្រាក់តាមដំណាក់កាល

ដំណាក់កាល	បរិយាយ	ចំនួនភាគរយនៃការបង់ប្រាក់
១	ចុះកិច្ចសន្យា លក់- ទិញ	អតិបរមា ១0%
២	បញ្ចប់ការងារគ្រឹះ	អតិបរមា ១0%
៣	បញ្ចប់ការងារក្រោង	អតិបរមា ១0%
៤	បញ្ចប់ការងាររៀបឥដ្ឋជញ្ជាំង	អតិបរមា ១0%
៥	បញ្ចប់ការងារដំបូល	អតិបរមា ១0%
៦	បញ្ចប់ការងារដំឡើងទ្វារ បង្អួច និងបំពាក់គ្រឿងអគ្គីសនី	អតិបរមា ៥%
៧	បញ្ចប់ការងារចំណតយានយន្ត ផ្លូវចេញ- ចូល និងការងារប្រព័ន្ធទឹកស្អាត និងទឹកស្អុយ	អតិបរមា ៥%
៨	បញ្ចប់ការងារសំណង់អគារទាំងមូល	អតិបរមា ២៥%
៩	ទទួលបានលិខិតបិទការដ្ឋាន (ដកប្រាក់ឥម្ពស់ពីក្រសួង)	អតិបរមា ៥%
១0	ផ្ទេរសិទ្ធកាន់កាប់	អប្បបរមា ៥%
១១	បញ្ចប់កាតព្វកិច្ចលើការធានា	អប្បបរមា ៥%

តារាង

ស្តីពី

ការកំណត់ថ្លៃ អាជ្ញាបណ្ណ សុពលភាព ថ្លៃសេវាសាធារណៈ និងរយៈពេលផ្តល់សេវាសាធារណៈ

របស់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនទ្រព្យ បញ្ជាំ និងប្រាតិភាគដោយអនុប្បទាន÷

១. អាជ្ញាបណ្ណអាជីវកម្មអតិថិជ្ជលំនៅដ្ឋាន

ក. សំណង់ផ្ទះល្វែង

ទំហំ	ថ្លៃអាជ្ញាបណ្ណ (រៀល)	សុពលភាព	ថ្លៃសេវាសាធារណៈ	រយៈពេលផ្តល់សេវាសាធារណៈ
ចាប់ពី ០៤ - ១០ល្វែង	១០០,០០០/ល្វែង	ម្ចាស់គម្រោងជាអ្នកកំណត់	៣០០,០០០ រៀល	៣០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីឯកសារគ្រប់
ចាប់ពី ១១ - ៥០ល្វែង			៦០០,០០០ រៀល	
ចាប់ពី ៥១ - ១០០ល្វែង			១,០០០,០០០ រៀល	
ចាប់ពី ១០១ ល្វែងឡើងទៅ			១,៦០០,០០០ រៀល	

ខ. សំណង់ភូមិត្រឹះ

ទំហំ	ថ្លៃអាជ្ញាបណ្ណ (រៀល)	សុពលភាព	ថ្លៃសេវាសាធារណៈ (រៀល)	រយៈពេលផ្តល់សេវាសាធារណៈ
ភូមិត្រឹះក្លោះ	១០០,០០០/ភូមិត្រឹះ	ម្ចាស់គម្រោងជាអ្នកកំណត់	៦០០,០០០ (ពី ០៣-១០ ភូមិត្រឹះ)	៣០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីឯកសារគ្រប់
			១,២០០,០០០ (ពី ១១-៥០ ភូមិត្រឹះ)	
			២,២០០,០០០ (ពី ៥១ ភូមិត្រឹះឡើងទៅ)	
ភូមិត្រឹះទោល	២០០,០០០/ភូមិត្រឹះ		៦០០,០០០ (ពី ០៣-១០ ភូមិត្រឹះ)	
			១,២០០,០០០ (ពី ១១-៥០ ភូមិត្រឹះ)	
			២,២០០,០០០ (ពី ៥១ ភូមិត្រឹះឡើងទៅ)	

គ. សំណង់អគារសហកម្មសិទ្ធិ (Condominium)

ទំហំ	ថ្លៃអាជ្ញាបណ្ណ (រៀល)	សុពលភាព	ថ្លៃសេវាសាធារណៈ (រៀល)	រយៈពេលផ្តល់សេវាសាធារណៈ
០១-០២ បន្ទប់គេង	១០០,០០០/យូនីត	ម្ចាស់គម្រោង ជាអ្នកកំណត់	៣០០,០០០ (ពី ០៤-១០ យូនីត)	៣០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីឯកសារគ្រប់
០៣ បន្ទប់គេងឡើងទៅ	២០០,០០០/យូនីត		៦០០,០០០ (ពី ១១-៥០ យូនីត)	
			១,០០០,០០០ (ពី ៥១-១០០ យូនីត)	
			១,៦០០,០០០ (ពី ១០១-២០០ យូនីត)	
			២,០០០,០០០ (ពី ២០១-៤០០ យូនីត)	
			២,២០០,០០០ (ពី ៤០០ យូនីតឡើងទៅ)	

២. ទិញ្ញាបនបត្រទីជ្រាជីវៈ និងអាជ្ញាបណ្ណក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនទ្រព្យ

ប្រភេទ	ថ្លៃវិញ្ញាបនបត្រវិជ្ជាជីវៈ/អាជ្ញាបណ្ណ (រៀល)	សុពលភាព	ថ្លៃសេវាសាធារណៈ (រៀល)	រយៈពេលផ្តល់សេវាសាធារណៈ
អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន				៣០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីឯកសារគ្រប់
ភ្នាក់ងារអចលនទ្រព្យ	៥០០,០០០	០១ ឆ្នាំ	១០០,០០០	
សេវាកម្មវាយតម្លៃ	៥០០,០០០	០១ ឆ្នាំ	១០០,០០០	
សាខាភ្នាក់ងារអចលនទ្រព្យ	៣០០,០០០	០១ ឆ្នាំ	៦០,០០០	
សាខាសេវាកម្មវាយតម្លៃ	៣០០,០០០	០១ ឆ្នាំ	៦០,០០០	
វិញ្ញាបនបត្រវិជ្ជាជីវៈសម្រាប់បុគ្គល				
ភ្នាក់ងារអចលនទ្រព្យ	២០០,០០០	០១ ឆ្នាំ	៤០,០០០	
អ្នកវាយតម្លៃ	២០០,០០០	០១ ឆ្នាំ	៤០,០០០	

៣. អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ជាំ និងអាជីវកម្មទទួលប្រាក់ភោគដោយអនុប្បទាន

ប្រភេទអាជ្ញាបណ្ណ		ថ្លៃអាជ្ញាបណ្ណ (រៀល)	សុពលភាព	ថ្លៃសេវាសាធារណៈ (រៀល)	រយៈពេលផ្តល់ សេវាសាធារណៈ
អាជីវកម្មទទួលបញ្ជាំ					៣០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីឯកសារគ្រប់
អាជ្ញាបណ្ណ	ខ្នាតមធ្យម	២,០០០,០០០រៀល/ឆ្នាំ	០៣ ឆ្នាំ	៤០០,០០០	
	ខ្នាតធំ(កម្រិត១)	៣,០០០,០០០រៀល/ឆ្នាំ		៤០០,០០០	
	ខ្នាតធំ(កម្រិត២)	៤,០០០,០០០រៀល/ឆ្នាំ		៤០០,០០០	
អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	១,០០០,០០០រៀល/ឆ្នាំ		២០០,០០០	
	ខ្នាតធំ(កម្រិត១)	១,៥០០,០០០រៀល/ឆ្នាំ		២០០,០០០	
	ខ្នាតធំ(កម្រិត២)	២,០០០,០០០រៀល/ឆ្នាំ		២០០,០០០	
អាជីវកម្មទទួលប្រាក់ភោគដោយអនុប្បទាន					
អាជ្ញាបណ្ណ	ខ្នាតមធ្យម	១,០០០,០០០រៀល/ឆ្នាំ	០៣ ឆ្នាំ	២០០,០០០	៣០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីឯកសារគ្រប់
	ខ្នាតធំ(កម្រិត១)	១,៥០០,០០០រៀល/ឆ្នាំ		២០០,០០០	
	ខ្នាតធំ(កម្រិត២)	២,០០០,០០០រៀល/ឆ្នាំ		២០០,០០០	
អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	៥០០,០០០រៀល/ឆ្នាំ		១០០,០០០	
	ខ្នាតធំ(កម្រិត១)	៧៥០,០០០រៀល/ឆ្នាំ		១០០,០០០	
	ខ្នាតធំ(កម្រិត២)	១,០០០,០០០រៀល/ឆ្នាំ		១០០,០០០	

ចំណាំ÷

ថ្លៃបន្ថយសុពលភាពអាជ្ញាបណ្ណទទួលបញ្ជាំ និងប្រាក់ភោគដោយអនុប្បទានត្រូវបង់រៀងរាល់ ១ឆ្នាំម្តងនៅកណ្តាលធនាគារជាតិ ដែលបើកនៅធនាគារជាតិនៃកម្ពុជា តាមដីការអមរបស់នាយកដ្ឋាន។

អាជីវកម្មទទួលបញ្ជាំ (ចល័តវត្ថុ និងអចល័តវត្ថុ)÷

- ខ្នាតមធ្យម ត្រូវមានដើមទុនលើសពី ៤០លានរៀល ដល់ ២០០លានរៀល
- ខ្នាតធំ(កម្រិត១) ត្រូវមានដើមទុនលើសពី ២០០លានរៀល ដល់ ៨០០លានរៀល
- ខ្នាតធំ(កម្រិត២) ត្រូវមានដើមទុនលើសពី ៨០០លានរៀល ឡើងទៅ

អាជីវកម្មទទួលប្រាក់ភោគដោយអនុប្បទាន (ចល័តវត្ថុ)÷

- ខ្នាតមធ្យម ត្រូវមានដើមទុនលើសពី ៤០លានរៀល ដល់ ២០០លានរៀល
- ខ្នាតធំ(កម្រិត១) ត្រូវមានដើមទុនលើសពី ២០០លានរៀល ដល់ ៨០០លានរៀល
- ខ្នាតធំ(កម្រិត២) ត្រូវមានដើមទុនលើសពី ៨០០លានរៀល ឡើងទៅ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សៀវភៅបន្ទុក

សម្រាប់

អ្នកកាន់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនទ្រព្យ
បញ្ចាំ និងធ្នាតិភោគដោយអនុប្បទាន
ការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

ទូរស័ព្ទ: ០២៣ ៤២៧ ៩៣៥
ទូរសារ: ០២៣ ៤២៧ ៩០១
គេហទំព័រ: http://gdfi.mef.gov.kh

Ministry of Economy and Finance
General Department of Financial Industry
Real Estate Business and
Pawnshop Department
Housing Development Business Division

Tel: 023 427 935
Fax: 023 427 901
Website: http://gdfi.mef.gov.kh

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនទ្រព្យ
បញ្ចាំ និងធ្នាតិភោគដោយអនុប្បទាន

សៀវភៅបន្ទុក
សម្រាប់
អ្នកកាន់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន

-អនុលោមតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាបណ្ណសម្រាប់បុគ្គលអភិវឌ្ឍអចលនវត្ថុ

-អនុលោមតាមប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន

ប្រការ១ ÷ គោលបំណង

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍលំនៅឋាន
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍ រវាងក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន និងអ្នកប្រើប្រាស់
- បង្ការទប់ស្កាត់ហានិភ័យហិរញ្ញវត្ថុ ក្នុងវិស័យអចលនវត្ថុ សំដៅធានាស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច
- ធានាចីរភាពនៃការអភិវឌ្ឍវិស័យអចលនវត្ថុ សំដៅជំរុញកំណើនសេដ្ឋកិច្ច
- រួមចំណែកទប់ស្កាត់សកម្មភាពសម្អាតប្រាក់ ក្នុងវិស័យអាជីវកម្មអភិវឌ្ឍលំនៅឋាន។

តទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហៅកាត់ "**ក្រសួង**" នឹងផ្តល់អាជ្ញាបណ្ណអភិវឌ្ឍលំនៅឋានប្រភេទទី.....
ជូនក្រុមហ៊ុន.....មានទីតាំងនៅផ្ទះលេខ.....ផ្លូវលេខ.....
ភូមិ.....ឃុំ/សង្កាត់.....ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....
ដើម្បីប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋានដែលមានគម្រោងឈ្មោះ.....
ដែលមានទីតាំងនៅដីឡូត៍លេខ.....ផ្លូវលេខ.....ភូមិ.....ឃុំ/សង្កាត់.....
ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....ចាប់ពីពេលនេះតទៅ ។

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណទាំងអស់ ត្រូវគោរពនៅតាមលក្ខខណ្ឌនានាដែលមានចែងនៅក្នុងប្រកាសលេខ**៩៦៥** **សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦** **ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន** **និងសៀវភៅបន្ទុកនេះ**។

ប្រការ២ ÷ ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ

រាល់ការធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋាន ដែលមានទំហំចាប់ពី ០៤ ល្វែង ឬ ០៣ ភូមិត្រឹះ ឬ ០៤ យូនីត នៃលំនៅឋានឡើងទៅ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន នៅនាយកដ្ឋានគ្រប់គ្រងអាជីវកម្ម អចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដោយផ្តល់នូវឯកសារតម្រូវដូចខាងក្រោម÷

- លិខិត និងពាក្យស្នើសុំអាជ្ញាបណ្ណ (តាមគំរូរបស់ក្រសួង)
- រូបថតទំហំ ៤ × ៦ របស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំនួន ០៣សន្លឹក

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ
បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន

- លក្ខន្តិកៈក្រុមហ៊ុនថតចម្លង និង វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ថតចម្លង) នៅក្រសួងពាណិជ្ជកម្ម ដោយមានដើមទុនចុះបញ្ជីអប្បបរមា ២.០០០.០០០.០០០ (ពីរលានរៀល)
- លិខិតថ្លៃលទ្ធកម្មរបស់អ្នកឈ្នះលេលាជ្ជាបណ្ណ ចេញដោយក្រសួងយុត្តិធម៌ ឬចេញដោយប្រទេសសាមី (ចំពោះជនបរទេស)
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ថតចម្លង) របស់អ្នកឈ្នះលេលាជ្ជាបណ្ណ ឬលិខិតឆ្លងដែន និងទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា ចំពោះជនបរទេស
- លិខិតបញ្ជាក់ការបើកគណនីអភិវឌ្ឍលំនៅឋានៅធនាគារពាណិជ្ជណាមួយ (ចំពោះអាជ្ញាបណ្ណប្រភេទ២)
- ឯកសារបញ្ជាក់ប្រភពទុន
- លិខិតបញ្ជាក់ប្រាក់ពន្ធលើធានាអាជីវកម្ម ២% (ពីរភាគរយ) នៃដើមទុនវិនិយោគសរុប ឬតាមដំណាក់កាល (ចំពោះអាជ្ញាបណ្ណប្រភេទ២)
- បណ្ណធានាវ៉ាប់រងការៈទទួលខុសត្រូវការដ្ឋានដែលចេញដោយក្រុមហ៊ុនធានាវ៉ាប់រងក្នុងស្រុក
- លិខិតអនុញ្ញាតសាងសង់ និងលិខិតបើកការដ្ឋានសាងសង់ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច (ប្រសិនមាន)
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ថតចម្លង) ឬវិញ្ញាបនបត្រជួលរយៈពេលវែងដែលមានធ្វើនីតិវិធីនុវត្តដ្ឋានៅសាលារាជធានី-ខេត្ត និងឯកសារវាយតម្លៃដីដែលចេញដោយភ្នាក់ងារវាយតម្លៃអចលនវត្ថុ ដែលទទួលបានវិញ្ញាបនបត្រពីក្រសួង
- បណ្ណប៉ាតង់ (ថតចម្លង)
- ផែនការអាជីវកម្មលម្អិត ទៅតាមរយៈពេលនៃគម្រោង និងគំរូប្លង់សាងសង់
- គំរូកិច្ចសន្យាលក់-ទិញ ដែលមានវាយត្រាក្រុមហ៊ុន
- ឯកសារសម្រាប់ផ្សាយពាណិជ្ជកម្ម តារាងតម្លៃលក់ និងប្លង់ផ្ទះគំរូ
- វិក្កយបត្របង់ថ្លៃអាជ្ញាបណ្ណ និងសេវាសាធារណៈ

រាល់ការខកខានមិនបានផ្តល់ឯកសារចំពោះចំណុចណាមួយ ត្រូវចាត់ទុកថា មិនបានបំពេញឯកសារគ្រប់ចំនួន។
រាល់ការផ្តល់ឯកសារ ឬព័ត៌មានក្លែងបន្លំនឹងត្រូវចាត់ទុកថាជាបទល្មើស និងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ៣ ÷ លក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណ

អាជ្ញាបណ្ណត្រូវបានផ្តល់ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន សម្រាប់គម្រោងអភិវឌ្ឍលំនៅឋានតែមួយ នៅទីតាំងតែមួយ។ ក្នុងករណីគម្រោងអភិវឌ្ឍលំនៅឋានតែមួយត្រូវបានបែងចែកជាច្រើនដំណាក់កាល អាជ្ញាបណ្ណត្រូវបានផ្តល់ជូនទៅតាមដំណាក់កាលនីមួយៗនៃគម្រោងអភិវឌ្ឍលំនៅឋាន។

ប្រការ៤ ÷ ប្រភេទ និង ថ្លៃអាជ្ញាបណ្ណ

ក. ប្រភេទអាជ្ញាបណ្ណ

អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន ចែកចេញជា ២ ប្រភេទ គឺ÷

- អាជ្ញាបណ្ណប្រភេទ១÷ ផ្តល់ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលមានដើមទុនផ្ទាល់ខ្លួនតាំងស្រុង និង/ឬដើមទុនខ្ចីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗ ដើម្បីអភិវឌ្ឍលំនៅឋាន ... ...

- អាជ្ញាបណ្ណប្រភេទ២÷ ផ្តល់ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលមានដើមទុនផ្ទាល់ខ្លួនខ្ពស់ និង/ឬដើមទុនខ្វីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុខ្ពស់ និង/ឬដើមទុនដែលប្រមូលបានពីអ្នកទិញលំនៅឋានជាមុន ដើម្បីអភិវឌ្ឍលំនៅឋាន ដោយសង់បណ្តើរ លក់បណ្តើរ ស្របទៅតាមលក្ខខណ្ឌជូចបានកំណត់ក្នុងប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន អាចផ្លាស់ប្តូរប្រភេទអាជ្ញាបណ្ណដោយស្នើសុំការសម្រេចពីក្រសួងជាមុន។

ខ. ថ្លៃអាជ្ញាបណ្ណ

ថ្លៃអាជ្ញាបណ្ណ ត្រូវបានកំណត់ទៅតាមប្រភេទ និងទំហំនៃសំណង់ជូចខាងក្រោម ÷

ប្រភេទ	ទំហំ	ថ្លៃអាជ្ញាបណ្ណ (រៀល)
សំណង់ផ្ទះល្វែង	០១ ល្វែង	១០០.០០០រៀល/១ល្វែង
សំណង់ភូមិគ្រឹះ	ភូមិគ្រឹះភ្លោះ	១០០.០០០រៀល/១ភូមិគ្រឹះ
	ភូមិគ្រឹះទោល	២០០.០០០រៀល/១ភូមិគ្រឹះ
សំណង់អគារសហកម្មសិទ្ធិ	០១-០២ បន្ទប់គេង	១០០.០០០រៀល/ ១ យូនីត
	០៣ បន្ទប់គេងឡើងទៅ	២០០.០០០រៀល/ ១ យូនីត

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវបង់ថ្លៃអាជ្ញាបណ្ណជូចមានចែងខាងលើ ទៅគណនីទោលរតនាគារជាតិ ដែលបើកនៅធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ជាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

ប្រការ៥ ÷ ភាពកាតព្វកិច្ចរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានត្រូវអនុវត្តភាពកាតព្វកិច្ចជូចមានចែងក្នុងប្រការ ១៤ និងប្រការ ១៥ នៃប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។

ប្រការ៦ ÷ ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការហាមឃាត់

រាល់ការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ដែលទទួលបានអាជ្ញាបណ្ណប្រភេទ១ និងប្រភេទ២ ត្រូវគោរពទៅតាមលក្ខខណ្ឌជូចមានចែងក្នុងប្រការ១៧ នៃប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។

ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីគម្រោងអភិវឌ្ឍលំនៅឋានតាមគ្រប់រូបភាព ត្រូវបានហាមឃាត់ចំពោះបុគ្គលណា ដែលពុំទាន់ទទួលបានអាជ្ញាបណ្ណពីក្រសួង។

ការផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈជាការឆបោក ឬនាំឲ្យមានការយល់ខុស ឬធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ត្រូវបានហាមឃាត់ និងត្រូវទទួលពិន័យជូចមានចែងក្នុងប្រការ៤២ នៃប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ
បញ្ជាំ និងប្រាតិភោគដោយអនុប្បទាន

ប្រការ៧ ÷ ការលក់-ទិញលំនៅឋាន

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ១ អាចដំណើរការប្រតិបត្តិការលក់-ទិញបាន លុះត្រាតែក្រុមហ៊ុនបានបញ្ចប់ការសាងសង់គម្រោងជាស្ថាពរ ដែលមានការបញ្ជាក់ដោយលិខិតបិទការដ្ឋាន និង/ឬមានការវាយតម្លៃពីមន្ត្រីជំនាញរបស់នាយកដ្ឋានជាមុន។

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ២ អាចដំណើរការប្រតិបត្តិការលក់-ទិញបាន លុះត្រាតែក្រុមហ៊ុនមានលិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅពេលដែលមិនទាន់ទទួលបានលិខិតអនុញ្ញាតសាងសង់ ក្រុមហ៊ុនមានសិទ្ធិទទួលត្រឹមតែប្រាក់កក់ដំបូងយ៉ាងច្រើន ១% (មួយភាគរយ) នៃតម្លៃលក់ពីអ្នកទិញលំនៅឋានតែប៉ុណ្ណោះ។ ប្រាក់កក់ដំបូងនេះ ត្រូវរក្សាទុកនៅក្នុងគណនីអភិវឌ្ឍលំនៅឋាន និងមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់រហូតដល់ទទួលបានលិខិតអនុញ្ញាតសាងសង់។ ក្នុងករណីមិនទទួលបានលិខិតអនុញ្ញាតសាងសង់ ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវប្រគល់ប្រាក់កក់ដំបូងនេះជូនអ្នកទិញលំនៅឋានវិញទៅតាមលក្ខខណ្ឌកំណត់របស់ភ្លាមៗ។

ប្រការ៨ ÷ កិច្ចសន្យាលក់-ទិញ

រាល់កិច្ចសន្យាលក់-ទិញជាមួយអ្នកទិញលំនៅឋាន ត្រូវចែងឱ្យច្បាស់លាស់នូវព័ត៌មានអប្បបរមា ដូចមានចែងក្នុងប្រការ២១ និងត្រូវធ្វើឡើងឱ្យស្របទៅតាមប្រការ២២ នៃប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។

ប្រការ៩ ÷ លំនៅឋានគំរូ

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ត្រូវរៀបចំលំនៅឋានគំរូឱ្យបានរួចរាល់ មុនធ្វើការប្រកាសលក់លំនៅឋាន។ លំនៅឋានគំរូត្រូវរៀបចំជាក់ស្តែង ឱ្យស្របទៅតាមគំរូប្លង់ ទំហំ ការតុបតែង និងបំពាក់សម្ភារៈសំណង់ ដូចគម្រោងលំនៅឋានដែលនឹងត្រូវសាងសង់ ដើម្បីលក់ជូនអ្នកទិញលំនៅឋាន។ ចំពោះសម្ភារៈបំពាក់ និងគ្រឿងសង្ហារឹមដែលមិនផ្តល់ជូនត្រូវសរសេរស្លាកបិទឱ្យបានច្បាស់។

ប្រការ១០ ÷ គណនីអភិវឌ្ឍលំនៅឋាន

ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលទទួលបានអាជ្ញាបណ្ណប្រភេទ២ ត្រូវប្រើប្រាស់គណនីអភិវឌ្ឍលំនៅឋានឱ្យស្របទៅនឹងប្រការ២៨ និងប្រការ២៩ នៃប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។

រាល់ការដកប្រាក់ពីគណនីអភិវឌ្ឍលំនៅឋាន ត្រូវអនុលោមទៅតាមខ្លឹមសារដូចមានចែងក្នុងប្រការ២៩ នៃប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង អាជីវកម្មអភិវឌ្ឍលំនៅឋាន។

គណនីនេះ ត្រូវស្ថិតនៅក្រោមការតាមដានជាប្រចាំពីក្រសួង និងអាចបិទបាន លុះត្រាតែគម្រោងអភិវឌ្ឍលំនៅឋាននោះ បានបញ្ចប់ជាស្ថាពរ និងមានការឯកភាពពីក្រសួង។

ក្រសួងមានសិទ្ធិស្នើសុំបង្ហាញគណនីអភិវឌ្ឍលំនៅឋានរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន ក្នុងករណីដែលក្រសួងពិនិត្យឃើញថា ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាននោះ ពុំមានលទ្ធភាពសាងសង់ ឬចោះបង់ចោលការសាងសង់គម្រោងអភិវឌ្ឍលំនៅឋានរបស់ខ្លួន ឬ ប្រធានសក្តិ ឬដែលបានធ្វើឱ្យខូចប្រយោជន៍របស់អ្នកទិញលំនៅឋាន។

គណនីនេះ អាចត្រូវបានដាក់ឱ្យដំណើរការវិញបាន លុះត្រាតែមានការឯកភាពជាមុនពីក្រសួង។

ត្រូវនឹងសេក្តីពិត និង ហត្ថលេខា
នាយកដ្ឋានគ្រប់គ្រងអាជីវកម្ម
ហ៊ីង ធ្លាត់ រៀបរៀងដោយអនុប្បធាន

ខ្ញុំបាទ/នាងខ្ញុំ សូមបញ្ជាក់ថា ពិតជាបានអាន និងយល់ព្រមអនុវត្តទាំងស្រុង ទៅតាមប្រការដែលមានចែងនៅក្នុងសៀវភៅបន្ទុកនេះ។ បើខ្ញុំបាទ/នាងខ្ញុំបានប្រព្រឹត្តិផ្ទុយទៅនឹងសៀវភៅបន្ទុកនេះ ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ.....

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ

សៀវភៅបន្ទុកនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះ
ហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ.....

បានឃើញ និង ឯកភាព

រដ្ឋលេខាធិការ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានសេដ្ឋាភិបាលកម្មហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ
បញ្ជាំ និងប្រតិបត្តិការដោយអនុម្យាន

ឯកសារតម្រូវ
សម្រាប់ជាក់ការស្នើសុំអាជ្ញាបណ្ណអភិវឌ្ឍលំនៅដ្ឋាន (ប្រភេទ ២)
List of required documents for Applying for Housing Development License (2nd Type)

ក្រុមហ៊ុន (Company)/ឃុំ (Borey): .....

លរ	ឈ្មោះឯកសារ (Documents name)	មាន
១	លិខិត និងពាក្យស្នើសុំអាជ្ញាបណ្ណ (មានគំរូ Letter of Intent and Application Form (Sampled)	
២	រូបថតទំហំ ៤x ៦ របស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំនួន ៣ សន្លឹក Three 4 x 6 sized photos of licensee	
៣	លក្ខន្តិកៈក្រុមហ៊ុន និងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម (ថតចម្លង) ដោយមានដើមទុនចុះបញ្ជីអប្បបរមា ២ ប៊ីលានរៀល Article of association and certificate of Company registration by the Ministry of Commerce (Copied) with capital registered of 2 Billions Riel	
៤	លិខិតប្រាសចោទរបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណចេញដោយក្រសួងយុត្តិធម៌ (ចំពោះជនជាតិខ្មែរ) ឬចេញដោយប្រទេសសាមី (ចំពោះជនបរទេស) Criminal record of Licensee by the Ministry of Justice (for Cambodian) or by the authority of the country of origin (for Foreigner)	
៥	អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជារបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំពោះជនបរទេស (ថតចម្លង) Cambodian ID card or Passport and Entry Visa to the Kingdom of Cambodia of Licensee for foreigner (Copied)	
៦	ឯកសារបញ្ជាក់ដើមទុនសម្រាប់អភិវឌ្ឍគម្រោងទាំងមូល ឬតាមដំណាក់កាល Document to approve capital for the entire project or project in phase	
៧	លិខិតបញ្ជាក់ការបើកគណនីអភិវឌ្ឍលំនៅដ្ឋានៅធនាគារពាណិជ្ជណាមួយ (មានគំរូ Certified Letter on Housing Development Account by any licensed Commercial Bank in Cambodia for the Housing Development Project (Sampled)	
៨	លិខិតបញ្ជាក់ប្រាក់កម្ពស់ធានាអាជីវកម្ម២% នៃដើមទុនវិនិយោគសរុប ឬតាមដំណាក់កាល (មានគំរូ Certified Letter of 2% Business Deposit of total Investment cost or by phase (Sampled)	
៩	បណ្ណធានាភ័ស្តុភារៈទទួលទុសត្រូវការដ្ឋានដែលចេញដោយក្រុមហ៊ុនធានាភ័ស្តុភារក្នុងស្រុកណាមួយ Insurance Policy on Construction Site (Contractor's All Risks) issued by any licensed insurance company in Cambodia	
១០	លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន និងតម្រោងប្លង់ស្ថាបត្យកម្ម ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលាភូមិ-នគរ (ថតចម្លង) ប្រសិនបើមាន Construction permit; Construction site permits and Architecture plan approved by the Ministry of Land Management, Urban Planning and Construction or by authorities (Copied) if any	
១១	វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រជួលរយៈពេលវែងដែលមានធ្វើនីតិវិធីនៅសាលាភូមិ-នគរ (ថតចម្លង) Copied Certificate of Land ownership title or Certificate of long-term Lease legalized by provincial or municipal authority	
១២	បណ្ណប៉ាតង់ (ថតចម្លង) Patent (Copied)	
១៣	ផែនការអាជីវកម្ម (ផ្នែកលើរយៈពេលនៃគម្រោងទាំងមូល) Business plan	
១៤	គំរូកិច្ចសន្យាលក់-ទិញ មានត្រាយីហោ Sample of Buy-and-Sale Agreement with company stamp	
១៥	ឯកសារសម្រាប់ផ្សាយពាណិជ្ជកម្ម និងតារាងតម្លៃលក់ Advertisement Materials and Price list	
១៦	វិក្កយបត្របង់ថ្លៃអាជ្ញាបណ្ណ និងសេវាសាធារណៈ: Receipts on License Fee and Public Service Fee	

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
អ្នកយកលិខិត

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
អ្នកទទួល

បានទទួលឯកសារគ្រប់ចំនួន
ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ជាំ
និងប្រតិបត្តិការដោយអនុម្យាន
ប្រធាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ
បណ្ណាំ និងព្រាតិភាគដោយអនុប្រធាន

ឯកសារតម្រូវ
សម្រាប់ជាក់ពាក្យស្នើសុំអាជ្ញាបណ្ណអភិវឌ្ឍន៍ដីនៅទីតាំង (ប្រភេទ ១)

List of required documents for Applying for Housing Development License (1st Type)

ក្រុមហ៊ុន (Company)/**ឃុំ** (Borey): .....

ល.រ	**ឈ្មោះឯកសារ** (Documents name)	**មាន**
១	លិខិត និងពាក្យស្នើសុំអាជ្ញាបណ្ណ (មានគំរូ Letter of Intent and Application Form (Sampled)	
២	រូបថតទំហំ ៤ x ៦ របស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំនួន ៣ សន្លឹក Three 4 x 6 sized photos of licensee	
៣	លក្ខន្តិកៈក្រុមហ៊ុន និងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម (ថតចម្លង) ដោយមានដើមទុនចុះបញ្ជីអប្បបរមា ២ ប៊ីលានរៀល Article of association and certificate of Company registration by the Ministry of Commerce (Copied) with capital registered of 2Billions Riel	
៤	លិខិតថ្លៀងមោសរបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណចេញដោយក្រសួងយុត្តិធម៌ (ចំពោះជនជាតិខ្មែរ) ឬចេញដោយប្រទេសសាមី (ចំពោះជនបរទេស) Criminal record of Licensee by the Ministry of Justice (for Cambodian) or by the authority of the country of origin (for Foreigner)	
៥	អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជារបស់អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ចំពោះជនបរទេស (ថតចម្លង) Cambodian ID card or Passport and Entry Visa to the Kingdom of Cambodia of Licensee for foreigner (Copied)	
៦	ឯកសារបញ្ជាក់ដើមទុនសម្រាប់អភិវឌ្ឍគម្រោងទាំងមូល ឬតាមដំណាក់កាល Document to approve capital for the entire project or project in phase	
៧	បណ្ណធានានាភ័ប់រងលើការៈទទួលនុសត្រូវការងារនានាដែលចេញដោយក្រុមហ៊ុនធានានាភ័ប់រងក្នុងស្រុកណាមួយ Insurance Policy on Construction Site (Contractor's All Risks) issued by any licensed insurance company in Cambodia	
៨	លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន និងគម្រោងប្លង់ស្ថាបត្យកម្ម ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី-ខេត្ត (ថតចម្លង) ប្រសិនបើមាន Construction permit; Construction site permits and Architecture plan approved by the Ministry of Land Management, Urban Planning and Construction or by authorities (Copied) if any	
៩	វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រជួលរយៈពេលវែងដែលមានធ្វើនិត្យានុកូលកម្មនៅសាលារាជធានី-ខេត្ត (ថតចម្លង) Copied Certificate of Land ownership title or Certificate of long-term Lease legalized by provincial or municipal authority	
១០	បណ្ណជាតង់ (ថតចម្លង) Patent (Copied)	
១១	ផែនការអាជីវកម្ម (ផ្នែកបើរយៈពេលនៃគម្រោងទាំងមូល) Business plan	
១២	គំរូកិច្ចសន្យាលក់-ទិញ មានវាយត្រាក្រុមហ៊ុន Sample of Buy-and-Sale Agreement with company stamp	
១៣	ឯកសារសម្រាប់ផ្សាយពាណិជ្ជកម្ម និងតារាងតម្លៃលក់ Advertisement Materials and Price list	
១៤	វិក្កយបត្របង់ថ្លៃអាជ្ញាបណ្ណ និងសេវាសាធារណៈ Receipts on License Fee and Public Service Fee	

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
អ្នកប្រគល់

បានទទួលឯកសារគ្រប់ចំនួន
ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
អ្នកទទួល

បានឃើញ និងឯកភាព
ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បណ្ណាំ
និងព្រាតិភាគដោយអនុប្រធាន
ប្រធាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ
បញ្ចាំ និងប្រាតិហារ

Photo
4X6

ពាក្យស្នើសុំអាជ្ញាបណ្ណអភិវឌ្ឍលំនៅដ្ឋាន
សម្រាប់ប្រភេទ ☐ ១ ឬ ☐ ២

APPLICATION FORM FOR A HOUSING DEVELOPER'S LICENSE

FOR TYPE ☐ 1 or ☐ 2

សម្រាប់មន្ត្រីមានសមត្ថកិច្ច (FOR OFFIACIAL USED ONLY)		
ថ្លៃអាជ្ញាបណ្ណ (License fee):		.....រៀល
វិក្កយបត្របង់ថ្លៃអាជ្ញាបណ្ណ (License fee receipt)	កាលបរិច្ឆេទ (Transaction date):	...../...../.....
	លេខវិក្កយបត្រ (Ref. No)	.....
ប្រាក់តម្កល់ (Deposit)	ឈ្មោះធនាគារ (Bank)	.....
	ចំនួនទឹកប្រាក់ (Amount)	.....
	សុពលភាព (Expiration Date)	...../...../.....
គណនីអភិវឌ្ឍលំនៅដ្ឋាន (Housing Development Account)	លេខគណនី (Acc. Number)	.....
	ឈ្មោះធនាគារ (Bank)	.....

I. ឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋាន (Name and Address of Housing Development Company)

ក. ឈ្មោះក្រុមហ៊ុន (Company's Name)

១- ឈ្មោះជាភាសាខ្មែរ (Name in Khmer) : .....

២- ឈ្មោះជាភាសាអង់គ្លេស (Name in English) : .....

ខ. អាសយដ្ឋានក្រុមហ៊ុន (Company's Address)

១- ផ្ទះលេខ (House No):..... ផ្លូវលេខ (Street No): .....

២- ភូមិ (Village):..... ឃុំ / សង្កាត់ (Commune / Sangkat) : .....

៣- ក្រុង/ ស្រុក/ ខណ្ឌ (City/District /Khan): ..... រាជធានី/ ខេត្ត (Capital/Province): .....

៤- ទូរស័ព្ទ (Mobile/Telephone):..... ទូរសារ (Fax):.....

៥- អ៊ីមែល (Email):..... គេហទំព័រ (Website Address):.....

II. ឈ្មោះរបស់ភាគទុនិក (Name of Shareholders)

ឈ្មោះភាគទុនិកកម្ពុជា (Cambodian's Shareholder)	ភេទ Sex	ភាគរយ Percentage	ឈ្មោះភាគទុនិកបរទេស (Foreigner's Shareholder)	សញ្ជាតិ Nationality	ភេទ Sex	ភាគរយ Percentage
១.			១.			
២.			២.			
៣.			៣.			
៤.			៤.			

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនៈ
បញ្ចាំ និងប្រាតិហារ

III. សេចក្តីសង្ខេបរបស់អ្នកលក់ឈ្មោះលើអាជ្ញាបណ្ណ (Background of licensee):

១- ឈ្មោះ (Name of licensee)

- ឈ្មោះជាភាសាខ្មែរ (Name in Khmer): .....
- ឈ្មោះជាភាសាអង់គ្លេស (Name in English) : .....

២- ភេទ (Sex): ☐ ប្រុស (Male) : ☐ ស្រី (Female)

៣- ថ្ងៃ ខែ ឆ្នាំកំណើត (Date of Birth): ...../...../.....

៤- ទីកន្លែងកំណើត (Place of Birth):

- ភូមិ (Village): ..... ឃុំ / សង្កាត់ (Commune / Sangkat) : .....
- ក្រុង/ស្រុក / ខណ្ឌ (City/District / Khan): ..... រាជធានី / ខេត្ត (Capital/Province): .....
- ប្រទេស (Country): .....

៥- សញ្ជាតិ (Nationality): .....

៦- អត្តសញ្ញាណបណ្ណលេខ (ID No): ..... ផុតកំណត់ (Expired Date): ...../...../.....

ឬកាន់លិខិតឆ្លងដែនលេខ(Passport No):..... ផុតកំណត់ (Expired Date): ...../...../.....

៧- លេខទូរស័ព្ទ (Mobile phone):..... អ៊ីមែល (Email):.....

IV. ឈ្មោះ និង ទីតាំងគម្រោងសំណង់ដែលត្រូវអតិថិជន (Project's name and location)

១. ឈ្មោះគម្រោង (Project's name) .....

២. ទីតាំងគម្រោង (Project's Location)

- ដីឡូត៍លេខ (Lot No):..... ស្ថិតនៅផ្លូវលេខ (Street No):.....
- ភូមិ (Village): ..... ឃុំ / សង្កាត់ (Commune / Sangkat): .....
- ក្រុង/ស្រុក / ខណ្ឌ (City/District /Khan): ..... រាជធានី/ ខេត្ត (Capital/Province): .....
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យលេខ (Land Ownership Title No): .....
- ឈ្មោះកម្មសិទ្ធិករ (Name of Registered Owner(s)): .....

V. ប្រភេទ ទំហំ និងតម្លៃគម្រោង (Type, Size and Cost of project)

១. គម្រោងរួម (Whole Project)

ប្រភេទលំនៅដ្ឋាន (Type of Project)		ទំហំគម្រោង (Project Size)			តម្លៃគម្រោងសរុប (Total Project Cost)		រយៈពេលគម្រោងទាំងមូល (Duration of the whole project)	ចំនួនដំណាក់កាល (Number of Phases)
		ចំនួនលំនៅដ្ឋាន (Number unit)	សំណង់ (m²) Construction (sqm)	ដី (m²) Land (sqm)	ថ្លៃសំណង់ (ដុល្លា) Construction Cost ($)	ថ្លៃដី (ដុល្លា) Land Cost ($)		
ផ្ទះល្វែង (Town/Flat house/Shop house)								
ភូមិត្រីះ (Villas)	នោះ (Single)							
	ភ្លោះ (Twin)							
អគារសហកម្មសិទ្ធិ Condominium	បន្ទប់គេង 1 (1 bedroom)							
	បន្ទប់គេង 2 (2 bedrooms)							
	៣ បន្ទប់គេងឡើងទៅ (From 3 bedroom Up)							
កន្លែងរួម (Common Area)								
សរុប (Total)								

ប្រធានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនទ្រព្យ
បណ្ឌិត ជ ចន្ធារ៉ា

២. សម្រាប់គម្រោងវិនិយោគដំណាក់កាលទី .... (For Investment in phase ...)

ប្រភេទលំនៅឋាន (Type of Project)		ទំហំគម្រោង (Project Size)			តម្លៃគម្រោង (Total Project Cost)		រយៈពេលគម្រោងនៃដំណាក់កាលស្នើសុំ (Duration of the phased project in this phase)
		ចំនួនលំនៅឋាន (Number of unit)	សំណង់ (ម២) Construction(sqm)	ដី (ម២) Land (sqm)	ថ្លៃសំណង់ (ដុល្លា) Construction Cost ($)	ថ្លៃដី (ដុល្លា) Land Cost ($)	
ផ្ទះល្វែង (Town/Flat house/Shop house)							
ភូមិគ្រឹះ (Villas)	ដាច់ (Single)						
	ភ្លោះ (Twin)						
អគារសហកម្មសិទ្ធិ Condominium	បន្ទប់គេង 1 (1 bedroom)						
	បន្ទប់គេង 2 (2 bedrooms)						
	៣ បន្ទប់គេងឡើងទៅ (From 3 bedrooms Up)						
តំបន់រួម (Common Area)							
សរុប (Total)							

VI. ប្រភពទុនទីនិយោគនៃគម្រោង (Source of Investment Capital of the project)

ដើមទុន (Investment Capital)		ភាគរយ (%)	ប្រភពទុន (Source of fund)		
			ក្នុងប្រទេស (Local %)	ក្រៅប្រទេស (Overseas)	
				(%)	ឈ្មោះប្រទេស (Country name)
ទុនផ្ទាល់ខ្លួន (Own Capital)	ទ្រព្យសកម្ម (Current Asset)				
	ទ្រព្យអចិន្ត្រៃយ៍ (Fixed Asset)				
ហិរញ្ញប្បទានពីធនាគារ (Loan from Bank)					
ទុនពីការលក់ (Fund from Sale)					

ខ្ញុំបាទ/នាងខ្ញុំ ជាក្រុមហ៊ុនអភិវឌ្ឍលំនៅឋានសូមដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់**អភិវឌ្ឍលំនៅឋាន** ដោយស្របទៅតាមប្រកាសស្តីពី**ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន** និងសូមភ្ជាប់មកជាមួយនូវឯកសារតម្រូវចាំបាច់ដូចមានជូនភ្ជាប់។

I, a Housing Developer would like to apply for housing development license with the Prakas on Housing Development with the attaching files.

ខ្ញុំបាទ/នាងខ្ញុំ សូមបញ្ជាក់ជានិច្ចារិកថា ព័ត៌មានដែលបានបំពេញខាងលើគឺពិតជាត្រឹមត្រូវ និងបានធ្វើដោយចំណេះដឹងរបស់ខ្ញុំបាទ/នាងខ្ញុំពិតប្រាកដមែន។ បើព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយ ឬទុសពីការពិត ខ្ញុំបាទ/នាងខ្ញុំសូមទទួលទុសត្រូវនៅចំពោះមុខច្បាប់។

I hereby declare to the best of my knowledge that the particulars given above are true. I understand that any misleading statement, false representation or description of the above particulars in an offence under the law of the Kingdom of Cambodia.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ.....

ហត្ថលេខា និងត្រាក្រុមហ៊ុន

(Signature of Applicant and Company stamp)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

LOGO
ក្រុមហ៊ុន

លេខ:.....

ខ្ញុំបាទឈ្មោះ.....

ជានាយកក្រុមហ៊ុន/ឃុំ.....

<u>សូមគោរពជូន</u>

ឯកឧត្តមទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

<u>កម្មវត្ថុ:</u> សំណើសុំអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋានសម្រាប់ក្រុមហ៊ុន..... ដែលមានទីតាំងស្ថិតនៅភូមិ..... សង្កាត់..... ខណ្ឌ..... រាជធានី/ខេត្ត..... ។

<u>យោង:</u> ប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបថា ក្រុមហ៊ុន..... ខ្ញុំបាទ/នាងខ្ញុំមានបំណងធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋាន ដែលមាន គម្រោងឈ្មោះ ..... មានទីតាំងស្ថិតនៅដីឡូតិ៍លេខ..... ផ្លូវលេខ..... ភូមិ..... សង្កាត់..... ខណ្ឌ..... រាជធានី/ខេត្ត.....។ ដើម្បីអនុវត្តន៍អោយស្របតាមប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំបាទ/នាងខ្ញុំសូមដាក់ពាក្យស្នើសុំអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋានដូចមានឯកសារជូនភ្ជាប់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាផ្តល់អាជ្ញាបណ្ណអភិវឌ្ឍលំនៅឋានសម្រាប់ក្រុមហ៊ុន.....របស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

រាជធានីភ្នំពេញ,ថ្ងៃទី.....ខែ.....ឆ្នាំ.....

ហត្ថលេខា និងត្រា
នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារ.....

លេខ: .....

រាជធានីភ្នំពេញ, ថ្ងៃទី ..... ខែ..... ឆ្នាំ .....

<u>លិខិតបញ្ជាក់ពីធនាគារ</u>

ជូនចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តាមសំណើរបស់លោក/លោកស្រី .....
តំណាងឲ្យក្រុមហ៊ុន/ឃុរ.....

